ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ដើម្បីធានាឱ្យបានយុត្តិធម៌
- ការព្រួយបារម្ភរបស់ម្ដាយ ឌុច និងវិស័យច្បាប់នៅកម្ពុជា

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៤៣ ខែកក្កដា ឆ្នាំ២០០៣

## មាតិកា

◆ សំបុត្រៈ ដើម្បីធានាឲ្យបានយុត្តិធម៌ ....................................១

**ផ្នែកឯកសារ**

◆ សួស នៅ ហៅសមមិត្ត ឈូក..........................................២

◆ កំណត់ហេតុនៃការប្រជុំសមមិត្ត តាល់.....................................៧

◆ ជីវិត ខៀវ ប៉ុណ្ណារី ........................................................៨

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១..........១០

◆ (ឯកសារខ្មែរក្រហម)ៈដំណឹងផ្សេងៗស្រង់ពីវិទ្យុបរទេស .........១២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ការព្រួយបារម្ភរបស់ម្តាយ ឌុច ........................................១៥

◆ យាយអន រំឭករឿងដើម ..............................................១៩

◆ ការធ្វើកោសល្យវិច័យទៅលើឆ្អឹង.................................... ២៣

◆ មរតកក្រោយសង្គ្រាម ...............................................២៦

◆ សំណល់បដិវត្តន៍ .........................................................២៩

◆ តើការបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមគឺជាបញ្ហាកម្មផល? ..៣៣

◆ រឿងរ៉ាវមនុស្សស៊ីសាច់មនុស្ស............................................៣៥

**ផ្នែកច្បាប់**

◆សហគមន៍អន្តរជាតិអាចបញ្ចៀសអំពើប្រល័យពូជសាសន៍......... ៣៧

**វេទិកាពិភាក្សាសាធារណៈ**

◆ការអប់រំប្រវត្តិសាស្ត្ររបបខ្មែរក្រហម.................................៤០

◆ដំណើរការយុត្តិធម៌ជូនជនរងគ្រោះនៃរបបខ្មែរក្រហម ............៤២

◆ ការយល់ឃើញរបស់ប្រជាជនកម្ពុជាចំពោះតុលាការ .............៤៤

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ខ្ញុំចង់បានសន្តិភាពពិតប្រាកដ ..........................................៥៩



ម្តាយឌុចៈ គីម សៀវ

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្មេរលេខនេះៈ** យិន នាន, វ៉ាន់ថាន់ ពោដារ៉ា, ឡុង ដានី, ទុម ទិរ៉ា, ផេង ពង្សរ៉ាសុី, ផាន់ សុជា, អែម សុខឃីម, ជួប ខាំលី, ចន ឆរធីអារី, វីជីនី ឡាឌីស **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុជល, សើ សាយ្យាណា **ជំនួយការនិពន្ធនាយកៈ** សាន់ កល្យាណ **និពន្ធនាយករងៈ** ស៊ូ ប៊ុនស៊ូ **អ្នកបកប្រែៈ** អេង កុកថាយ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្រ្ត **គ្រប់គ្រងការចែកផ្សាយៈ** មាស ប៊ុនថាន

***សំបុត្រៈ***

# ដើម្បីធានាឱ្យបានយុត្តិធម៌

នៅពេលដែលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមខិតចូលមកដល់ យើងកំពុងតែពិចារណាថាតើយើងត្រូវគាំទ្រដល់ដំណើរការជំនុំជម្រះក្តីតាមវិធីណាខ្លះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាសន្យាថានឹងផ្តល់នូវព័ត៌មានដែលមិនលម្អៀងជូនចំពោះអង្គជំនុំជម្រះវិសាមញ្ញ ចៅក្រមស៊ើបអង្កេត ព្រះរាជអាជ្ញា និងមេធាវីការពារក្តី ។ យើងបានចាប់ផ្តើមអនុវត្តគោលការណ៍សំខាន់ៗដែលយើងបានស្នើឡើងហើយ ដើម្បីធានានូវសន្តិសុខនិងសិទ្ធិក្នុងការប្រើប្រាស់ឯកសារភ័ស្តុតាង ។ យើងកំពុងតែធ្វើការជាមួយអ្នកជំនាញការច្បាប់ដើម្បីធ្វើឲ្យគោលការណ៍ទាំងនោះមានលក្ខណៈត្រឹមត្រូវ មានតម្លាភាព និងមានប្រសិទ្ធភាពតាមតែអាចធ្វើទៅបាន ។ ចំណុចចុងក្រោយមួយទៀតគឺយើងកំពុងតែពិភាក្សាជាមួយអង្គការក្រៅរដ្ឋាភិបាលដទៃទៀតដែលពាក់ព័ន្ធ ។ នៅក្នុងកិច្ចប្រជុំជាមួយបណ្តាអង្គការក្រៅរដ្ឋាភិបាលទាំងនោះ យើងបានរិះរកគ្រប់មធ្យោបាយដើម្បីកំណត់ចេញនូវតួនាទីដ៏មានសារសំខាន់បំផុតដែលយើងអាចប្រើប្រាស់ ។

យើងកំពុងតែគិតពិចារណាទៅលើលទ្ធភាពនៃការបើកការិយាល័យផ្គត់ផ្គង់តុលាការតូចមួយដែលនឹងផ្តល់នូវជំនួយការដល់អង្គតុលាការនិងមេធាវីការពារក្តី ។ ប៉ុន្មានឆ្នាំមុន មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការវិភាគយ៉ាងច្រើនដោយផ្អែកលើមូលដ្ឋានគតិយុត្តិទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ និងវិភាគទៅលើភ័ស្តុតាងនៃការរំលោភបំពានដែលប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហម ។ ការិយាល័យផ្គង់ផ្គង់របស់យើងនឹងផ្តល់ជាមគ្គុទ្ទេសក៍ដល់មេធាវីការពារក្តីនិងអ្នកស៊ើបអង្កេត ឲ្យទទួលបាននូវធនធានសមស្របដែលយើងមាន ហើយជួយឲ្យអ្នកទាំងនោះចុះធ្វើការស៊ើបអង្កេត វិភាគឯកសារនិងធ្វើកិច្ចការជាក់ស្តែងផ្សេងៗទៀតដែលទាក់ទងទៅនឹងការស្វែងរកការពិត ។ ប្រសិនបើអង្គការសហប្រជាជាតិបើកស្ថាប័នអយ្យការជិតការិយាល័យធំរបស់ខ្លួននៅទីក្រុងញូវយ៉ក យើងសង្ឃឹមនិងមានបំណងចង់បើកការិយាល័យតូចមួយនៅទីនោះ ដែលមានបុគ្គលិកមួយរូបឬច្រើនរូបជាទីប្រឹក្សាច្បាប់របស់យើង និងមានបុគ្គលិកខ្មែរមួយរូបឬច្រើនរូបទៅតាមតម្រូវការជាក់ស្តែង ។ យើងនឹងផ្តល់ដល់ការិយាល័យរបស់យើងនូវឯកសារចម្លងពីឯកសារដើមដែលចងក្រងនៅទីក្រុងភ្នំពេញ ។

ការលំបាកដែលយើងត្រូវជួបប្រទះនាពេលនេះគឺបញ្ហាសន្តិសុខ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែស្ថិតក្នុងការប្រុងប្រយ័ត្នចំពោះការគំរាមកំហែងផ្នែកសន្តិសុខជាមធ្យម ។ ចាប់តាំងពីឆ្នាំ១៩៩៩ នៅពេលដែលអង្គការចាត់តាំងយោធានិងនយោបាយរបស់ខ្មែរក្រហមត្រូវដួលរលំ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានអនុវត្តការងាររបស់ខ្លួននៅក្នុងប្រទេសកម្ពុជាដោយគ្មានបញ្ហាអ្វីឡើយ ។ យើងធ្លាប់បានទទួលការគំរាមកំហែងដល់អាយុជីវិត និងការគំរាមកំហែងដាក់គ្រាប់បែកពីសំណាក់ប្រភពរបស់ខ្មែរក្រហម ។ មន្ត្រីរដ្ឋាភិបាលកម្ពុជាក៏បានប្រាប់យើងឲ្យដឹងជាមុនអំពីការគំរាមកំហែងមិនលេចមុខច្បាស់លាស់ពីសំណាក់អតីតកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហម ។ សំណាងល្អការវាយប្រហារដោយមិនប្រយោលមកលើមជ្ឈមណ្ឌលឯកសារកម្ពុជាមកទល់នឹងពេលនេះមិនទាន់ទទួលរងនូវការខូចខាតឬរបួសធ្ងន់ធ្ងរទេ ។ ប៉ុន្តែយើងប្រមើលឃើញថា តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនឹងចេញជារូបរាងខាងមុខនេះនឹងដាក់ទម្ងន់សន្តិសុខមកលើយើងមួយកម្រិតទៀត ។ ខៀវ សំផន អតីតប្រធានគណៈប្រធានរដ្ឋខ្មែរក្រហមបាននិយាយជាសាធារណៈថាដីកាចោទប្រកាន់នឹងនាំដល់ការ«ផ្ចាញ់តបវិញ»ជាក់ជាមិនខាន ។ ដើម្បីដោះស្រាយបញ្ហាគំរាមកំហែងដល់មជ្ឈមណ្ឌលនិងបុគ្គលិករបស់យើង យើងបានចាប់ផ្តើមត្រួតពិនិត្យទៅលើស្ថានភាពនិងប្រព័ន្ធសន្តិសុខរបស់យើងនៅក្នុងពេលនេះ ។ យើងកំពុងតែចាត់វិធានការទប់ទល់ទៅនឹងការគំរាមកំហែងផ្នែកសន្តិសុខដែលនឹងកើតមានក្នុងរយៈដ៏ខ្លីខាងមុខនេះ ។ **ឆាំង យុ**

*(អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាព)*

# សួស នៅ ហៅសមមិត្ត ឈូក

សួស នៅ មានឈ្មោះក្នុងបដិវត្តន៍ សួស សុត ហៅ ឈូក, ម៉ែន ឬ VIII ។ ឪពុកម្តាយរបស់ ឈូក ស្ថិតក្នុងវណ្ណៈភាពជាកសិករកណ្តាលថ្នាក់ក្រោម មានមុខរបរធ្វើស្រែ មានទីលំនៅនៅតំបន់២៣ ខេត្តស្វាយរៀង ។ ក្រោយពីបានចូលបម្រើក្នុងជួរបដិវត្តអស់រយៈពេល៩ឆ្នាំ ឈូក បានទទួលតំណែងជាលេខាតំបន់២៤ និងធ្វើពេទ្យរហូតដល់ចប់សង្គ្រាម ។ នៅឆ្នាំ១៩៧៦ ឈូក ត្រូវអង្គការចាប់ខ្លួនបញ្ជូនមកឃុំឃាំងនៅមន្ទីរស-២១ ។

ខាងក្រោមនេះ ជាសេចក្តីសង្ខេបប្រវត្តិសកម្មភាពរបស់ ឈូក តាមរយៈចម្លើយសារភាពរបស់ខ្លួន ដែលបានបន្សល់ទុកនៅមន្ទីរស-២១÷

**មុនរដ្ឋប្រហារ**

នៅឆ្នាំ១៩៤៩ ឈូក បានចូលបម្រើក្នុងចលនាឥស្សរៈយៀកមិញជាមួយនឹងមិត្តភក្តិពីរនាក់ទៀត គឺ ទុំ និង កាន តាមរយៈបងជីដូនមួយឈ្មោះ លី ។ ឈូក បាននិយាយថា ខ្លួនស្ម័គ្រចិត្តចូលចលនាឥស្សរៈ ដោយសារកើតក្តីទោមនស្សខឹងឈ្មោះប្រកែកនឹងក្មេងវត្តបង្កត់បាយ ។ ឈូក បានទទួលការចាត់តាំងឲ្យធ្វើជាក្រុមស៊ើបការណ៍ស្រុករមាសហែករហូតដល់ឆ្នាំ១៩៥០ ។ ពីឆ្នាំ១៩៥០ដល់ឆ្នាំ១៩៥៤ ឈូក ធ្វើពេទ្យនៅខេត្តកំពង់ចាម ។ រយៈពេលនោះ ឈូក ខំរៀនពេទ្យ រៀននិយាយនិងសរសេរភាសាវៀតណាម ព្រោះបុគ្គលិកទាំងអស់នៅក្នុងមន្ទីរពេទ្យសុទ្ធសឹងជាជនជាតិវៀតណាម ។ នៅក្នុងឆ្នាំ១៩៥២ ឈូក ត្រូវប្តូរទៅស្រុកមេមត់ ធ្វើជាអ្នកបកប្រែពេទ្យ និងជាស្មៀនឲ្យលេខាស្រុកមេមត់ដែលជាជនជាតិវៀតណាមឈ្មោះបាត់ដាំង ។ នៅមេមត់ ឈូក មានជំងឺគ្រុនចាញ់យ៉ាងធ្ងន់ស្ទើរតែបាត់បង់ជីវិត ។ មួយឆ្នាំក្រោយមកគឺក្នុងឆ្នាំ១៩៥៣ ឈូក ត្រូវបញ្ជូនមកធ្វើពេទ្យក្នុងកងឈ្លប ឃុំពាមជីលាំង ។ នៅចុងឆ្នាំដដែលនោះ ឈូក ត្រូវបញ្ជូនមកធ្វើពេទ្យនៅភូមិភាគបូព៌ាទិសសន្ទែ ។ មកដល់ពេទ្យនេះ ឈូក បានទទួលភារកិច្ចទៅកាប់ចម្ការដាំស្រូវវិញ ។ ឈូក ទោមនស្សនឹងវៀតណាមខ្លាំងណាស់ ព្រោះត្រូវវៀតណាមមើលងាយមើលថោកជារៀងរាល់ថ្ងៃ ។ ដល់ឆ្នាំ១៩៥៤ ឈូក ត្រូវប្តូរភារកិច្ចឲ្យមកធ្វើជាពេទ្យម្តងទៀត ។ នៅឆ្នាំ១៩៥៤ អង្គការបានប្រគល់ ឈូក ឲ្យទៅនៅខេត្តស្វាយរៀងតាមព្រំដែនកម្ពុជា-វៀតណាមជាមួយ យ៉ា (ណៃ សារ៉ាន់) លេខាភូមិភាគឦសានដោយធ្វើជាពេទ្យ នីរសានិងកងការពារ ។ ក្រៅពីនេះ ឈូក មាននាទីជាអ្នកនាំយកកាតទៅឲ្យកម្មាភិបាលដឹកនាំដែលបានធ្វើដំណើរទៅប្រទេសវៀតណាមបានចូលមកក្នុងប្រទេស (ស្រុកខ្មែរ) វិញ ។

ឆ្នាំ១៩៥៥ មុនពេលបោះឆ្នោតជាតិ ឈូក បានចូលមកទីក្រុងភ្នំពេញ ហើយត្រូវអង្គការចាត់ឲ្យទៅលីបាវស្រូវនៅគីឡូលេខ៦ អស់រយៈពេល៣ខែ ដើម្បីចិញ្ចឹមឈ្មោះមិត្ត(តា) កែវ ហែម និង មិត្ត(តា) យុត យុន ។ យុត យុន អតីតតំណាងរាស្ត្រក្រុមប្រជាជនប្រចាំស្រុកកោះជ័យ (ស្រុកព្រះស្តេច) ខេត្តព្រៃវែង ។ នៅក្រោយសន្និសីទទីក្រុង ហ្សឺណែវ យុត យុន បានទៅធ្វើជាស្មៀនឃុំប្រាសាទ ស្រុកពាមជរ ជាមួយប្អូនថ្លៃដែលជាមេឃុំ ។ បន្ទាប់ពីរដ្ឋប្រហារភ្លាម វៀតណាមបានចាត់តាំង យុត យុន ឲ្យធ្វើជាប្រធានរណសិរ្សប្រចាំអាគ្នេយ៍ទិស ។ ពេលនេះ ឈូក មានសតិអារម្មណ៍តូញត្អែរថា ហត់លំបាកនិងចង់ជួប យ៉ា ឲ្យជួយដោះស្រាយរកកន្លែងធ្វើការបានធូរស្រាលជាងមុនបន្តិច ។ អង្គការបានឲ្យ ឈូក ទៅរស់នៅជាមួយ កែវ សុវណ្ណ នៅផ្ទះរបស់តាហ៊ី ជាជាងធ្វើកង់នៅពេទ្យចិន ដើម្បីធ្វើជានីរសាទៅប្រទេសវៀតណាម ។ ឈូក សុំកង់ពី សុវណ្ណ មួយគ្រឿងដើម្បីជិះធ្វើការ ប៉ុន្តែ សុវណ្ណ មិនឲ្យ ។ ឈូក មានការអាក់អន់ស្រពន់ចិត្ត

យ៉ាងខ្លាំង ។ ដល់ពេលបោះឆ្នោតសកលឆ្នាំ១៩៥៥ អង្គការបានឲ្យ ឈូក ទៅនៅមន្ទីរកាសែតប្រជាជាតិ ដើម្បីធ្វើជានីរសានាំកាសែតទៅចែកនៅមូលដ្ឋានខេត្តស្វាយរៀង ។ ក្រោយពីបោះឆ្នោតរួច បងៗ(ថ្នាក់លើ, អ្នកដឹកនាំ) គេចខ្លួនអស់ ដោយសារខ្មាំង (ខាងរដ្ឋាភិបាល លន់ ណុល) រាតត្បាតខ្លាំង នៅសល់តែ ឈូក និងមិត្តពីរនាក់ទៀតប៉ុណ្ណោះ ។ ឈូក មានអារម្មណ៍តែលគោលមិនដឹងទៅណា ម្យ៉ាងភ័យខ្លាចខ្មាំងចាប់ដាក់គុក ម្យ៉ាងអន់ចិត្តអង្គការមិនគិតគូរដល់ខ្លួន ក៏ដើរស្រាយបដាក្រុម ប្រជាជន ហើយយកខ្សែលក់បានប្រាក់៥០រៀល ចែកគ្នាធ្វើសោហ៊ុយត្រឡប់ទៅស្រុកវិញ ។ ចាប់តាំងពីពេលនោះមក ឈូក សម្រេចចិត្តរស់នៅជាមួយឪពុកម្តាយនៅស្រុកកំណើត ។ នៅឆ្នាំ១៩៥៦ ឈូក បានរៀបការប្រពន្ធ ។

នៅក្នុងឆ្នាំចុង១៩៥៧ អង្គការបានភ្ជាប់ការទាក់ទងជាមួយ ឈូក ឡើងវិញ តាមរយៈ កែវ អាន ។ ឈូក បានធ្វើសកម្មភាពជាប់រហូតមក ធ្វើឲ្យរដ្ឋអំណាចតាមដានរកចាប់ខ្លួនគាត់ ។ ឈូក បានគេចខ្លួនរត់មកភ្នំពេញ ស្នាក់នៅផ្ទះបងនៅសង្កាត់ទឹកល្អក់ ប្រកបរបរលក់នំបុ័ង ។ បីខែក្រោយមកទៅធ្វើកម្មករទឹកក្រូចឈីហោ «ខ្លាប្រាំ» អស់រយៈពេលពីរខែ ក៏មានគំនិតផ្តើមដឹកនាំកម្មករប្រឆាំង មិនធ្វើការហួសម៉ោងនិងទាមទារប្រាក់កម្រៃបន្ថែម ។ ថៅកែហាងទឹកក្រូចខឹង ក៏ដេញ ឈូក ចេញពីការងារ ។ ឈូក ចេញទៅរកមន្ទីរកាសែតក្រុមប្រជាជននៅខាងត្បូងវត្តលង្កាដើម្បីជួបបងៗទាំងអស់នៅមន្ទីរកាសែត ។ បងៗក៏ទទួលស្គាល់ហើយយក ឈូក ទៅទុកនៅផ្ទះ ជូ ជេត ដែលជាលេខាភូមិភាគបស្ចិមឲ្យជួយសង់ផ្ទះ ។ សាងសង់ផ្ទះរួចរាល់ហើយ ឈូក ត្រូវបញ្ជូនឲ្យទៅនៅផ្ទះសមមិត្ត ឃ្លាំង នៅទួលគោក ដោយព្យាបាលរោគប្រពន្ធសមមិត្ត ឃ្លាំង និងធ្វើកម្មករសង់ផ្ទះថ្មឲ្យ ស៊ាន អាន ដើម្បីចិញ្ចឹមជីវិត ។ ក្រោយមកទៀត ស៊ាន អាន បានយក ឈូក ទៅធ្វើជាស្មៀននៅសាលាកម្ពុជបុត្រទួលគោក ជាមួយ ប៉ែន យុត ជាអគ្គានុរក្សសាលា ។ ក្រោយពេលដែល ឈូក ទៅធ្វើការនៅសាលាកម្ពុជបុត្រ ទួលគោក គាត់បានសង្កេតឃើញសកម្មភាពទាក់ទងរបស់ ប៉ែន យុត និង ស៊ីវ ហេង ក៏បានរាយការណ៍ជូនចាងហ្វាងសាលានិងសមមិត្ត យ៉ា ជាលេខាសាលាឲ្យបានជ្រាប ដើម្បីតាមដានសកម្មភាពអ្នកទាំងពីរនេះ ។ ចាងហ្វាងសាលាបានឃើញសកម្មភាពរបស់ យុត ដើរចោលសាលានិងយកប្រាក់សាលាដែលសិស្សបង់ថ្លៃរៀនទៅចាយវាយផ្តេសផ្តាសក៏សម្រេចបញ្ឈប់ ប៉ែន យុត ចេញពីសាលាកម្ពុជបុត្រទួលគោកនៅចុងឆ្នាំ១៩៦១ ហើយជ្រើសរើស ស៊ឹម ដឹងហាយ ជំនួសវិញ ។ រយៈកាលនេះ ឈូក ជាប់ខ្សែចាត់តាំងបក្សដោយមានសមមិត្ត យ៉ា ជាលេខា ។ ឈូក ធ្វើការឲ្យសាលាផងទទួលធ្វើសកម្មភាពបំផុសសិស្សធ្វើបាតុកម្មប្រឆាំងទូតអាមេរិកផង ។ ក្រៅពីនោះខិតខំរកប្រាក់កាសជួយចិញ្ចឹមប្អូនៗ ដែលបងៗយកទៅផ្ញើឲ្យរៀនសូត្រ ជួយដល់កម្មករ កាសែតក្រុមប្រជាជនជួយផ្គត់ផ្គង់សមមិត្ត ជ័យនិងកូន ដែលជាប់នៅក្នុងមន្ទីរឃុំឃាំង ។ ឆ្នាំ១៩៦៣ ខ្មាំងតាមដានខ្លាំងពេក ឈូក សម្រេចសុំអង្គការឈប់ធ្វើការនៅសាលាកម្ពុជបុត្រ មកធ្វើសកម្មភាពជាសម្ងាត់វិញ ។ ដល់ឆ្នាំ១៩៦៥ ឈូក ចេញទៅមូលដ្ឋានជនបទ ។ អង្គការបានប្រគល់សមមិត្តក្រុមប្រជាជននិងសមមិត្តក្រុមសមាគមសន្សំបុណ្យទឹកល្អក់ និងត្រាជូ និងក្រុមកំពង់ដែកំពង់សោម ដើម្បីឲ្យ ឈូក គ្រប់គ្រងដឹកនាំបំផុសសម្មភាព ។ រយៈកាលនេះ ឈូក នៅក្រោមការដឹកនាំផ្ទាល់ពីសមមិត្ត វន (វន វេត) ទទួលបន្ទុកជាប្រធានសេដ្ឋកិច្ចរដ្ឋ ។ ឆ្នាំ១៩៦៥ បក្សបានឲ្យ ឈូក ទៅនៅជនបទស្រុកព្រះស្តេចដើម្បីបង្កប់ខ្លួនធ្វើសកម្មភាពក្នុងនៅទីនោះ ។

## ក្រោយរដ្ឋប្រហារ

ក្រោយរដ្ឋប្រហារភ្លាម ឈូក បានទទួលការណែនាំឲ្យដើរឃោសនានៅស្រុករមាសហែក តំបន់២៣ បានរយៈ១៥ថ្ងៃ ទើបអង្គការប្រគល់អង្គភាពមួយកងអនុសេនាតូច មានអាវុធគ្រប់ដៃ ឲ្យមកនៅមូលដ្ឋានស្រុកព្រះស្តេចវិញ ដើម្បីចាត់តាំងរដ្ឋអំណាចនៅក្នុងស្រុក៥គឺ ពាមរ ពាមជរ ព្រះស្តេច ត្របែក និងស្រុកបាភ្នំ ។ ទន្ទឹមនឹងនេះ ស្ហួន ក៏បានរួមជាមួយទ័ពវៀតណាមវាយប្រហារទីតាំងខ្មាំងនៅអ្នកលឿង ត្របែក ពាមរ និងកំពង់សឹង ។ អង្គការភូមិភាគ២០៣ បូព៌ា បានប្រគល់ភារកិច្ចឲ្យ ឈូក ជ្រើសរើសកម្មាភិបាល ចាត់តាំងគណៈតំបន់២៥ជាបណ្តោះអាសន្នសម្រាប់ទៅប្រតិបត្តិការរួមជាមួយវៀតណាមនៅខេត្តកណ្តាល ។

ពេលនោះ ឈូក បានជ្រើសរើសមិត្ត សុខ ប៊ុតចំរើន ជាលេខាមិត្ត ហ៊ួត សេ ជាអនុ មិត្ត សុក ជាប្រធានយោធា ។ ក្រុមទាហានវៀតណាមដែលមាន ឡេង បាវ និង ហាយវៃ ជាមេ បានចាប់មិត្ត សុវណ្ណ ដែលចេញពីក្រុង ដាក់ក្នុងមន្ទីរឃុំឃាំង ប៉ុន្តែគណៈភូមិភាគ២០៣ បានបញ្ជាឲ្យដោះលែងវិញ ។ ក្រោយពីការដោះលែង មិត្ត សុវណ្ណ បានមកជួប ឈូក នៅភូមិអំពិលទោល (ឃុំព្រៃទទឹង) ស្រុកមេសាង ដើម្បីប្រជុំគណៈតំបន់២៥បណ្តោះអាសន្ន។ គណៈតំបន់ត្រឡប់ទៅវិញបានរយៈពេលពីរខែ ក៏មានទំនាស់រហូតដល់បាញ់សម្លាប់គ្នា ។ ប៊ុត ចំរើន រួមជាមួយ យួន បានបាញ់សម្លាប់ សម្បត្តិ និងរកចាប់ សុវណ្ណ ។ សុវណ្ណ បានគេចខ្លួនទៅខេត្តតាកែវ ។ នៅក្នុងតំបន់២៥មានភាពច្របូកច្របល់ ព្រោះទំនាស់រវាងវៀតណាមនិងខ្មែរមានសភាពកាន់តែខ្លាំងឡើង ។ អង្គការបានសម្រេចប្រគល់តំបន់២៥ឲ្យភូមិភាគពិសេសគ្រប់គ្រងផ្ទាល់វិញ ទើបសភាពការណ៍ប្រែត្រឡប់ជាស្ងប់ស្ងាត់វិញ ។

នៅក្នុងចម្លើយសារភាពបញ្ជាក់ថា ឈូក បានធ្វើជីវទស្សន៍ចំនួនពីរលើកក្នុងការដោះស្រាយពាក្យចោទប្រកាន់របស់មហាជនទាំងក្នុងទាំងក្រៅបក្សដែលវាយតម្លៃថា "លេខាតំបន់២៤ ជាស្តេចត្រាញ់" ហើយកិច្ចការទាំងអស់ដែល ឈូក បានធ្វើគឺគ្មានអង្គការបក្សថ្នាក់លើណាមួយក្តាប់បានទេ ។ ឈូក ក៏មិនដែលធ្វើតាមការណែនាំរបស់ថ្នាក់លើទៀតផង ។ ឈូក ត្រូវអង្គការបានស្នើឲ្យរាយការណ៍លម្អិត ទាំងការប្រព្រឹត្តដាក់ស្តែង ទាំងជីហរសិតអារម្មណ៍ នយោបាយចាត់តាំង តាំងពីដើមរហូតមក ។ ឈូក បានបកស្រាយជាលើកទីមួយដោយរៀបរាប់អំពីចំណុចល្អនិងចំណុចខ្វះខាតរបស់ខ្លួនជាផ្នែកៗ មានទាំងខាងជីហរសតិអារម្មណ៍ ជីហរនយោបាយចាត់តាំង តាំងពីដើមរហូតមកដល់ឆ្នាំ១៩៧៦ ។ ឈូក បានសារភាពអំពីខ្សែចាត់តាំងក្បត់ក្នុងភូមិភាគនិរតី ភូមិភាគឦសាន និងឧត្តរ រួមទាំងរៀបរាប់អំពីសកម្មភាពទាក់ទងជាមួយ យួន អំពីផែនការនៅកងពល១៧០ ទាក់ទងជាមួយ ចាន់ ចក្រី



ក្នុងការទទួលសេចក្ដីរាយការណ៍ ការណែនាំជំរុញការអនុវត្តន៍ផែនការនៅកងពល១៧០ រាយការណ៍បន្តទៅវៀតណាម ទទួលមតិណែនាំពីបក្សពលករវៀតណាមមកវិញនិងសកម្មភាពទាក់ទងជាមួយឈ្មោះមួយចំនួនទៀត ដូចជា សុខ ប៊ិតចំរើន, សុផាន ហៅ លី វ៉ាយ, សុជាតិ, ហាយអ៊ែល, កែវ ហែម, កែវ សុវណ្ណ, យុត ឃុន, លី ផែន, ម៉ែន សាន ហៅ យ៉ា និង សកម្មភាពទាក់ទងជាមួយវៀតណាមផង ។

### អំពីផែនការសម្លាប់មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា

ក្រោយរដ្ឋប្រហារ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សុខ ប៊ិតចំរើន បានរត់ទៅស្រុកមេសាង តំបន់២០ជាមួយមនុស្សដទៃទៀតមានមានឈ្មោះ គឹម ហុង, ដៃ, អួន, ស៊ឹម, សាភឿន, ឈឹម វ៉ាន់សាត ។ អ្នកទាំងអស់នេះនៅធ្វើការក្នុងស្រុកមេសាង (មិនមែននៅជាមួយ ឈូក ទេ) ។ រយៈកាលស្គាល់គ្នាកាលណោះគឺពេល ឈូក រត់ពីខាងត្បូងថ្នល់ទៅនៅស្រុកមេសាង គេចចេញពីការរាតត្បាតរបស់ទាហានធីវគី ។

នៅពាក់កណ្ដាលឆ្នាំ១៩៧៤ នៅមន្ទីររបស់ខ្លួននៅភូមិព្រៃប្រង់ សង្កាត់ស្ដី ស្រុកបាភ្នំ ឈូក បានទទួលសំបុត្រមួយច្បាប់ពី ឧត្ដមសេនីយ៍ ឌឿង ខែល ជាឧត្ដមសេនីយ៍យោធភូមិភាគពិសេសភ្នំពេញរបស់ លន់ ណុល តាមរយៈ សន ថន គណៈកម្មការពាណិជ្ជកម្មភូមិភាគបូព៌ាទិស ប្រចាំនៅដីក្រហម ។ ខ្លឹមសារនៅក្នុងសំបុត្រគឺសុំឲ្យ ឈូក រួមដៃ វាយយួនយៀកមិញ យៀកណាមខាងជើងឲ្យអស់ពីទឹកដីនិងឈានទៅរំដោះកម្ពុជាក្រោម ។ ប្រមាណជាដប់ថ្ងៃក្រោយពីទទួលបានសំបុត្រនេះ ឈូក បានឡើងទៅជួប សោភឹម នៅមន្ទីរសេនាធិការភូមិភាគដើម្បីឆ្លងផែនការវាយទីតាំងសាលាស្រុកពាមជរ និង អុងកូ ហើយប្រាប់ ភឹម ពីរឿងសំបុត្រ ។ បន្ទាប់ពី ភឹម អានសំបុត្រនោះរួចហើយ ភឹម បានបញ្ជាក់ប្រាប់ ឈូក ថា "នេះហើយខ្មាំងធ្វើសន្តិសម្ព័ន្ធ ត្រូវប្រុងប្រយ័ត្នយុទ្ធជន និងកម្មាភិបាលដែលចលនាទាហានខ្មាំងប្រយ័ត្នវាអូសទាញបាន" ។

ការទាក់ទងរាយការណ៍ពី ចក្រី មកកាន់ ឈូក អំពីផែនការវាយបក្សកុម្មុយនិស្តកម្ពុជានៅក្នុងក្រុងភ្នំពេញជាលើកទី១នៅក្នុងឆ្នាំ១៩៧៥ គឺក្រោយពេលដែល ចក្រី ទៅទទួលផែនការពី ឈូក ។ ផែនការនោះមិនសម្រេចទេ ដោយមូលហេតុក្នុងពេលបុណ្យខួបបក្សមានផែកឆែរម៉ត់ចត់ មិនឲ្យយកអាវុធគ្រប់គុនចូល និងដោយមូលហេតុផ្សេងទៀតដូចជាកម្លាំងរបស់ចក្រី នៅថ្មីពេក នៅខ្វាចញញើតញញើមមិនដាច់ខាត និង មិនស្គាល់មុខមេដឹកនាំបក្សច្បាស់លាស់ ។ ឈូក បានណែនាំជាវិធានការថ្មីដល់ ចក្រី ឲ្យត្រូវត្រៀមកម្លាំងឲ្យបានច្រើនដាក់ឲ្យគ្រប់ផ្លូវដោយប្រើរូបភាពយាមកាមពិសេស នៅមុខព្រួញដែលខ្លួនទទួលខុសត្រូវតាមផ្លូវធំសំខាន់ៗ ពិសេសផ្លូវវិមានឯករាជ្យ ។ ក្រុមទាំងនេះត្រូវបញ្ជាឲ្យឯករាជម្ចាស់ការ ជួបពេលណាបាញ់ពេលនោះ មិនបាច់បញ្ជា ។ ធ្វើយ៉ាងនេះមានប្រសិទ្ធភាពជាង ។ រៀបចំកម្លាំងកងពិសេសមួយវរសេនាតូចយ៉ាងតិច ហើយបង្ហាត់ក្បួនបាញ់កាំភ្លើងឲ្យត្រង់ពីចម្ងាយ ដើម្បីត្រៀមលក្ខណៈសម្បត្តិសម្រាប់វាយបុកនៅពេលណាជាកំណត់ និងពេលមានពិធីបុណ្យធំៗ ដូចជាបុណ្យឯករាជ្យនិងបុណ្យខួបបក្សនៅតាមផ្លូវ ។ ត្រូវខិតខំកសាងកម្លាំងនៅតាមអង្គភាពដទៃទៀតឲ្យបានជាបណ្ដើរៗដើម្បីបង្កើនដានមុខព្រួញសំខាន់របស់ខ្លួន ។

នៅខែ១០ ឆ្នាំ១៩៧៥ ក្រោយទទួលផែនការហើយ ចក្រី បានទៅរាយការណ៍ឲ្យ ឈូក ម្ដងទៀត "អំពីបញ្ហាជួបការលំបាកច្រើន ដោយអង្គការបានដកកម្លាំងកងពល១៧០ ចេញពីភ្នំពេញអស់ជាច្រើន ។ អាវុធអង្គភាពក៏អង្គការដកមួយចំនួនទុកក្នុងឃ្លាំង ។ ការរៀបចំកម្លាំងកងពិសេស ជួបការលំបាកដោយសារជ្រើសរើសមនុស្សស្មោះត្រង់មិនបានច្រើន ។

ការកសាងកម្លាំងអង្គភាពដទៃក៏មិនបាន ពីព្រោះអង្គភាពទាំងនោះតែងតែទំនាស់គ្នា ដូចជាកងខាងឧត្ដរ និរតី កង១២ និងកង១១ ។ល ។ ពេលនេះបើវាយបុកដណ្ដើមយកឃោសនាការក៏ជាការប្រថុយប្រថាន ព្រោះកម្លាំងមានតែជាង៩០នាក់ប៉ុណ្ណោះ" ។ ឈូក បានចាត់វិធានការណែនាំថ្មីចំពោះ ចក្រី សម្រាប់ខែមករា ឆ្នាំ១៩៧៦ ដោយឲ្យរៀបចំចាត់តាំងកងស៊ើបការណ៍ "តាមដានអង្គការឲ្យជាប់ទាំងមន្ទីរធ្វើការនិងកន្លែងរស់នៅឲ្យប្រាកដ ។ ត្រូវតែដាច់ខាតរៀបចំកម្លាំងបង្កប់នៅតាមអង្គភាពដទៃឲ្យបានដើម្បី

បង្កើនផែនទិសសកម្មភាពរបស់ខ្លួន ។ ត្រូវរកមនុស្សដែលធ្លាប់ស្គាល់មិនបាច់ចំណាំលេខឡានទេ ព្រោះឡានកំណត់មិនបាន ។ ត្រូវខិតខំកសាងកងពិសេសតទៅទៀត កុំអាលអស់សង្ឃឹមហើយ ប្រើប្រាស់វាដើម្បីលត់ដំបណ្តើរៗគឺឲ្យវាធ្វើឲ្យចលាចលលួចបាញ់ បោះគ្រាប់ណោះគ្រាប់ណោះ តាមមុខព្រួញអង្គភាពដទៃដើម្បីឲ្យគេចាប់អារម្មណ៍ដល់អង្គភាពផ្សេងទៀតក្រៅពីកង១៧០លួចដុតផ្ទះបំផ្លាញឃ្លាំង ។ល ។»

ក្រោយពីបានទទួលសេចក្តីរាយការណ៍ពី ចក្រី ក្នុងឆ្នាំ ១៩៧៥ ក្រោយបុណ្យឯករាជប្រហែលមួយសប្តាហ៍ ឈូក បានទៅជួប បៃ ម៉ាប់ ដែលជាគណៈទាក់ទងរបស់វៀតណាម ខេត្តដុងថាប ដើម្បីរាយការណ៍ពីសភាពការណ៍ដែលមិនបានសម្រេចក្នុងឱកាសបុណ្យឯករាជ្យកន្លងមក ។ បៃ ម៉ាប់ បានឲ្យមតិចាត់វិធានការជាបន្តបន្ទាប់ រហូតទីចុងបំផុត ដោយឲ្យយោបល់ថាមិនហ៊ានសម្រេចបញ្ហាធំៗទេ គឺគ្រាន់តែជាអ្នកនាំពាក្យជូនអង្គការខ្មែរតែប៉ុណ្ណោះ ។ បៃ ម៉ាប់ បាននិយាយថា «អង្គការខាងលើខ្មែរនិងវៀតណាម សម្រេចយ៉ាងម៉េច ខ្ញុំចាំតែអនុវត្តដូចអស់មិត្តដែរ តែសុំមិត្តកុំភ្លេច បើមិនស្រួល ម្ចាស់ការបណ្តើរៗឲ្យតែមានស្បៀង កុំដេកចាំគេចង ហើយចាំបម្រះក្រោយមិនស្រួលទេ ត្រូវស្វ័យប្រវត្តិខ្លះទៅ ។ វៀតណាមមិនចោលទេ នៅតែចាំជួយដូចកាលឆ្នាំ១៩៧០អ៊ីចឹង» ។

ឈូក សរសេរសំបុត្រមួយច្បាប់ដោយឡែក ដោយមានរាយការណ៍ពីសភាពការណ៍ជាក់ស្តែងជូន កែវ មាស ជ្រាប និងដោះស្រាយស្ថានការណ៍ ដើម្បីសំណូមពរវាយដោយអាវុធ ។

នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៦ ឈូក ត្រូវអង្គការចាប់ខ្លួន ហើយត្រូវបានសួរចម្លើយដោយឈ្មោះ ប៉ុន នៅមន្ទីរ ស-២១ ចំនួន៣២លើក គឺចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៧៦ រហូតដល់ថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៧៦ ។ នៅក្នុងចម្លើយសារភាពរបស់ ឈូក ដែលមានចំនួន៩៧០ទំព័រ មានសភាពដូចជាមិនទាន់ចប់ស្រួលបួល ប៉ុន្តែត្រូវបានបញ្ជូនឲ្យ ឌុច ត្រួតពិនិត្យ បន្ទាប់មកបញ្ជូនទៅអង្គការលើ ។ ចំណារខ្លះៗក្នុងចំណោមចំណារជាច្រើនរបស់ ឌុច បានសរសេរថា÷ «ចម្លើយនេះមានលក្ខណៈជាគោល ខ្វះខាតត្រង់មិនទាន់ល្អិតមិនទាន់ជាក់ស្តែង ។ ២០-៩-៧៦, ឌុច» ។ «២៨-៩-៧៦, រាយការណ៍ច្បាប់ដើមទាំងអស់ ជូនបង៦២ ។ សូមជូនបងផ្ទាល់ជាពត៌មាន ។ ឌុច, ២៦-៩-៧៦» ។ «ព្រឹក ២៩-៩-៧៦ បានរាយការណ៍ជូនបង៦២មួយច្បាប់បានទាំងរាយការណ៍អំពីវិធានការចំពោះមុខ ។ ២៩-៩-៧៦, ឌុច» ។ «សម្រេចមិនទាន់រាយការណ៍ជាបណ្តោះអាសន្ន ព្រោះវាបេះកុងកេវទៅរកបងអក្សរ ភ ។ ឌុច, ២៩-៩-៧៦ ។ ច្បាប់ដើមបានចូលសំណុំរឿង» ។ «បងឈូក ជាទីរឭក, ដែលហៅថាស្រឡះតាមសំណូមពរ យើងខ្ញុំគឺនិយាយអំពីមនុស្សណាជាមួយបង គោងសរសេរតែអំពីមនុស្សនោះជាមួយបង ។ អ្នកដទៃទៀតអាចមានឈ្មោះដែរតែមានឈ្មោះក្នុងឋានៈគេជាមនុស្សត្រឹមត្រូវ ឧទាហរណ៍ដូចបងធ្លាប់និយាយថា បង និង បងយ៉ាគេចខ្លាចបងទុំពួ ។ អ្នកដទៃទៀតដែលត្រូវតែមានឈ្មោះ ដោយចាំបាច់គឺនិរសាជាវៀតណាមក្តី ជាខ្មែរក្តី ។ ក្រោយៗទៅទៀតក៏យើងធ្វើការជាមួយគ្នាអំពីមនុស្សដទៃទៀតតាមគោលការណ៍នេះ ។ ធ្វើការយ៉ាងនេះទើបហៅថាស្រឡះ ។ ដោយរឭក! ៣០-៩-៧៦, ឌុច ។ បានទទួល, ៣០-៩-៧៦ ម៉ែន» ។

**សើ សាយ្យាណា**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org*

# កំណត់ហេតុនៃការប្រជុំសមមិត្តតាល់ កងពល២៩០និងកងពល១៧០

**សមមិត្ត តាល់**

១) សភាពការណ៍ខ្មាំងក្នុងអង្គភាព មិនទាន់មានបញ្ហាប្លែកទេ។ តែនៅអ្នកលឿងត្រើយខាងលិច ថ្ងៃ១២-៩ មានមនុស្សម្នាក់មកអើតអើមលួចអង្ករបានមួយថៅ បងប្អូនចាប់ឃុំឃាំង។ យប់ជ្រៅវាសុំបត់ជើង ពេលបណ្តើរ វារត់លោតទំលាក់ទឹកមេកុង។ បងប្អូនបាញ់សម្លាប់ឥតបានសួរចម្លើយអីទេ។

២) ចុងខែ ៧-៩ យុទ្ធជនឈ្មោះ ប៊ិន សឿន បានរត់ទៅស្រុកកញ្ច្រៀច ពួនសំងំផ្ទះនារីម្នាក់ដែលប្តីត្រូវអង្គការចាប់។ ឥឡូវយកពីមូលដ្ឋានវិញហើយ។

៣) ឈ្មោះ ជុំ កម្មាភិបាលអនុសេនាធំ ចេញសេរី ដើរឥតច្បាប់រហូតស្រុកពាមជរអស់រយៈ៣-៤ថ្ងៃ។ ឈ្មោះនេះធ្លាប់ទាក់ទងជាមួយចក្រី។

**មតិបង៨៩:**

សុំជម្រាបសភាពការណ៍តំបន់២៤ ដើម្បីសមមិត្តម្ចាស់ការគ្រប់គ្រងកងពល២៩០។ ក្រោយយើងចាប់ចក្រី វាឆ្លើយដាក់ពួកតំបន់២៤មួយចំនួនដែលទាក់ទងវៀតណាម-សូវៀត ដើម្បីវាយបដិវត្តយើងថ្ងៃ៣០-៩-៧៦នេះ។ ឥឡូវ ឈូក លេខាតំបន់និងបក្សពួកត្រូវយើងចាប់ វាសារភាពហើយ ត្រឹមត្រូវដូច អាចក្រី ឆ្លើយមែន។

គួរពិនិត្យកងពល២៩០ ខ្សែស៊ីងស្តូតនិងខ្សែ២៤។ ឈ្មោះត្រូវយកគឺៈ ១)ជុំ ចាន់ ២)ខៀវ ម៉ា ៣)ជុំ និង ៤)យស់ យ៉ន បងរបស់ យស់ សុផុន ចោរលួចគោ។

**ប្រជុំបន្ទះ បង៨១ បើកការប្រជុំ**

ពិនិត្យឈ្មោះត្រូវយកពីកងពល២៩០ៈ ពួកខ្សែតំបន់២៤និងខ្សែពួកចក្រី។

អង្គប្រជុំសុំឯកសារយល់ស្របយកឈ្មោះ៤ខាងលើរបស់កងពល២៩០។

**សមមិត្ត ឌុច មានមតិៈ**

ក្រោយប្រជុំ សមមិត្ត សុខ និង តាត កងពល១៧០ បានឯកភាពគ្នា ត្រូវស្នើយកឈ្មោះ២៩នាក់ទៀតគឺ÷

១)ហួង ប៉េងឡេង វាយអង្គលីលេខ ២)ថាច់ ស៊ាន ភ័ស្តុកា ៣)ថោង សាដៃ ៤)សូ សុន ៥)ខឹម យ៉ាន់ ៦)ងួន ទូច ៧)នៅ ផុន ៨)ចៀវ សាយ ៩)យោក សាំង ១០)អែម សុត ១១)ហួត សំអែល ១២)ប៉ែន ពេញ ១៣)គ្រឿន ១៤)អ៊ុង សុន ១៥)សុខ ខៃ ១៦)កែន ង៉ុន ១៧)ទិត សាមិត ១៨)សាម៉េត ១៩)គង់ សឿន ២០)កែ អឿន ២១)ឡុង សារ៉េត ២២)កែវ សុខ ២៣)ចាន់ អួន ២៤)កង សារ៉េត ២៥)តី សុជាត ២៦)សុខ ពៅ ២៧)ស៊ិន សុង ២៨)ពត់ សុខន និង ២៩)ប្រាក់ ដល្លី។

ឈ្មោះស្នើនេះ គឺស-២១និងកងពល១៧០ ប្រជុំគ្នាសម្រេចក្រៅពី១១នាក់ដែលប្រជុំសម្រេចពីថ្ងៃ១៥-៩។

១) ឈរលើហេតុផលបញ្ជាក់របស់ស-២១ និងកងពលឃើញសកម្មភាពដាក់ស្តែងជាបន្តបន្ទាប់ ព្រមទាំងឈរលើគោលការណ៍អង្គការកំណត់ ពួកខ្សែស្រឡាយអាចក្រីត្រូវយកអង្គប្រជុំយល់ស្របសម្រេចយកឈ្មោះទាំង២៩នាក់នេះទៀត។

២) សម្រេចយកនារី២នាក់ទៀត គឺប្រពន្ធនិងក្មួយរបស់អាចក្រី។

**វិធីដំណើរការៈ**

១) ត្រូវធ្វើតាមពិសោធរបស់យើងដែលបានធ្លាប់យកពួកនេះជាបន្តបន្ទាប់ធ្វើម៉េចកុំឲ្យអង្គការជ្រួលច្របល់ ក្តាប់អង្គភាពឲ្យជាប់ក្នុងដៃនិងរក្សាការសម្ងាត់ឲ្យបានល្អ។ ដាក់ស្តែងពិគ្រោះពិភាក្សាវិធីដំណើរការជាមួយស-២១ ដើម្បីយកនិងចាត់តាំងគ្រប់គ្រងអង្គភាពក្នុងពេលដកពួកវាចេញ។

២) កងពលត្រូវមានមនុស្សក្នុងដៃ ក្តាប់ឃ្លាំង ក្តាប់អាវុធឲ្យជាប់ ប្រយ័ត្នខ្មាំងដណ្តើមយកអាវុធពីយើងបាន។

**វិធីដាក់ស្តែងៈ**

១) ខាងកងពល២៩០ៈ ត្រូវស-២១ និងកងពលសហការគ្នា ចាប់យកពីកន្លែងដាក់ឡានតែម្តង។

២) ខាងកងពល១៧០ៈ ត្រូវស-២១និងកងពលពិគ្រោះគ្នា យកវិធានការល្អិតដាក់ស្តែងដើម្បីយកពួកទាំង៤០នាក់។ ឯនារី២នាក់ចាំគិតបន្តគ្នា។

ប្រជុំចប់ម៉ោង២២និង១៥នាទី។

(ឯកសារN000១៨៤៧)

# ជីវិត ខៀវ ប៉ុណ្ណារី



ខៀវ ប៉ុណ្ណារី (១៩៧៣)

ខៀវ ប៉ុណ្ណារី បានទទួលមរណភាពនៅថ្ងៃអង្គារទី១ ខែកក្កដា ឆ្នាំ២០០៣ ដោយជំងឺចាស់ជរាក្នុងអាយុ៨៣ឆ្នាំ ។ ខៀវ ប៉ុណ្ណារី បានស្គាល់និងទាក់ទង ប៉ុល ពត ក្នុងសម័យប្រជុំផ្សេងៗក្នុងមជ្ឈដ្ឋានម៉ាក់សុីសនិយម ហើយបានរៀបការជាមួយ ប៉ុល ពត នៅឆ្នាំ១៩៥៦ ។ ខៀវ ប៉ុណ្ណារី បានទទួលការថែទាំពីក្រុមគ្រួសារ អៀង សារី តាំងពីឆ្នាំ១៩៧៩មកម្ល៉េះ ។ ក្រុមគ្រួសាររបស់ អៀង សារី មានការអាក់អន់ចិត្តយ៉ាងខ្លាំងចំពោះ ប៉ុល ពត ដែលបោះបង់ចោល ខៀវ ប៉ុណ្ណារី ចោលក្រោយពីគាត់មានជំងឺ ហើយទៅរៀបការជាមួយស្ត្រីថ្មីទៀត ។

ខៀវ ប៉ុណ្ណារី កើតនៅខេត្តបាត់ដំបងដែលមានឪពុកជាចៅក្រម ។ ខៀវ ប៉ុណ្ណារី មានប្អូនស្រីម្នាក់ឈ្មោះ អៀង ធីរិទ្ធ មានឋានៈជារដ្ឋមន្ត្រីទទួលបន្ទុកក្រសួងសង្គមកិច្ចនិងសុខាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យ និងត្រូវជាប្រពន្ធរបស់ អៀង សារី ។

នៅខែកក្កដា ឆ្នាំ១៩៦១ ខៀវ ប៉ុណ្ណារី បានបង្កើតអង្គការស្ត្រីកុម្មុយនិស្តសម្ងាត់ ហើយបានធ្វើសកម្មភាពយ៉ាងសកម្មដោយលួចលាក់ ។ ឆ្នាំ១៩៦៦ ខៀវ ប៉ុណ្ណារី បានលះបង់ការងារជាសាស្ត្រាចារ្យនិងផ្ទះសម្បែងភៀសខ្លួនចូលព្រៃដើម្បីរួមចំណែកក្នុងការងារបដិវត្តន៍ជាមួយ ប៉ុល ពត ។ ទោះបីនៅក្នុងព្រៃក៏ដោយ ខៀវ ប៉ុណ្ណារី នៅតែបន្តសរសេរអត្ថបទឃោសនាអូសទាញប្រជាជន ហើយបានផ្សព្វផ្សាយដោយលួចលាក់នៅតាមជនបទនានា ។ រោងពុម្ពមួយចំនួនត្រូវបានបង្កើតនៅកណ្តាលព្រៃជ្រៅក្នុងខេត្តតាកែវនិងខេត្តកំពត ហើយត្រូវបានផ្លាស់ប្តូរទីតាំងជាញឹកញាប់ដើម្បីគេចវេះពីការតាមដានពីអាជ្ញាធរ ។ កម្មាភិបាលខ្មែរក្រហមម្នាក់ឈ្មោះ អ៊ឹម ណេន ហៅ លី បានឲ្យដឹងថាឆ្នាំ១៩៦៥-៦៧ ខៀវ ប៉ុណ្ណារី បានធ្វើសកម្មភាពយ៉ាងខ្លាំងក្នុងការចូលរួមចលនាតស៊ូក្នុងព្រៃជាមួយថ្នាក់ដឹកនាំកំពូលនិងចូលរួមស្ទើរតែគ្រប់អង្គសិក្ខាសាលារបស់កម្មាភិបាលខ្មែរក្រហមដែលមកពីគ្រប់តំបន់និងភូមិភាគ ។

នៅឆ្នាំ១៩៧១ ខៀវ ប៉ុណ្ណារី បានទទួលបន្ទុកភារកិច្ចមួយផ្សេងទៀត គឺប្រធាននារីនិងកុមារប្រចាំការនៅភូមិភាគឧត្តរ ។ ក្នុងចំណោមនោះមានគណៈនារីក្រោមបង្គាប់របស់ ខៀវ ប៉ុណ្ណារី ជាច្រើននាក់ដូចជា ឡេង ស៊ឹមហាក់ ហៅ សី ជាប្រពន្ធរបស់ ទីវ អុល ហៅ ពេញ គ្រប់គ្រងមន្ទីរកុមារ(ឆ្នាំ១៩៧៥ ក្រោយរំដោះ ឡេង ស៊ឹមហាក់ ក្លាយជាប្រធានមន្ទីរ១៧មេសា សព្វថ្ងៃពេទ្យរុស្ស៊ី ប៉ុន្តែត្រូវអង្គការចាប់មកដាក់គុកទួលស្លែងនៅឆ្នាំ១៩៧៦) ។ វ៉ាន់ឡាន ហៅ សាយ និង ហៅ យាត ជាប្រពន្ធរបស់ ហ៊ូ នឹម មានតួនាទីជាអនុប្រធានកុមារ ។ ទូច ជាប្រពន្ធ តូច ភឿន ជាសមាជិកមន្ទីរកុមារ ។ មិត្ត គី ប្រពន្ធរបស់ ហ៊ូ យន់ ជាសមាជិកមន្ទីរ ។

ខៀវ ប៉ុណ្ណារី បានបង្កើនចលនាយ៉ាងខ្លាំង ក្នុងការអូសទាញនិងប្រមូលនារីនៅតាមតំបន់នានាបានយ៉ាងច្រើនដើម្បីចូលរួមក្នុងបដិវត្តន៍ ។ ក្នុងនោះភូមិភាគនិរតីគឺជាភូមិភាគមួយឈានមុខ ដែលមាននារីចូលរួមក្នុងចលនាបដិវត្តន៍យ៉ាងកុះករ ។ ក្នុងឆ្នាំ១៩៧៣ ខៀវ ប៉ុណ្ណារី បានក្លាយជាលេខាបក្សប្រចាំនៅខេត្តកំពង់ធំ ។

នៅឆ្នាំ១៩៧៦ ខៀវ ប៉ុណ្ណារី ត្រូវបានតែងតាំងជាប្រធានសមាគមស្ត្រីកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែគាត់ហាក់ដូចជាលែងបង្ហាញខ្លួនជាសាធារណៈជាមួយថ្នាក់ដឹកនាំកំពូលៗដទៃទៀត ហើយពុំឃើញមានសកម្មភាពអ្វីគួរឲ្យកត់សម្គាល់ដូចជា អៀង ធីរិទ្ធ ប្អូនស្រីរបស់គាត់ឡើយ ។ ទាំងសកម្មភាពនិងការងាររបស់គាត់ហាក់ដូចជាស្ថិតក្នុងសភាពលាក់លៀមនិងបំបិទបោល ។ មានមតិសាធារណជនសន្និដ្ឋានថា ខៀវ ប៉ុណ្ណារី មានរោគសរសៃប្រសាទ ហើយក្លាយខ្លួនទៅជនពិការ ។ ដំណឹងនេះហាក់បីដូចជាស្របនឹងព្រឹត្តិការណ៍មួយដែលកើតមាននៅចុងឆ្នាំ១៩៧៦ គឺសម្ព័ន្ធស្ត្រីសង្គមនិយមវៀតណាមបានអញ្ជើញសមាគមស្ត្រីកម្ពុជាប្រជាធិបតេយ្យទៅធ្វើទស្សនកិច្ចនៅប្រទេសវៀតណាម ។ ស្ត្រីខ្មែរ៥នាក់ត្រូវបានចាត់តាំងឲ្យទៅធ្វើទស្សនកិច្ចនៅសាធារណរដ្ឋសង្គមនិយមវៀតណាម ចាប់ពីថ្ងៃទី២៨ ខែសីហា ដល់ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ១៩៧៦ ប៉ុន្តែគ្មានវត្តមាន ខៀវ ប៉ុណ្ណារី ដែលជាប្រធានសមាគមឡើយ ។ ផ្ទុយទៅវិញបែរជាមានវត្តមាន ស៊ឹម ឡេងហាក់ ហៅ សី ប្រធានមន្ទីរពេទ្យ១៧ មេសា ជាអ្នកដឹកនាំគណៈប្រតិភូជំនួសវិញ ។

ការបាត់ខ្លួនរបស់ ខៀវ ប៉ុណ្ណារី ធ្វើឲ្យកើតមានការសង្ស័យជាច្រើន ហើយមានទស្សនៈខុសៗគ្នា ។ សូម្បីតែ ខៀវ សំផន ដែលជាអតីតសមមិត្តរួមការងារ ក៏បាននិយាយដែរថា គាត់មិនបានឃើញ ខៀវ ប៉ុណ្ណារី អស់រយៈពេលជាង២០ឆ្នាំមកហើយ ។

នៅពេលមួយនោះ ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ខៀវ ប៉ុណ្ណារី បានទៅព្យាបាលជំងឺសរសៃប្រសាទនៅប្រទេសចិន ប៉ុន្តែរបាយការណ៍ចេញមកថា ជំងឺរបស់គាត់ មិនអាចព្យាបាលបាន ។ ខៀវ ប៉ុណ្ណារី ក៏វិលត្រឡប់មកប្រទេសកម្ពុជាវិញ ។ នៅចន្លោះឆ្នាំ១៩៧៩-១៩៨០ មានការសង្ស័យមួយបានលេចឮថា ខៀវ ប៉ុណ្ណារី ត្រូវបានប៉ុនប៉ងធ្វើឃាតដោយដាក់ថ្នាំបំពុល ហើយបញ្ជូនទៅសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យក្នុងប្រទេសថៃ ។ ដំណឹងដែលអាចចាត់ទុកជាបានការគឺសេចក្តីប្រកាសរបស់ អៀង សារី នៅពេលដែលគាត់ចុះចូលជាមួយរាជរដ្ឋាភិបាល ខៀវ ប៉ុណ្ណារី នៅរស់នៅឡើយទេ ហើយក្លាយជាជនវិកលចរិតនិងពិការអង្គុយលើរទេះរុញក្រោមការបីបាច់ពីក្រុមគ្រួសាររបស់ខ្លួនគាត់ ។

ប៉ុល ពត និង ខៀវ ប៉ុណ្ណារី គ្មានកូនទេ ហើយបានលែងលះគ្នានៅឆ្នាំ១៩៨២ ។

នៅឆ្នាំ១៩៨២ ប៉ុល ពត បានរៀបការម្តងទៀត ។ នៅពេលមានអាយុ៦៨ឆ្នាំ ប៉ុល ពត បានរៀបការជាលើកទី៣ ជាមួយស្ត្រីម្នាក់ទៀតឈ្មោះ «នាងស» ដែលមានអាយុ៤០ឆ្នាំ បង្កើតបានកូនស្រីម្នាក់ ។

ខៀវ ប៉ុណ្ណារី ដែលបានតស៊ូរស់ជាមួយនឹងជំងឺសរសៃប្រសាទរបស់គាត់អស់រយៈពេលជាងពីរទសវត្សរ៍ និងដោយសារភាពចាស់ជរានិងជំងឺមហារីកទន្ទ្រានអស់រយៈពេលយូរណាស់មកហើយនោះ បានទទួលមរណភាពនៅក្រុងប៉ៃលិន ភាគពាយ័ព្យនៃប្រទេសកម្ពុជា ។

ពិធីបូជាសពរបស់ ខៀវ ប៉ុណ្ណារី បានប្រព្រឹត្តទៅនៅព្រឹកថ្ងៃព្រហស្បតិ៍ ទី៣ ខែកក្កដា ឆ្នាំ២០០៣ ក្នុងវត្តកោងកាងកណ្តាលទីក្រុងប៉ៃលិនដោយមានមនុស្សប្រមាណ៥០០នាក់ចូលរួមដែលមានព្រះសង្ឃ កងកម្លាំងប្រដាប់អាវុធអតីតមេដឹកនាំខ្មែរក្រហម ក្នុងនោះមាន អៀង សារី ដែលត្រូវជាប្អូនថ្លៃ, នួន ជា និង ខៀវ សំផន ប្រជាជននិងសិស្សសាលា ។ ភាគច្រើនប្រជាជនដែលចូលរួមនោះ គឺជាអ្នករស់នៅប៉ៃលិន ។ នៅក្នុងពិធីបូជាសពនេះដែរ ខៀវ ធីរិទ្ធ បានឡើងអានវិយោគកថាបញ្ជាក់ពីប្រវត្តិតស៊ូរបស់បងស្រីខ្លួន ។

**វ៉ែអម សុខឃីម**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

**រៀបចំនិងចងក្រងដោយៈ យិន នាន**

**(តពីលេខមុន)**

| លរ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ៧៦៦ | ស៊ុំម ឆន | មេក្រុម | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៦៧ | នួន គន ហៅ សារឿន | យុទ្ធជន | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៦៨ | គង់ អាន | កងរយ | កងពលបូព៌ា | ?? | ២៩-៧-៧៦ |
| ៧៦៩ | អ៊ូច ចាន់ថុល | អនុសេនាតូច | កងពល១៦៤ | ?? | ២៩-៧-៧៦ |
| ៧៧០ | សួ សុខុម | អនុក្រុម | កងពល១៦៤ | ?? | ២៩-៧-៧៦ |
| ៧៧១ | យឹម ឈឺន | យុទ្ធជន | យានដ្ឋានយ-១ | ?? | ២៩-៧-៧៦ |
| ៧៧២ | ដូ ឈុន | យុទ្ធជន | ស២១-យ | ?? | ២៩-៧-៧៦ |
| ៧៧៣ | ហ៊ុន គឹម | អនុក្រុម | ស២១-យ | ?? | ២៩-៧-៧៦ |
| ៧៧៤ | សួន ខន | កងរយ | ស២១-យ | ?? | ២៩-៧-៧៦ |
| ៧៧៥ | បុង សុន | កងវរសេនាតូច | ស២១-យ | ?? | ២៩-៧-៧៦ |
| ៧៧៦ | ពេជ សាញ់ | កងរយ | ស២១-យ | ?? | ២៩-៧-៧៦ |
| ៧៧៧ | ម៉ែន ហ៊ាង | អនុកងហា | ស២១-យ | ?? | ២៩-៧-៧៦ |
| ៧៧៨ | ថាវ សឿន ហោ ម៉ង | កងវរសេនាតូច | កងពល៥០២ | ?? | ២៩-៧-៧៦ |
| ៧៧៩ | ស្រី ប៉េង | បញ្ញោការកងរយ | ស២១-យ | ?? | ២៩-៧-៧៦ |
| ៧៨០ | ចាន់ សាវ៉ាត | ផ្នែកសួរ | ស២១-យ | ?? | ២៩-៧-៧៦ |
| ៧៨១ | សេង ជាតិ | ស្នងការកងវរសេនាធំ | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៨២ | សួ សុផាន | បញ្ញោការកងពល១៧០ | កងពល១៧០ | ?? | ២៩-៧-៧៦ |
| ៧៨៣ | ប៊ុន សានី | ប្រធានចម្ការនៅស្ទឹង | ភូមិភាគបូព៌ា | ?? | ២៩-៧-៧៦ |
| ៧៨៤ | នង សាវ៉ាន | មេក្រុម | ទូរពុម្ព | ២៩-៨-៧៦ | ១៦-៩-៧៦ |
| ៧៨៥ | ឈន ឈិន ហៅ រេន | ស្នងកងហា | ទូរពុម្ព | ២៩-៨-៧៦ | ១៦-៩-៧៦ |
| ៧៨៦ | ដេង យ៉ាន | អនុកងហា | ទូរពុម្ព | ២៩-៨-៧៦ | ១៦-៩-៧៦ |
| ៧៨៧ | ណែម ឈឿន | មេក្រុម | កងពល៥០២ | ៣១-៨-៧៦ | ១៦-៩-៧៦ |
| ៧៨៨ | សួ សួន | អនុក្រុម | កងពល១៧០ | ៣-៩-៧៦ | ១៦-៩-៧៦ |
| ៧៨៩ | ព្រុំ ដូង | យុទ្ធជន | កងពល១៧០ | ៤-៩-៧៦ | ១៦-៩-៧៦ |
| ៧៩០ | ចក់ ហុន | ប្រធានកងហា | កងពល១៧០ | ៣-៩-៧៦ | ១៦-៩-៧៦ |
| ៧៩១ | សៅ ឃឹន ហៅ សាវុធ | ពេទ្យកងរយ | កងពល១៧០ | ៣-៩-៧៦ | ១៦-៩-៧៦ |
| ៧៩២ | ប៉ាល់ សំបូរ | អនុកងហា | កងពល១៧០ | ៣-៩-៧៦ | ១៦-៩-៧៦ |
| ៧៩២ | ប៉ាល់ សំបូរ | អនុកងហា | កងពល១៧០ | ៣-៩-៧៦ | ១៦-៩-៧៦ |

| | | | | | |
|---|---|---|---|---|---|
| ៧៩៣ | ស៊ូ ថៃវ៉ា | មេពួក | កងពល១៧០ | ៦-៩-៧៦ | ១៦-៩-៧៦ |
| ៧៩៤ | យូ ដុនអេង | ប្រធានកងវរយ | កងពល១៧០ | ៦-៩-៧៦ | ១៦-៩-៧៦ |
| ៧៩៥ | អ៊ឹម សាវ៉ន | យុទ្ធជន | កងពល១៧០ | ៦-៩-៧៦ | ១៦-៩-៧៦ |
| ៧៩៦ | ឈុំ ឈឿន | អនុក្រុម | កងពល១៧០ | ៦-៩-៧៦ | ១៦-៩-៧៦ |
| ៧៩៧ | ងួន ឈាងគីម | មេក្រុមជួសជុល | កងពល១៧០ | ៦-៩-៧៦ | ១៦-៩-៧៦ |
| ៧៩៨ | ញ៉ែម សំបូរ | មេពួក | កងពល១៧០ | ៦-៩-៧៦ | ១៦-៩-៧៦ |
| ៧៩៩ | ដាប ឡាំង | យុទ្ធជនដឹដែក | កងពល១៧០ | ៦-៩-៧៦ | ១៦-៩-៧៦ |
| ៨០០ | ឆុង ឆេង ហៅ ឆេន | កងវរយ | កងពល១៧០ | ១៣-៩-៧៦ | ១៦-៩-៧៦ |
| ៨០១ | សៅ លាង | ជាងកាត់សក់ | ស២១-យ | ៤-៧-៧៦ | ១៦-៩-៧៦ |
| ៨០២ | សុក អាន | យុទ្ធជន | កងពល៧០៣ | ២៧-៧-៧៦ | ១៦-៩-៧៦ |
| ៨០៣ | យុង ម៉ៅ | កងវរយ | កងពល៧០៣ | ៣១-៨-៧៦ | ១៦-៩-៧៦ |
| ៨០៤ | លី ហ៊ុយ | យុទ្ធជន២៦០ | កងពល៧០៣ | ៣១-៨-៧៦ | ១៦-៩-៧៦ |
| ៨០៥ | ឆាយ ចេង | មន្ទីរ២៧០ | កងពល៧០៣ | ១-៩-៧៦ | ១៦-៩-៧៦ |
| ៨០៦ | សំ មឿន | យុទ្ធជន | ស២១-យ | ១១-៩-៧៦ | ១៦-៩-៧៦ |
| ៨០៧ | ពៀង ចន ហៅ ថា | កងហោ | ស២១-យ | ១៥-៩-៧៦ | ១៦-៩-៧៦ |
| ៨០៨ | ពត គា | យុទ្ធជន | ស២១-យ | ៣១-៨-៧៦ | ១៦-៩-៧៦ |
| ៨០៩ | សៀក សារឿន | យុទ្ធជន | ស២១-យ | ៣១-៨-៧៦ | ១៦-៩-៧៦ |
| ៨១០ | ដឹម ដឿន | យុទ្ធជន | ស២១-យ | ៣១-៨-៧៦ | ១៦-៩-៧៦ |
| ៨១១ | ញោ លាងអូន (ស្រី) | ប្រធានផ្នែក | រោងចក្រគ-៣ | ១២-៨-៧៦ | ១៦-៩-៧៦ |
| ៨១២ | លី យ៉េត (ស្រី) | ប្រពន្ធ ម៉ាត់ | រោងចក្រគ-៥ | ៥-៩-៧៦ | ១៦-៩-៧៦ |
| ៨១៣ | អ៊ុក សាត (ស្រី) | ប្រពន្ធ សាំង មឿង | រោងចក្រគ-២ | ១២-៧-៧៦ | ១៦-៩-៧៦ |
| ៨១៤ | បាន យន (ស្រី) | ពលកម្ម | រដ្ឋករទឹក | ៥-៨-៧៦ | ១៦-៩-៧៦ |
| ៨១៥ | ទេព សួងបូផា (ស្រី) | អគ្គលេខាធនាគារ | ភូមិតាឡី | ១-៩-៧៦ | ១៦-៩-៧៦ |
| ៨១៦ | រស់ រុន | ប្រជាជន | តំបន់១៥ | ១៩-៦-៧៦ | ១៦-៩-៧៦ |
| ៨១៧ | តែ លាងសេង ហៅ ទីលុន | ជាងម៉ូតូ | ជិតវត្តភ្នំ | ១០-៧-៧៦ | ១៦-៩-៧៦ |
| ៨១៨ | ងួន ស្រេង | កម្មករលក់ម៉ូតូ | ជិតវត្តភ្នំ | ១០-៧-៧៦ | ១៦-៩-៧៦ |
| ៨១៩ | ស ពុធ ហៅ សុវណ្ណ | កូនសិស្ស | ស្វាយរៀង | ២២-៨-៧៦ | ១៦-៩-៧៦ |
| ៨២០ | ឡាំ សិត (ស្រី) | ប្រជាជន | កំពង់ស្ពឺ | ៥-៩-៧៦ | ១៦-៩-៧៦ |
| ៨២១ | ឈុន បួយ ហៅ ចរិយា | ប្រជាជន | ពោធិចិនតុង | ១១-៩-៧៦ | ១៦-៩-៧៦ |
| ៨២២ | ហ៊ុន ហឿន | ប៉េអឹម | តំបន់១៥ | ១៩-៦-៧៦ | ១៦-៩-៧៦ |
| ៨២៣ | ដា យុន | ស័ក្តិ១ | តំបន់១៥ | ១៩-៦-៧៦ | ១៦-៩-៧៦ |
| ៨២៤ | នូ លុន | អាត់សាដង់ | តំបន់២៥ | ១-៧-៧៦ | ១៦-៩-៧៦ |
| ៨២៥ | ធុច សុភី | ស័ក្តិ២ម៉ារីន | រោងចក្រមេទ្យាមី | ៧-៧-៧៦ | ១៦-៩-៧៦ |
| ៨២៦ | ញ៉ឹក ស៊ីវ៉េងហួរ ហៅ វ៉េងហៀង | ស័ក្តិ២ | តំបន់២៥ | ២១-៨-៧៦ | ១៦-៩-៧៦ |

**(នៅមានត)**

*(ឯកសារខ្មែរក្រហម)*

# ដំណឹងផ្សេងៗស្រង់ពីវិទ្យុបរទេសថ្ងៃអាទិត្យ ទី២៤ ធ្នូ ១៩៧៨

**ក) កម្ពុជា**

វិទ្យុប៉េកាំងផ្សាយថ្ងៃទី២ធ្នូ ម៉ោ១៧:៣០នាទី សមមិត្ត អៀង សារី ទទួលទីភ្នាក់ងារសារព័ត៌មានស៊ិនហួ មានប្រសាសន៍ថា:

ឆ្នាំ១៩៧៨ ជាឆ្នាំលោតផ្លោះនៃការងារបរទេសកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងមួយឆ្នាំកន្លងទៅក្នុងការតស៊ូប្រឆាំងឈ្លានពានក្រោមការគាំទ្ររបស់សូវៀត កម្ពុជាបានទទួលសមានចិត្ត និងការគាំទ្រពីប្រទេសនិងប្រជាជនសកលលោកកាន់តែច្រើនឡើងៗ សូម្បីប្រទេសខ្លះពីមុនគ្មានសមានចិត្តចំពោះកម្ពុជាឥឡូវក៏ប្រកាន់អាប្បកិរិយាមានសមានចិត្តដល់កម្ពុជាដែរ នេះជាជ័យជម្នះធំបំផុតនៃកិច្ចការបរទេសកម្ពុជា ។ ក្នុងឆ្នាំនេះកម្ពុជាបានពង្រីកការទាក់ទងជាមួយបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ថែមទៀត ។ ការទាក់ទងកម្ពុជាជាមួយសម្ព័ន្ធបរទេសអាស៊ីអាគ្នេយ៍កាន់តែល្អឡើងហើយ ។ ការទាក់ទងកម្ពុជាជាមួយភូមា នេប៉ាល់ បង់ក្លាដេស ក៏បានរីកលូតលាស់ដែរ ។ កម្ពុជាបានពង្រីកការទាក់ទងជាមួយអឺរ៉ុប ជាពិសេសជាមួយប្រទេសអឺរ៉ុបខាងជើង ។ យើងខ្ញុំបានពង្រឹងពង្រីកថែមទៀត មហាមិត្តភាពសុទ្ធសាមគ្គីភាពជាមួយប្រទេសចិន ។

សមមិត្តឧបនាយកមន្ត្រីបានបិតិរីករាយចំពោះការទាក់ទងជួរទូតរវាងចិននិងអាមេរិក ។ សមមិត្តមានប្រសាសន៍ថា: "យើងខ្ញុំបានពង្រីកការទាក់ទងជាមួយកូរ៉េ កម្ពុជានិងកូរ៉េបានគោរពគ្នានិងគាំទ្រគ្នាទៅវិញទៅមក" ។

ឆ្នាំនេះមានប្រតិភូនៃប្រទេសជាច្រើន ឥស្សរជននៃមជ្ឈដ្ឋានសារព័ត៌មានបរទេសជាច្រើន ព្រមទាំងអ្នកយកព័ត៌មានអាមេរិកាំងបានមកភ្នំពេញកម្ពុជាបំពេញទស្សនកិច្ច ។ គេទាំងឡាយមើលឃើញសភាពការណ៍នៅទីនេះដែលប្រជាជនកម្ពុជាប្រឆាំងឈ្លានពានរបស់យួនយ៉ាងប្តូរផ្តាច់ប្រទេសជាតិមានភាពសុខសាន្ត ការកសាងបានដំណើរការជាប្រក្រតី ។

សមមិត្តវ៉ែកញែកថា "ការទាក់ទាក់ទងកម្ពុជាជាមួយអង្គការសហប្រជាជាតិបានរីកលូតលាស់ ដើម្បីពង្រីកការទាក់ទងជាមួយអង្គការសហប្រជាជាតិថែមទៀត យើងខ្ញុំអញ្ជើញលោក វ៉ាន់ហែម មកបំពេញទស្សនកិច្ចនៅកម្ពុជាប្រជាធិប-តេយ្យ ។

សមមិត្តឧបនាយក អៀង សារី មានប្រសាសន៍ថា ក្នុងឆ្នាំ១៩៧៩ កម្ពុជានិងពង្រីកការទាក់ទងនឹងបង្កើនការទៅមករកគ្នាជាមិត្តភាពជាមួយបណ្តាប្រទេសលោកថែមទៀត ។

សន្ធិសញ្ញាយួនវៀតណាមមានធាតុពិតជាសន្ធិសញ្ញាយោធា មានគោលបំណងវាតទីនឹងកាន់កាប់កម្ពុជានឹងអាស៊ីអាគ្នេយ៍ជាគ្រោះថ្នាក់ធំមហិមាចំពោះកម្ពុជានិងអាស៊ីអាគ្នេយ៍ទាំងមូល ។ យើងត្រូវតែរួមសាមគ្គីគ្នាឡើងប្រឆាំងតទល់និងគំនិតលោភលន់អនុត្តរភាពនិយមនៃសូវៀតវៀតណាម ។

អំពីនយោបាយបរទេសកម្ពុជាគោរពគោលការណ៍៥-ខរួមរស់នៅដោយសន្តិភាព ។

កម្ពុជាជាសមាជិកសកម្មនៃចលនាមិនចូលបក្សសម្ព័ន្ធ ។ កម្ពុជាគាំទ្រការតស៊ូរបស់ប្រជាជនគ្រប់ប្រទេសដែលប្រឆាំងចក្រពត្តិនិយម អាណានិគមនិយមថ្មីចាស់ វាតទីនិយម ។ កម្ពុជាជាប្រទេសឯករាជ្យ មានបូរណភាពដែនដីរបស់ប្រទេសខ្លួន ។ កម្ពុជាពង្រីកការទាក់ទងមិត្តភាពនិងបង្កើនសាមគ្គីភាព ហើយគាំទ្រគ្នាទៅវិញទៅមកជាមួយបក្សម៉ាក្សលេនីននិយមពិតប្រាកដលើសកលលោក លើមូលដ្ឋានអន្តរជាតិនិយមវណ្ណៈអធន ។

សារព័ត៌មានប្រជាជននៃប្រទេសចិន ច្បាប់ចេញថ្ងៃទី២៣ធ្នូនេះ បានចុះផ្សាយអត្ថបទរបស់ក្រុមអ្នកយកព័ត៌មាននៃទីភ្នាក់ងារព័ត៌មានស៊ិនហួ ក្រោមចំណងជើងថា "...ក្រែក-សមរភូមិបូព៌ាដែលកម្ពុជាប្រឆាំងទប់ទល់នឹងអំពើឈ្លានពានរបស់យួន" ។

កាលពីថ្ងៃ២០ធ្នូ ក្រុមអ្នកយកព័ត៌មាននៃទីភ្នាក់ងារសារ

ពត៌មានស៊ិនហួរ ដែលកំពុងបំពេញទស្សនកិច្ចនៅកម្ពុជា បានទៅទស្សនាតំបន់ក្រែក ។ នេះជាតំបន់មួយដែលតែងមានការប្រយុទ្ធក្តៅនៃសមរភូមិបូព៌ា តាំងពីយួនឈ្លានពានកម្ពុជាពីខែធ្នូ១៩៧៧មក ។ សមមិត្តបញ្ជាការសមរភូមិបូព៌ាដែលកំដរក្រុមអ្នកយកពត៌មានទៅទស្សនាបានពត៌មានថា ប៉ុន្មានថ្ងៃកន្លងទៅនេះ តំបន់ក្រែកមានភាពស្ងប់ស្ងាត់បន្តួរ តែនៅតំបន់មួយទៀតនៃភូមិភាគបូព៌ា គឺតំបន់ស្វាយរៀង កងទ័ពបដិវត្តកម្ពុជាកំពុងប្រយុទ្ធយ៉ាងតឹងតែងជាមួយនឹងពួកឈ្លានពាន ។

យើងបានឆ្លងកាត់ទន្លេមេគង្គពីកំពង់ចាម បន្តួសដំណើរទៅដល់សមរភូមិមុខ ។ តាមផ្លូវបានឃើញប្រជាជនកម្ពុជាអង់អាចនឹងធឹងវាយសម្រុកបង្កបង្កើនផលខស្សាហកម្មនិងកសិកម្មយ៉ាងមានះខ្ជាប់ខ្ជួន ។ សមាជិកសហករណ៍កសិកម្មរាប់ម៉ឺនរាប់ពាន់នាក់ កំពុងប្រូតកាត់ប្រមូលទុកដាក់ផលស្រូវយ៉ាងមមាញឹក ។ រទេះគោជាជួរៗកំពុងប្រមូលដឹកជញ្ជូនស្រូវទៅដាក់ទុក ។ មានស្រែមួយចំនួនគេបានស្ទូងសំណាបខៀវស្រងាត់រួចរាល់ហើយ ។

សមមិត្តអ្នកបញ្ជាការសរមភូមិមុខបានថ្លែងថា "យើងខ្ញុំបានជម្រាបមហាជនតាមវិទ្យុហើយថា ត្រូវខំប្រមូលប្រូតកាត់ទុកដាក់ផលស្រូវឲ្យរួចរាល់ក្នុង៤-៥ថ្ងៃនេះ ត្រូវដកមេរៀននៅរយៈពេលដដែលនេះ នៅឆ្នាំទៅមិញ កុំឲ្យយួនវាមកឆក់ប្លន់ស្រូវយើងទៀត" ។ កម្មាភិបាលនិងមហាជននៅតំបន់នេះនៅចាំច្បាស់លាស់អំពីយួនចោរប្លន់ ដែលចូលមកប្លន់យកស្រូវយ៉ាងច្រើនក្នុងពេលដែលវាចូលមកឈ្លានពានកម្ពុជាកាលពីដំណាច់ឆ្នាំទៅមិញ ។

សមមិត្តលេខាបក្សតំបន់ត្បូងឃ្មុំនៃភូមិភាគបូព៌ា បានមានប្រសាសន៍ថា ចុងឆ្នាំទៅមិញនិងដើមឆ្នាំនេះ ស្រុកពីរនៃតំបន់ត្រូវកងទ័ពយួនឈ្លានពាន ពួកវាប្លន់យកស្រូវអស់ជាង២ម៉ឺនតោន ។

ក្រែកឃ្លាតពីកំពង់ចាមតែប្រមាណ៦០គីឡូម៉ែត្រប៉ុណ្ណោះ ។ រថយន្តបើកតាមផ្លូវលេខ៧តែមួយម៉ោងកន្លះ ក៏អាចទៅដល់ ។ តាមផ្លូវយើងបានឆ្លងកាត់ផ្សារស្នួល ។ សមមិត្តកម្ពុជាដែលកំដរយើងខ្ញុំ ជម្រាបយើងខ្ញុំថា ពេលឈ្លានពានលើកទីមួយ យួនបានចូលជិតដល់ផ្សារស្នួល ។ កន្លែងនោះ យើងខ្ញុំឃើញផ្ទាល់ភ្នែក ផ្ទះសម្បែងដែលត្រូវកងទ័ពយួនបំផ្លាញ យើងខ្ញុំធ្វើដំណើរកាត់ផ្សារក្រែកទៅដល់គណៈបញ្ជាការមួយនៅជិតសមរភូមិមុខ ។ នៅជុំវិញគណៈបញ្ជាការនេះ សុទ្ធតែជាទីតាំងកងទ័ពកម្ពុជាក្នុងនោះរួមទាំងទីតាំងកាំភ្លើងធំនិងទីតាំងកាំភ្លើងបាញ់យន្តហោះផង ។ វិទ្យុទាក់ទងក្នុងគណៈបញ្ជាការបញ្ចេញស្នូរញាប់រន្ថើន ទទួលដំណឹងដែលផ្សាយមកពីសមរភូមិមុខ ។ កន្លែងនេះឋិតក្នុងរយៈបាញ់នៃកាំភ្លើងធំរបស់យួន ។

យើងខ្ញុំបានដឹងពីកន្លែងនោះថា អំពើឈ្លានពានថ្មីលើកនេះនៃកងទ័ពយួនមានតំបន់ខ្លះចូលជ្រៅ៦-៧គម ក្នុងដែនដីកម្ពុជា ។ កងទ័ពកម្ពុជាបានវាយបណ្តេញពួកវាចេញវិញរុញថយក្រោយ ១-៤គម ។ ហេតុនេះនៅតំបន់ខ្លះ កងទ័ពយួនឈ្លានពានចូលដីកម្ពុជាបានតែ២-៣គមប៉ុណ្ណោះ នៅតំបន់ខ្លះពួកវាត្រូវវាយបណ្តេញចេញទាំងស្រុងហើយ ។

មេមត់ដែលឃ្លាតពីក្រែកតែ៦គ.ម សព្វថ្ងៃនេះត្រូវកងទ័ពយួនទន្ទ្រានកាន់កាប់ មេមត់ជាតំបន់ដែលគេហៅថាតំបន់ផ្ទៃសន្ទូច ។ ដោយមកពីគណៈបញ្ជាការនេះនៅជិតសមរភូមិមុខពេក ដោយសមមិត្តអ្នកបញ្ជាការសមរភូមិបូព៌ា អញ្ជើញអ្នកយកពត៌មានទៅធ្វើការប្រជុំសន្និសីទនៅគណៈបញ្ជាការមួយផ្សេងទៀត ដែលនៅឆ្ងាយពីសមរភូមិមុខបន្តិច តែគណៈបញ្ជាការនោះក៏នៅក្នុងរយៈបាញ់នៃកាំភ្លើងធំរបស់យួនដែរ ។ នៅខាងក្រោយគណៈបញ្ជាការនេះមិនដល់១០០ម កាលពីប៉ុន្មានថ្ងៃមុន ចាប់ត្រូវកាំភ្លើងយួនបាញ់ផ្គក់ ។ ឥឡូវឃើញតែចម្ការចេកដែលត្រូវបំផ្លាញខ្ទេចខ្ទីអស់ ។ នៅក្នុងគណៈបញ្ជាការនោះ យើងខ្ញុំសន្ទនាជាមួយសមមិត្តអ្នកបញ្ជាការថ្នាក់កងពលមួយចំនួន បណ្តាសមមិត្តបានថ្លែងថា "សព្វថ្ងៃនេះកងទ័ពកម្ពុជាវាយទប់ទល់នឹងពួកយួនឈ្លានពានតាមវិធីដូចតទោះ គឺឲ្យកងទ័ពនៅតិចតួចវាយស្ទាក់នៅពីមុខ រួចព័ទ្ធវាពីក្រោយនិងពីចំហៀង ។ សព្វថ្ងៃកងទ័ពយួនមិនហ៊ានវាយលុកដោយកងទ័ពថ្មើរជើងផ្តេសផ្តាសទេ តែវាប្រើកាំភ្លើងធំបាញ់ផ្គក់ឬឲ្យយន្តហោះមកទម្លាក់គ្រាប់បែក កងទ័ពកម្ពុជាបាញ់ធ្លាក់យន្តហោះយួន២០គ្រឿងហើយ-នៅតំបន់ក្រែកធ្លាក់...គ្រឿង នៅតំបន់ស្វាយរៀង៨គ្រឿង ។

ក្នុងសង្គ្រាមរំដោះជាតិ៩ឆ្នាំ កងទ័ពកម្ពុជាមានពិសោធន៍បាញ់ធ្លាក់យន្តហោះគ្រប់ផុន ហេតុនេះមិនខ្លាចពួកឈ្លានពានវាប្រើយន្តហោះទេ ។ យន្តហោះយួនក៏បានទម្លាក់គ្រាប់បែកទៅលើភូមិគរ ជិតសមរភូមិមុខដែរ ។ ៨-៩ថ្ងៃមុនពួកវាបានទម្លាក់លើភូមិមួយនៅស្វាយរៀង បណ្តាលឲ្យមហាជនស្លាប់និងរបួស ។

បណ្តាសមមិត្តមានប្រសាសន៍ថា កងទ័ពយួនធ្លាប់ប្រើគ្រាប់បែកខ្ស័នពុលនៅតំបន់ក្រែកដែរ ។ គ្រាប់បែកផ្សែងពុលនេះម្យ៉ាងបាញ់ដោយកាំភ្លើងធំ ម្យ៉ាងបាញ់ដោយគ្រឿងបាញ់ផ្សែងពុល ប៉ុន្តែគ្រាប់បែកផ្សែងពុលនេះ ក៏មិនអាចជួយយិតយោងពួកឈ្លានពានដែរ កងទ័ពកម្ពុជាមានវិធីនឹងពួកវាហើយ ។

បណ្តាសមមិត្តវែកញែកថា កម្លាំងរស់កម្លាំងទ័ពយួនបានត្រូវខូចខាតច្រើននៅតំបន់ក្រែកតាំងពីចូលឆ្នាំនេះរៀងមក កងទ័ពយួនបានត្រូវកម្ទេចជាង១០០០ក្បាល ។ ឧទាហរណ៍ចាប់ពី១១កញ្ញា កងទ័ពយួនវាយប្រហារដោយឲ្យយន្តហោះរួមផ្សំនិងកាំភ្លើងវែង ។ ឆ្លងការប្រយុទ្ធ២ថ្ងៃកន្លះ កងទ័ពយួនត្រូវស្លាប់ជាង១០០ក្បាល ។

សមមិត្តអ្នកបញ្ជាការទាំងនេះបញ្ជាក់ថា ឥឡូវនេះកងទ័ពកម្ពុជាមានស្មារតីប្រយុទ្ធអង់អាចក្លៀវក្លាណាស់ នៅសមរភូមិផ្លូវលេខ៧ កងទ័ពកម្ពុជាទ្រាំទ្រនិងបានសាកល្បងមកហើយ ។ កងទ័ពកម្ពុជាមានជំនឿយ៉ាងមាំក្នុងការកម្ទេចវគ្គវាយលុករដូវប្រាំងរបស់កងទ័ពយួន បណ្តេញពួកឈ្លានពានឲ្យអស់ពីដីកម្ពុជាដែលវានៅទន្ទ្រានកាន់កាប់នៅឡើយ ។

បន្ទាប់ពីទស្សនាសមរភូមិតំបន់ក្រែក អ្នកយកពត៌មាននៅបានទៅទស្សនាចម្ការកៅស៊ូធំពីរនៅ ជុប និង ពាមជាំង ។ ចម្ការកៅស៊ូទាំងពីរនេះធ្លាប់ជាជម្រកនៃកងទ័ពយួនកាលពីមុន ។ ប្រជាជនកម្ពុជានៅទីនោះផ្តល់ស្បៀងនិងផ្ទះសម្បែងឲ្យកងទ័ពយួន ហើយនៅបានជួយឧបត្ថម្ភពួកវាច្រើនវិស័យទៀតផង ប៉ុន្តែសព្វថ្ងៃនេះរដ្ឋការយួនយកទោសសងគុណ ។ វាប្រហារយ៉ាងព្រហើនកោងកាចដោយទ្រង់ទ្រាយធំ ប៉ុនប៉ងគ្របាក់លេបកម្ពុជា ។ ពេលសន្ទនាជាមួយអ្នកយកពត៌មាន កម្មករចម្ការកៅស៊ូទាំងពីរនេះបានសម្តែងកំហឹងយ៉ាងខ្លាំងចំពោះអំពើឈ្លានពានអកតញ្ញូរបស់យួន ។

**១) យួន**

វិទ្យុអូស្ត្រាលី ម៉.៩. ភាសាអង់គ្លេស

យួនបាននិយាយថា វាកំពុងប្រឈមមុខនឹងសភាពការណ៍សេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរដោយគ្រោះធម្មជាតិធំ និងការឈ្លោះប្រកែកជាមួយចិននិងកម្ពុជា ។

នៅពេលអានសេចក្តីរាយការណ៍របស់រដ្ឋាភិបាលនៅមុខសភាយួន ឧបនាយករដ្ឋមន្ត្រីយួន ឡេថាញ់ងី បាននិយាយថា ផែនការណ៍ស្ទើរតែទាំងអស់អត់បានសម្រេច ។ ពីលើនេះទៀត យួនត្រូវផ្តាច់យកភោគទ្រព្យមួយចំនួនរបស់ខ្លួនទៅប្រើប្រាស់សម្រាប់ទាហាននៅសមរភូមិផង ហើយសម្រាប់រៀបចំឲ្យច្រើនជាងមុនក្នុងការវិវាទជាមួយចិននិងកម្ពុជា ។ ដោយជួបប្រទះនឹងទឹកជំនន់ ផលស្រូវបានតិចជាងគម្រោងចំនួន៣លានតោន ។ ឡេថាញ់ងី បាននិយាយទៀតថា ផ្ទះជិត៩០០.០០០ខ្នង ត្រូវខូចខ្ទី ហើយត្រូវការចំណាយច្រើនជាបន្ទាន់ដើម្បីសង់ឡើងវិញជាទូទៅ ។

## ពន្យល់ពាក្យខ្មែរក្រហម

- **យុទ្ធសាស្ត្រ ឬ រណសាស្ត្រ:** ក្បួនរៀនខាងចម្បាំងក្បួនប្រយុទ្ធផ្សេងៗ ។
- **ចិត្តសាស្ត្រ ឬ ចិត្តវិទ្យា:** ចិត្តវិជ្ជាក្បួនរៀនខាងផ្លូវចិត្តមើលចិត្ត ។
- **នយោបាយ:** ឧបាយជាគ្រឿងដឹកនាំ ។

**(សៀវភៅកំណត់ហេតុ ប៊ុន ធឿន)**

- **អនុធនទីក្រុង:** ជាកម្លាំងសម្ព័ន្ធមិត្តជិតស្និទ្ធរបស់កម្មករ-កសិករ ។
- **សម្ព័ន្ធយុវកក:** សម្ព័ន្ធយុវជនកុម្មុយនិស្តកម្ពុជា ។

**(សៀវភៅកំណត់ហេតុ ០៦៩)**

- **សារវត្ថុ:** គឺអ្វីមួយដែលមានប្រយោជន៍សំខាន់ធំដុំដែលត្រូវប្រើប្រាស់គិតគូរជាចាំបាច់គ្រប់ពេលវេលា ។

**(សៀវភៅកំណត់ហេតុអ៊ីវ)**

# ការព្រួយបារម្ភរបស់ម្តាយ ឌុច និងវិស័យច្បាប់នៅកម្ពុជា

នៅថ្ងៃទី៦ ខែមិថុនា រាជរដ្ឋាភិបាលកម្ពុជា និងទីប្រឹក្សាច្បាប់របស់អង្គការសហប្រជាជាតិបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ដើម្បីបង្កើតតុលាការខ្មែរក្រហម ក្រោយពីមានការចរចាអស់រយៈពេលជាច្រើនឆ្នាំមក ។ ចុងចោទមួយរូបដែលនឹងត្រូវលេចមុខនៅក្នុងតុលាការនេះគឺ កាំង ហ្កិច អៀវ ឈ្មោះបដិវត្តន៍ ឌុច ដែលជាអតីតប្រធានគុកទួលស្លែងដ៏ល្បីអសោចរបស់ខ្មែរក្រហម ។ ភស្តុតាងរូបវ័ន្តនិងឯកសារជាច្រើនភ្ជាប់ ឌុច ទៅនឹងការធ្វើទារុណកម្មនិងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយការសារភាពរបស់ ឌុច ក្នុងឆ្នាំ១៩៩៩ នៅចំពោះមុខអ្នកសារព័ត៌មាន នេត ថាយ័រ ក៏បានបង្ហាញអំពីការផ្សារភ្ជាប់យ៉ាងដូច្នេះដែរ ។ ក្រោយមក ឌុច បានដកសម្តីរបស់ខ្លួនវិញដោយនិយាយថា គាត់ពុំបានសម្លាប់នរណាម្នាក់ឡើយ ហើយគាត់ "គ្រាន់តែជាកម្មាភិបាលតូចតាចរបស់ខ្មែរក្រហមម្នាក់ប៉ុណ្ណោះ" ដែលគ្មានអំណាចគ្រប់គ្រាន់ ដើម្បីបញ្ឈប់នូវអំពើឃោរឃៅដែលដាក់បញ្ជាដោយមេដឹកនាំបក្សបានទេ ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលតុលាការខ្មែរក្រហមចាប់ដំណើរការ ឌុច ប្រាកដជានឹងត្រូវនាំឡើងតុលាការពីបទឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ ។

នៅក្នុងបទសម្ភាសន៍ជាមួយម្តាយរបស់ ឌុច ឈ្មោះ គីម សៀវ និងប្អូនស្រីរបស់ ឌុច ឈ្មោះ គីម ហៀវ គ្មាននរណាម្នាក់អាចនឹកស្មានសោះឡើយថា អ្នកទាំងពីរមានញាតិបង្កើតម្នាក់ដែលត្រូវចោទប្រកាន់ថាមានការទទួលខុសត្រូវពីបទឧក្រិដ្ឋកម្មដ៏ឃោរឃៅរបស់គុកទួលស្លែង ហើយបានបញ្ជូនជនរងគ្រោះរាប់ពាន់នាក់ទៅកាន់វាលពិឃាតជើងឯក ។ ឌុច កើតនៅក្នុងឆ្នាំ១៩៤២ នៅក្នុងគ្រួសារមួយដែលមានសមាជិក៧នាក់ ហើយគាត់ជាកូនច្បងនិងជាកូនប្រុសតែមួយគត់របស់គ្រួសារ ។ ឌុច មានកំណើតនៅក្នុងភូមិមួយតាមដងស្ទឹងស្ទោង ស្រុកស្ទោង ខេត្តកំពង់ធំ ។ ម្តាយ ឌុច និយាយទាំងញញឹមថា "ឌុច ជាក្មេងសុភាពនិងចេះគោរពចាស់ទុំ ។ វាមិនដែលរើសម្ហូបទេ ស្អីក៏ហូបដែរពេលមកពីរៀន មិនចេះត្អូញត្អែរមួយម៉ាត់ឡើយ ។ វារៀនពូកែចេះជួយធ្វើការងារផ្ទះ ហើយស្រលាញ់បងប្អូន ។ វាមិនសូវមាត់កប៉ុន្មានទេ ចូលចិត្តស្ងួចត្រីនៅតាមដងស្ទឹង" ។ គីម ហៀវ បន្តថា "គាត់រៀនពូកែណាស់ ជាពិសេសផ្នែកគណិតវិទ្យា" ។

ឌុច បន្តការសិក្សានៅទីរួមខេត្តកំពង់ធំ ហើយក្រោយមកនៅខេត្តសៀមរាប ។ ដោយសាររៀនពូកែ នៅអំឡុងឆ្នាំ១៩៦១ ឌុច បានក្លាយទៅជាគ្រូបង្រៀនគណិតវិទ្យា ។ ឌុច មកលេងផ្ទះជាញឹកញាប់ក្នុងអំឡុងពេលមុនរដ្ឋប្រហាររបស់សេនាប្រមុខ លន់ ណុល នៅខែមីនា ឆ្នាំ១៩៧០ ប៉ុន្តែម្តាយនិងប្អូនស្រីរបស់ ឌុច បានឲ្យដឹងថាក្នុងពេលមកលេងផ្ទះ ឌុច មិន ដែលនិយាយប្រាប់ពួកគាត់អំពីរឿងនយោបាយឡើយ ហើយគាត់នៅតែជាកូននិងបងប្រុសដែលសុភាព គោរពចាស់ទុំ និងស្រលាញ់បងប្អូនដដែល ។

នៅក្នុងអំឡុងសង្គ្រាមស៊ីវិលពីឆ្នាំ១៩៧០-១៩៧៥ ឌុច មិនបានមកផ្ទះវិញទេ ប៉ុន្តែបានត្រឡប់មកស្រុកជាញឹកញាប់ក្រោយថ្ងៃដែលខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជាទាំងស្រុងនៅខែមេសា ឆ្នាំ១៩៧៥ ។ អ្នកមីង គីម ហៀវ និយាយថា "យើងមិនដឹង ឌុច ធ្វើអ្វីឡើយនៅក្នុងសម័យខ្មែរក្រហម ។ គាត់មិនដែលនិយាយអំពីការងាររបស់គាត់ប្រាប់សោះ ហើយមើលទៅគាត់ក៏មិនមានអ្វីប្លែកពីមុនដែរ ។ គាត់ស្លៀកពាក់សម្លៀកបំពាក់អាវខ្មៅខោខ្មៅនិងមានក្រមាមួយដូចកម្មាភិបាលផ្សេងទៀតដែរ" ។

ក្រោយការវាយលុករបស់កងទ័ពវៀតណាមនៅឆ្នាំ១៩៧៩ ឌុច បានបាត់ខ្លួនសាជាថ្មីហើយ អស់រយៈកាលជិតពីរទសវត្សរ៍គ្រួសាររបស់ ឌុច មិនដែលបានជួបមុខ ឌុច ទាល់តែសោះ ។ ម្តាយ ឌុច ពោលថា "ខ្ញុំគិតថាវាស្លាប់បាត់ទៅហើយ ។ ពេលខ្ញុំបានឃើញវាវិញខ្ញុំសប្បាយចិត្តរកអ្វីប្រៀបផ្ទឹមពុំបានឡើយ ។ ខ្ញុំសឹងតែមិនជឿសោះថាវានៅរស់ដល់សព្វថ្ងៃ" ។ មុនឆ្នាំ១៩៩៥ ឌុច បានរស់នៅក្នុងសភាពគោកយ៉ាកនៅក្នុងតំបន់ខ្មែរក្រហមកាន់កាប់ភាគពាយ័ព្យនៃប្រទេសកម្ពុជា ។

បន្តិចម្តងៗ ឌុច បានងាកទៅប្រតិបត្តិតាមគន្លងគ្រិស្តសាសនា ។ នៅក្នុងឆ្នាំ១៩៩៥ ក្រោយពីពេលដែលប្រពន្ធរបស់ខ្លួនត្រូវលួចធ្វើឃាត ឌុច បានចូលសាសនាគ្រិស្ត ។ ឌុច បានប្រែឈ្មោះទៅជា តាពិន ហើយបានចាប់ផ្តើមដើរផ្សព្វផ្សាយធម៌ព្រះយេស៊ូក្នុងពេលបម្រើការងារជាបុគ្គលិកពេទ្យជំនួយមនុស្សធម៌នៅក្នុងជំរំជនភៀសខ្លួន ។ ក្រោយមក ឌុច បានមកលេងស្រុកកំណើតនិងម្តាយជាញឹកញយ ។ នៅឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជាបានស្រាវជ្រាវរកឃើញលំនៅដ្ឋានរបស់ ឌុច ហើយការដួលរលំរបស់ខ្មែរក្រហមបានជួយឲ្យការចាប់ខ្លួន ឌុច កាន់តែងាយស្រួល ។ ទាហានរដ្ឋាភិបាលបានចាប់ខ្លួន ឌុច នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រួចបញ្ជូនតាមឧទ្ធម្ភាគចក្រ យកមកឃុំឃាំងនៅក្នុងគុករបស់តុលាការយោធានៅទីក្រុងភ្នំពេញ ។ មន្ត្រីតុលាការបានចោទប្រកាន់ ឌុច ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងអំពើក្បត់ជាតិ ហើយតែងតាំងមេធាវីម្នាក់ឈ្មោះ កា សាវុធ ជាមេធាវីការពារក្តីរបស់ ឌុច ។

ម្តាយនិងប្អូនរបស់ ឌុច បានទទួលដំណឹងពីការចាប់ខ្លួន ឌុច តាមរយៈអ្នកភូមិម្នាក់ដែលបានទទួលដំណឹងតាមរយៈប្រព័ន្ធផ្សព្វផ្សាយពត៌មាន ។ គីម ហៀវ បាននិយាយថា «យើងមាន



ប្អូនស្រីឌុចៈ គីម ហៀវ

ការរន្ធត់ចិត្តយ៉ាងខ្លាំងបន្ទាប់ពីបានទទួលដំណឹងពីការចាប់ខ្លួនគាត់» ។ គីម សៀវ ងក់ក្បាលហើយនិយាយថា «កូនខ្ញុំបានមកលេងផ្ទះជាច្រើនលើកក្នុងចន្លោះឆ្នាំ១៩៩៦ទៅ១៩៩៩ ប៉ុន្តែវាមិនដែលនិយាយអំពីរឿងខ្មែរក្រហមប្រាប់ខ្ញុំសោះ ។ ខ្ញុំមិនដឹងថាវាបានធ្វើអ្វីទេនៅសម័យខ្មែរក្រហម ។ ពេលមកលេងផ្ទះវាគ្រាន់តែសួរសុខទុក្ខបងប្អូនប៉ុណ្ណោះ ។ ខ្ញុំភ័យណាស់ នៅពេលដែលឮថាវាត្រូវគេចាប់ខ្លួន ។ ខ្ញុំសង្ឃឹមថាគេមិនប្រហារជីវិតវាទេ» ។

នៅទីក្រុងភ្នំពេញ កា សាវុធ បានទាមទារឲ្យមានតុលាការមួយឲ្យបានឆាប់ ។ គាត់បានថ្លែងថា ឌុច ចង់និយាយបកអាក្រាតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែល ឌុច ចោទប្រកាន់ថា បានបញ្ជាគាត់ឲ្យអនុវត្តការកាប់សម្លាប់ ។ ច្បាប់កម្ពុជាអនុញ្ញាតឲ្យមានការឃុំឃាំងមុនការកាត់ទោសរយៈពេល៦ខែ ។ ទោះជាយ៉ាងនេះក៏ដោយ នៅខែសីហា ឆ្នាំ១៩៩៩ សភាជាតិកម្ពុជា បានអនុម័តច្បាប់មួយដែលអនុញ្ញាតឲ្យមានការឃុំខ្លួនមុនការជំនុំជម្រះក្តីរហូតដល់ទៅ៣ឆ្នាំ សម្រាប់ជនជាប់ចោទពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ អ្នកគាំទ្រអង្គការសិទ្ធមនុស្សនិងអង្គការសហប្រជាជាតិបានរិះគន់ច្បាប់នេះថាជាការរំលោភទៅលើសិទ្ធិរបស់ជនជាប់ចោទ ។ ប៉ុន្តែ



ម្តាយឌុចៈ គីម សៀវ



ឌុច

ច្បាប់នេះនៅតែត្រូវគេយកទៅអនុវត្តដដែល ។ នៅខែឧសភា ឆ្នាំ ២០០២ នៅពេលដែលការឃាត់ខ្លួនរបស់ ឌុច រយៈពេល៣ឆ្នាំត្រូវបានបញ្ចប់ ចៅក្រមស៊ើបអង្កេត ងិន សំអាន បានចោទប្រកាន់គាត់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលនាំឲ្យមានការឃុំខ្លួនឌុចរយៈពេល៣ឆ្នាំទៀត ។

លោក កា សាវុធ បាននិយាយថា ឌុច មិនសូវនិយាយរៀបរាប់អំពីលក្ខខណ្ឌនៅក្នុងគុកឡើយ ។ នៅចុងឆ្នាំ២០០១ ពេទ្យកងទ័ពម្នាក់ឈ្មោះ ទូត ណារ៉ា បានបង្ហាញឲ្យដឹងថា ឌុច កំពុងតែមានជំងឺភ្នែកនិងត្រចៀក ប៉ុន្តែលោក ងិន សំអាន ក្រោយមករាយការណ៍ថា ឌុច មានសុខភាពរឹងមាំជាងមុនពេលបញ្ជូនមកកាន់មន្ទីរឃុំឃាំងទៅទៀត ។ ម្តាយនិងប្អូនរបស់ ឌុច បានទទួលដំណឹងតិចតួចបំផុតអំពីការចោទប្រកាន់ទៅលើ ឌុច ។ ពួកគាត់មិនសូវយល់ដឹងអំពីច្បាប់ជាតិនិងអន្តរជាតិនិងនយោបាយដ៏ស្មុគស្មាញដែលនឹងសម្រេចជោគវាសនារបស់ឌុចឡើយក្រៅអំពីការព្រួយបារម្ភទៅលើ ឌុច នៅក្នុងគុក និងការកាត់ទោស ឌុច ។ «គេនឹងយកគាត់ទៅសម្លាប់ឬអត់?» គឹម សៀវ បានសួរនាំម្តងហើយម្តងទៀត ដោយមិនដឹងច្បាស់អំពីទណ្ឌកម្ម ដែល ឌុច ត្រូវទទួល ។ អ្នកមីង គឹម ហៀវ សួរថា «តើគាត់មានមេធាវីជួយការពារឬអត់?» អ្នកទាំងពីរចេះតែព្រួយបារម្ភដោយសារមិនដឹងអំពីច្បាប់ពាក់ព័ន្ធទៅនឹងរឿងក្តីរបស់ ឌុច ។

នៅចុងឆ្នាំ១៩៩៩ គឹម ហៀវ បានធ្វើដំណើរទៅទីក្រុងភ្នំពេញ ក្នុងគោលបំណងទៅជួប ឌុច នៅក្នុងពន្ធនាគារ ។ គាត់និយាយថា «ខ្ញុំចំណាយអស់រយៈពេលបីយប់ បីថ្ងៃ ទំរាំដឹងអំពីទីកន្លែងដែលគេយកគាត់ទៅឃុំ ។ ខ្ញុំចាំនៅក្រៅគុកអស់រយៈពេលជាច្រើនម៉ោងរង់ចាំឲ្យគេអនុញ្ញាតឲ្យខ្ញុំចូល ។ ឲ្យតែឃើញអ្នកធ្វើការនៅទីនោះដើរចេញមក ខ្ញុំប្រាប់គេថា ខ្ញុំជាប្អូនរបស់ ឌុច ប៉ុន្តែគ្មាននរណាម្នាក់អនុញ្ញាតឲ្យខ្ញុំជួបគាត់សោះ» ។ មន្ត្រីគុកបានទទួលយកបង្អែបរបស់គាត់ទៅឲ្យ ឌុច ប៉ុន្តែមិនបានពន្យល់គាត់អំពីមូលហេតុដែលគាត់មិនអាចចូលជួបទេ ។

ឆ្នាំនេះមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើសំណើរមួយដើម្បីសុំជួបសម្ភាសជាមួយ ឌុច ប៉ុន្តែត្រូវបដិសេធ ។

ឌុច នឹងត្រូវនាំខ្លួនទៅកាន់តុលាការខ្មែរក្រហម ហើយមានភស្តុតាងជាច្រើនបង្ហាញពីការជាប់ពាក់ព័ន្ធរបស់ ឌុច ទៅនឹងអំពើឃោរឃៅធ្ងន់ធ្ងរ ហើយនៅក្រោមច្បាប់ដែលពាក់ព័ន្ធជនដែលផ្តល់បញ្ជាថ្នាក់កំពូលមិនអាចមានការការពារក្តីទេ ។ តែទោះជាយ៉ាងនេះក៏ដោយការជាប់ឃុំដែលមានលក្ខណៈចំហរបស់ ឌុច គឺពុំមានភាពយុត្តិធម៌នៅក្នុងច្បាប់ឡើយ ។ តុលាការខ្មែរក្រហមគួរត្រូវបង្កើតឡើងដើម្បីយុត្តិធម៌មិនមែនការសងសឹកនោះទេ ។ គោលការណ៍ចម្បងមួយនៃយុត្តិធម៌គឺសិទ្ធិទទួលការចាត់ទុកថាគ្មានកំហុស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។ នៅក្នុងគុកទួលស្លែង និងកន្លែងផ្សេងទៀត ខ្មែរក្រហមមិនបានគោរពតាមគោលការណ៍នេះទេ ហើយនិយាយថា «ស៊ូចាប់ប្រទ្បុំ១០នាក់ កុំឲ្យលែងខ្មាំងប្រឡំម្នាក់» ។ ជ័យជម្នះទៅលើកេរដំណែលដ៏រន្ធត់នេះមានន័យថា ជាការបំបាត់ចោលនូវភាពអយុត្តិធម៌ក្នុងក្របខ័ណ្ឌច្បាប់ទោះជាភស្តុតាងប្រឆាំងនឹងជនជាប់ចោទមានលើសលប់ក៏ដោយ ។

រាជរដ្ឋាភិបាល ត្រូវធានាឲ្យឃើញថាទង្វើរបស់ខ្លួនទៅលើជនជាប់ឃុំទោះជាជននោះ ជាប់ចោទពីបទល្មើសធ្ងន់ធ្ងរយ៉ាងណាក៏ដោយស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ។ សិទ្ធិមួយចំនួនដូចជាសិទ្ធិទទួលការពិភាក្សាទទួលការថែទាំសុខភាព និងបរិភោគគ្រប់គ្រាន់ បើតាមការសង្កេតត្រូវបានបំពេញ ។ ចំណែកឯចំណុចផ្សេងទៀតវិញទាមទារឲ្យមានការកែលម្អ ។ រយៈពេលនៃការជាប់ឃុំរបស់ ឌុច គឺយូរហួសពេកទៅហើយ ។ តុលាការខ្មែរក្រហមនឹងត្រូវបង្កើតឡើងក្នុងពេលឆាប់ៗខាងមុខនេះ ប៉ុន្តែបើមានការពន្យាពេលតទៅទៀតយុត្តិធម៌ទាមទារឲ្យរដ្ឋាភិបាលផ្តល់នូវការពិចារណាឲ្យបានត្រឹមត្រូវចំពោះការដោះលែង ឌុច ។ លើសពីនេះការឃុំខ្លួនមួយដែលយុត្តិធម៌ជាការឃុំខ្លួនដែលផ្តល់ដល់ ឌុច នូវសិទ្ធិសុំជួប ។

ការផ្តល់សិទ្ធិដល់សមាជិកគ្រួសាររបស់ ឌុច ជាការគោរពសិទ្ធិមនុស្សជាមូលដ្ឋាននិងសិទ្ធិរបស់ជនជាប់ចោទ ។ ការអនុញ្ញាតឲ្យមានការត្រួតពិនិត្យមន្ទីរឃុំឃាំង និងសួរសុខទុក្ខ ឌុច នៅក្នុងគុកពីសំណាក់អង្គការក្រៅរដ្ឋាភិបាលជាការបង្ហាញអំពីការរីកលូតលាស់នូវវិស័យច្បាប់របស់កម្ពុជា ។

**ចន ឆរតីអារី និង អេង កុកថាយ**

# យាយ អន រំឭករឿងដើម




លោកយាយ អ៊ូ អន អាយុ៦៩ ឆ្នាំ ជាស្ត្រីមេម៉ាយមានកូន៥នាក់ ។ ប្តីរបស់យាយបានស្លាប់តាំងពី៣១ឆ្នាំមុនមកម្ល៉េះ ។ បច្ចុប្បន្នយាយរស់នៅជាមួយកូនៗនិងចៅៗ នៅភូមិពោធិទន្ទេ ឃុំកោះធំ“ក” ស្រុកកោះធំ ខេត្តកណ្តាល ។

យាយអន កើតឆ្នាំកុរ(ត្រូវនឹងឆ្នាំ១៩៣៤) នៅភូមិពោធិទន្ទេ គឺភូមិដែលយាយកំពុងរស់នៅនាពេលបច្ចុប្បន្ន ។ ឪពុករបស់យាយឈ្មោះ អ៊ូ ម្តាយឈ្មោះ ហង្ស ដែលជាអ្នកស្រែចម្ការសុទ្ធសាធ ។ យាយអន និយាយថា “ឪពុកខ្ញុំចំតួណាស់ គាត់ថាលុយក៏នៅនឹងចម្ការ មាសក៏នៅនឹងចម្ការ ប្រាក់ក៏នៅនឹងចម្ការ គាត់មិនដែលជួញមិនដែលលក់អីទេ” ។ យាយមានបងប្អូនស្រី៣នាក់ ប្រុសម្នាក់ ។ យាយជាកូនច្បង ។ នៅពេលយាយមានអាយុ១០ឆ្នាំ ម្តាយរបស់យាយបានស្លាប់ដោយជំងឺអាសន្នរោគ ហើយប្អូនទី៤របស់យាយដែលទើបតែមានអាយុ៣ខែក៏ស្លាប់ដែរ ។ យាយបានឲ្យដឹងថា កាលពីជំនាន់យាយនៅក្មេង ជំងឺអាសន្នរោគសម្លាប់មនុស្សច្រើនណាស់ ព្រោះគ្មានមន្ទីរពេទ្យនៅតាមស្រុកឃុំដូចបច្ចុប្បន្ននេះទេ មានតែនៅភ្នំពេញ ហើយមធ្យោបាយធ្វើដំណើរគឺចែវទូកឬថ្មើរជើង ដូច្នេះអ្នកជំងឺអាសន្នរោគមិនបានទទួលការសង្គ្រោះទាន់ពេលវេលាឡើយ ។

ក្រោយពេលដែលម្តាយរបស់យាយស្លាប់ប្រមាណ១០ឆ្នាំ ឪពុករបស់យាយក៏រៀបការប្រពន្ធក្រោយទៀតឈ្មោះ ចៅ និងបានកូនប្រុសម្នាក់ទៀត ។ ម្តាយក្រោយរបស់យាយស្រលាញ់អាណិតបងប្អូនទាំងបីនាក់របស់យាយដូចជាកូនបង្កើតរបស់គាត់ ។ គាត់ចិញ្ចឹមបីបាច់បងប្អូនរបស់យាយយ៉ាងល្អនិងរៀបចំឲ្យមានគូស្រករគ្រប់ៗគ្នា ។ បច្ចុប្បន្ន ម្តាយក្រោយរបស់យាយនៅរស់នៅឡើយ ។ គាត់មានអាយុ៨៦ឆ្នាំ ។ ចំណែកឪពុករបស់យាយស្លាប់កាលពី៥ឆ្នាំមុន ក្នុងជន្មាយុ៩០ឆ្នាំ ។

កាលពីយាយនៅក្មេង ជីវិតរបស់យាយពោរពេញទៅដោយសេចក្តីសុខណាស់ រស់នៅសម្បូរសប្បាយមិនដែលខ្វះខាតស្បៀងអាហារឡើយ ។ ឪពុករបស់យាយមានដីស្រែចម្ការធំទូលាយ ដាំពោត ស្រូវ ថ្នាំជក់ សណ្តែក ល្ង ទៅតាមរដូវកាលអាស្រ័យលក្ខណៈអំណោយផលនៃស្ថានភាពដីនិងធាតុអាកាស ។ ភោគផលកសិកម្មដែលទទួលបានល្មមគ្រប់គ្រាន់សម្រាប់ហូបពេញមួយឆ្នាំមិនដែលខ្វះខាត ពេលខ្លះថែមទាំងសល់ដូរបានអំបិល ប្រហុក ផ្អក ស្ករ និងគ្រឿងឧបភោគបរិភោគផ្សេងៗទៀតផង ។

យាយបាននិយាយថា កាលគាត់នៅក្មេងមិនដែលពិបាករត់គេចពីសង្គ្រាមទេ ។ កាលណោះប្រទេសកម្ពុជានៅក្រោមអាណានិគមនិយមរបស់បារាំងនិងជប៉ុន ។ ជួនកាលកងទ័ពឥស្សរៈបានធ្វើដំណើរឆ្លងកាត់ភូមិដែរប៉ុន្តែមិនដែលធ្វើទុក្ខទោសប្រជាជនឡើយ ។ កងទ័ពឥស្សរៈទាំងអស់នោះមានសម្លៀកបំពាក់ពណ៌ខ្មៅដើរកាត់ភូមិដោយស្ងៀមស្ងាត់និងរហ័សរហួន មិនដែលស្នាក់នៅក្នុងភូមិ ហើយក៏មិនដែលសុំស្រូវអង្ករ មាន់ទា ឬម្ហូបអាហារពីអ្នកភូមិដែរ ។

យាយមិនបានទៅរៀនសូត្រទេ ដោយសារកាលពីជំនាន់យាយនៅតូចមិនទាន់មានសាលារៀន មានតែវត្តអារាមប៉ុណ្ណោះដែលមានតួនាទីបណ្តុះបណ្តាលក្មេងប្រុស ចំណែកក្មេងស្រីមិនត្រូវបានអនុញ្ញាតឲ្យទៅរៀនឡើយ ។ ក្រោយពេលដែលយាយមានកូន២នាក់ យាយបានទៅរៀនអក្ខរកម្មដែរ ប៉ុន្តែយាយនិយាយថា *“រៀនមិនចេះទេ កូនជាប់នឹងដៃរញ៉េរញ៉ៃពីរបី យូរៗទៅកូនយំផង កូនឈឺផង លែងរៀនទៅ លែងចេះទៅ”* ។

ឪពុកម្តាយរបស់យាយបានរៀបចំទុកដាក់ឲ្យយាយមានប្តីនៅអាយុ២០ឆ្នាំ ។ ប្តីរបស់យាយឈ្មោះ ស្រ៊ន ជាអ្នកស្រែចម្ការ ។ ដោយមានចលនាទៅរានយកដីថ្មីនៅខេត្តព្រៃវែង ឪពុករបស់យាយក៏បានទៅរានដីថ្មីនៅភូមិកោះរកា (ឃុំកោះរកា ស្រុកពាមជរ ខេត្តព្រៃវែង) នៅជិតព្រំដែនវៀតណាម ហើយយាយ

និងស្វាមីក៏រើទីលំនៅទៅរស់នៅទីនោះបន្ទាប់ពីមានកូនមួយ ។ អ្នកទាំងពីរបានកាប់គាស់រានដីថ្មីនិងទិញដីពីអ្នកដែលទៅរស់នៅមុនៗផង បានដីធំទូលាយសម្រាប់ដាំស្រូវនិងដំណាំចម្ការផ្សេងៗទៀត បានភោគផលហូរហៀរហូបមិនអស់ ។ ប្តីប្រពន្ធរបស់យាយសន្សំប្រាក់សង់បានផ្ទះក្បឿងពីរខ្នងធំល្វឹងល្វើយនិងមានដីបម្រុងទុកសម្រាប់ជាកេរចែកកូនគ្រប់ៗគ្នា ។

បន្ទាប់ពីរដ្ឋប្រហាររបស់ លន់ ណុល នៅខែមីនា ឆ្នាំ១៩៧០ កងទ័ពជើងទឹកនិងជើងគោករបស់វៀតណាមបានឡើងមកប្រទេសកម្ពុជា បណ្តាលឲ្យប្រជាជនមានការភិតភ័យក៏រត់ប្រាសឡើងមកប៉ែកខាងលើនៃប្រទេស ។ ក្រុមគ្រួសាររបស់យាយដែលពេលនោះទើបតែមានកូន៤នាក់ បានជិះកង់ពីរគ្រឿងរត់មកស្រុកកោះធំវិញ ដោយអត់បានយកអ្វីទាំងអស់តាមខ្លួន ។ យាយនិងប្តីបោះបង់ ផ្ទះសម្បែង គោក្របី ទូករទេះ ដីស្រែចម្ការ និងភោគផលដំណាំគ្រប់ប្រភេទ ។ យាយបាននិយាយទាំងអស់សំណើចថា «នេះដូចពាក្យចាស់ថា ខ្មែរយើងរួចខ្លួន ខោអាវបានយួន រួចខ្លួនទទេ» ។ ពេលដែលយាយត្រឡប់ទៅនៅភូមិពោធិទន្លេប្រមាណពីរសប្តាហ៍ យន្តហោះការចាប់ផ្តើមទម្លាក់គ្រាប់បែកលើតំបន់មួយចំនួនដែលសង្ស័យថាមានវៀតកុងលាក់ខ្លួន ។

នៅឆ្នាំ១៩៧១ ពេលដែលកូនទី៦របស់យាយទើបនឹងមានអាយុ៧ខែ ប្តីរបស់យាយបានស្លាប់ដោយសារត្រូវគ្រាប់ផ្លោងមកពីម៉ារីន ក្នុងខណៈពេលដែលគាត់កំពុងតែធ្វើដំណើរតាមផ្លូវ ។ ចាប់ពីឆ្នាំ១៩៧២ ខ្មែរក្រហមបានគ្រប់គ្រងស្រុកកោះធំស្ទើរតែទាំងមូល ។ ភោគផលដែលប្រជាជនផលិតបានត្រូវប្រមូលយកមកដាក់រួមទាំងអស់ រួចទើបចែកទៅវិញតាមចំនួនមនុស្សនៅក្នុងគ្រួសារ ។

ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនទាំងអស់នៅក្នុងភូមិពោធិទន្លេត្រូវខ្មែរក្រហមជម្លៀសទៅក្អមសំណ ហើយយកប្រជាជនពីទីកន្លែងផ្សេងៗមកឲ្យរស់នៅក្នុងភូមិពោធិទន្លេ និងបានយកទីនោះធ្វើជាមន្ទីរសន្តិសុខនិងកន្លែងសម្លាប់មនុស្ស ។ យាយនិយាយថា មូលហេតុដែលខ្មែរក្រហមយកប្រជាជនពីភូមិពោធិទន្លេទៅឲ្យរស់នៅក្បែរព្រំដែនវៀតណាម ដោយសារខ្មែរក្រហមចាត់ទុកអ្នកទាំងអស់ជាអ្នកពេញសិទ្ធិ ។ យាយបញ្ជាក់បន្ថែមថា «ពួកខ្ញុំនេះសុទ្ធតែពេញសិទ្ធិហើយ ពេញនឹងអត់បាយ ពេញនឹងហូបគ្រាប់ពោត ពេញនឹងរត់គេចគ្រាប់ផ្លោង» ។

នៅក្អមសំណ ខ្មែរក្រហមបានចាត់តាំងយាយឲ្យធ្វើការនៅក្នុងក្រុមស្ត្រីមានផ្ទៃពោះនិងស្ត្រីចាស់ៗនាំគ្នាដើរប្រូតចុងត្រែងយកមកក្រងធ្វើកណ្តបសម្រាប់ប្រក់ផ្ទះ ។ ដោយសារនៅតំបន់ក្អមសំណមិនសម្បូរដើមត្នោតម៉្លោះហើយចុងត្រែងត្រូវបានប្រើជំនួសស្លឹកត្នោតក្នុងការប្រក់ផ្ទះ ។ ជួនកាលក្រុមរបស់យាយទៅជជុះចំបើងយកសរសៃវែងៗមកក្រងជាកណ្តប ។


លោកយាយ អ៊ូ អន ជាមួយចៅ

ប្រហែលនៅឆ្នាំ១៩៧៥ អង្គការបានតម្រូវឲ្យកូនប្រុសច្បងរបស់យាយទៅធ្វើកង-

ទ័ព ។ យាយនិយាយថា “ពេលគេហៅកូនទៅធ្វើកងទ័ព គេហៅខ្ញុំទៅប្រជុំ ។ ប្រជុំថ្ងៃហ្នឹង យើងគ្មានតវ៉ាបានមួយម៉ាត់ទេ គេថាបើយើងចង់ក៏នៅតែទៅ យើងមិនចង់ក៏នៅតែទៅ ។ គេនិយាយតែប៉ុណ្ណឹង ស្អែកឡើងគេហៅទៅ” ។

កូនរបស់យាយចូលរួមក្នុងជួរកងទ័ពបាត់ដំណឹងរហូតដល់របបខ្មែរក្រហមដួលរលំទើបឃើញត្រឡប់មកវិញជាមួយនឹងសម្លៀកបំពាក់រហែករហ៊យ ។ ចំណែកកូនផ្សេងៗទៀតចូលអង្គភាពកងចល័តតាមភេទនិងវ័យ សូម្បីតែកូនពៅដែលមានអាយុជិត ១០ឆ្នាំក៏ត្រូវចូលកងកុមារដែរ ។

ប្រហែលនៅឆ្នាំ១៩៧៦ យាយកើតបូសគ្មានមុខយ៉ាងធំនៅនឹងជើងខាងឆ្វេង រហូតត្រូវទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យស្រុក ។ កម្មាភិបាលពេទ្យទាមទារកាត់ជើងរបស់យាយ ប៉ុន្តែយាយបដិសេធដាច់អហង្ការ ។ យាយនិយាយថា “បើកាត់ទៅរស់ ហើយមិនកាត់ស្លាប់ ខ្ញុំសុខចិត្តស្លាប់ តែត្រង់ឲ្យខ្ញុំកាត់ជើង ខ្ញុំមិនកាត់ទេ” ។ បន្ទាប់ពីព្យាបាលអស់រយៈពេល៥ខែ ជំងឺរបស់យាយក៏បានធូរស្រាល ។ យាយក៏សុំចេញពីមន្ទីរពេទ្យមកនៅសហករណ៍វិញ ប៉ុន្តែមិនអាចដើរឆ្ងាយនិងធ្វើការងារធ្ងន់ៗបានទៀតឡើយ ។ ប្រធានសហករណ៍ក៏ចាត់តាំងយាយឲ្យធ្វើការងារខាងបកពោត កាច់ពោត និងជួយចិតបន្លែនៅរោងចុងភៅ ។ យាយធ្វើការងារនេះរហូតដល់ថ្ងៃដែលរបបខ្មែរក្រហមដួលរលំ ។

យាយអន បានឲ្យដឹងទៀតថា នៅក្ដមសំណ ឆ្នាំខ្លះប្រជាជនជួបប្រទះគ្រោះទុរ្ភិក្សដោយសារសត្វកណ្ដុរកាត់បំផ្លាញស្រូវ ។ ដោយសារតែមានកណ្ដុរច្រើនពេក អង្គការបានដាក់កម្រិតឲ្យប្រជាជនវាយកណ្ដុរឲ្យបានម្នាក់មួយក្នុងមួយថ្ងៃបន្ថែមពីលើការងារប្រចាំថ្ងៃ បើអ្នកណាវាយមិនបានកណ្ដុរមួយទេនឹងមិនបានទទួលរបបអាហារឡើយ ។ ឆ្នាំខ្លះទៀត ទឹកទន្លេឡើងធំបំផ្លាញស្រូវនិងដំណាំគ្រប់ប្រភេទគ្រប់ទីកន្លែងត្រូវទឹកលិចអស់ ។ អង្គការបញ្ជាឲ្យរើរោងបាយពីរ-បីបញ្ចូលគ្នាតែមួយ ហើយលើកដីជាទំនប់ទប់ការពារទឹកកុំឲ្យលិចរោងបាយ ។ ចុងភៅត្រូវអុំទូកយកបាយចែកឲ្យប្រជាជនណាដែលមិនអាចមកហូបបាយនៅរោងចុងភៅបាន ។ ឆ្នាំណាខ្វះខាតស្បៀង ប្រជាជនត្រូវហូបបាយលាយពោត បាយលាយចេកទុំ លាយដំឡូង ឬជួនកាលហូបពោតសុទ្ធតែម្ដង ។ យាយអន និយាយថា នៅក្ដមសំណសម្បូរចេកនិងដំឡូងឈើ ។ ចេកផ្លែធំៗថ្លោសៗ ដំឡូងឈើមានមើមធំៗនិងវែងៗ យកមកហាន់លាយបាយ ឬប្រើបាច់ធ្វើជាម្សៅទុកសម្រាប់ធ្វើនំបញ្ចុក ។ យាយបានឲ្យដឹងថា នៅសហករណ៍របស់យាយ អង្គការមិនសូវមានការតឹងតែងអំពីការហូបចុកទេ ទោះជាមិនបានបាយសុទ្ធក៏ដោយ ក៏ប៉ុន្តែប្រជាជនបានហូបឆ្អែតៗគ្រប់គ្នា ហើយក៏ធ្លាប់បានហូបនំបញ្ចុកឬបង្អែមម្ដងម្កាលដែរ ។ ពេលខ្លះប្រជាជនអាចសុំគ្រាប់ពោតយកមកលីងហូបបានទៀតផង ។

ក្រៅអំពីធ្វើការងារជាច្រើនម៉ោងក្នុងមួយថ្ងៃ ប្រជាជនត្រូវចូលរួមប្រជុំទៀត ។ នៅក្នុងអង្គប្រជុំប្រជាជនដឹងតែអង្គុយស្ដាប់ប៉ុណ្ណោះ ចំណែកអ្នកដែលឡើងមានយោបល់គឺប្រធានសហករណ៍និងប្រធានភូមិ ។ ប្រធានសហករណ៍គឺជាអង្គការ បើប្រធានសហករណ៍ប្រាប់ឲ្យទៅធ្វើការនៅទីណា ប្រជាជនត្រូវតែធ្វើតាម បើមិនដូច្នោះទេនឹងត្រូវស្លាប់ ។ យាយនិយាយថា “អត់មាននិយាយរឿងយើងមិនទៅទេ គេប្រាប់យើងឲ្យធ្វើអី យើងត្រូវតែទៅ បើមិនទៅគេយកយើងសម្លាប់ចោល” ។

ប្រហែលនៅឆ្នាំ១៩៧៨ មានការប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហមនិងកងទ័ពវៀតណាម ។ ពេលនោះកងទ័ពទាំងសងខាងប្រើកាំភ្លើងធំបាញ់ផ្លោងដាក់គ្នាទៅវិញទៅមកធ្វើឲ្យប្រជាជនភិតភ័យរត់ចូលពួនក្នុងលេណដ្ឋានស្ទើររាល់ថ្ងៃ ជួនកាលដាច់បាយដាច់ទឹក ទម្រាំតែស្ងប់ទើបហ៊ានចេញមកប្រកបការងារដូចធម្មតាវិញ ។ ការភិតភ័យមានកាន់តែខ្លាំងទៀតនៅចុងឆ្នាំ១៩៧៨ ។ ពេលនោះទាំងម៉ារីន ទាំងយន្តហោះទម្លាក់គ្រាប់បែក និងកងទ័ពជើងគោករបស់វៀតណាមបានវាយសម្រុកព្រមៗគ្នាធ្វើឲ្យប្រជាជនភិតភ័យតក្កមា ។ ទាំងខ្មែរក្រហម ទាំងប្រជាជននាំគ្នារត់ឡើងមកតំបន់លើៗដើម្បីគេចពីកងទ័ពវៀតណាម ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅខែមករា ឆ្នាំ១៩៧៩ ប្រជាជនបានធ្វើដំណើរត្រឡប់មកភូមិកំណើតវិញ ។ មកដល់ភូមិដំបូង យាយអន បានឃើញរណ្ដៅសាកសពរួមជាច្រើនដែលត្រូវខ្មែរក្រហមសម្លាប់មនុស្សហើយកប់មិនជិតលេចក្បាលជង្គង់និងជើងចេញមកក្រៅ និងឃើញស្នាមឈាមនៅទីកន្លែងសម្លាប់

មិនទាន់រលុបបាត់អស់នៅឡើយ ។ ពេលនោះទើបយាយនិងអ្នកភូមិទាំងអស់ដឹងថា ខ្មែរក្រហមបានយកភូមិពោធិទន្លេធ្វើជាកន្លែងសម្លាប់មនុស្ស ។ ក្រោយមករដ្ឋអំណាចមូលដ្ឋាននិងប្រជាជនបានរួមសហការគ្នាកសាងចេតិយមួយ ហើយគាស់ឆ្អឹងសាកសពដែលនៅក្នុងរណ្តៅយកមកតម្កល់នៅក្នុងចេតិយនោះ ។ នៅពេលដែលទើបនឹងមកដល់ភូមិកំណើតថ្មីៗ ជីវភាពគ្រួសាររបស់យាយ អននិងអ្នកភូមិទាំងអស់នៅមានការខ្វះខាត ប៉ុន្តែបានខិតខំធ្វើស្រែចម្ការលើដីដែលរដ្ឋអំណាចមូលដ្ឋានបានចែកឲ្យ ។ បច្ចុប្បន្ននេះនៅភូមិពោធិទន្លេ ប្រជាជនមានជីវភាពសមរម្យភាគច្រើនមានផ្ទះក្បឿងធំៗ ប៉ុន្តែឆ្នាំខ្លះភោគផលដែលបានមកមិនគ្រប់ហូបរយៈពេលមួយឆ្នាំទេ ដោយសារទឹកទន្លេលិចបំផ្លាញផលដំណាំអស់ ។ ប្រជាជនខ្លះទៅប្រកបរបរជាកម្មករស៊ីឈ្នួលនៅទីក្រុងខ្លះ ទៀតលក់ឬបញ្ចាំដីស្រែចម្ការយកដើមទុនទៅប្រកបរបរលក់ដូរផ្សេងៗ ។

យាយអន បានប្រៀបធៀបជីវភាពនាពេលបច្ចុប្បន្នទៅនឹងរបបខ្មែរក្រហមថា «ឥឡូវមិនដូចរបបប៉ុល ពត ទេ ។ ឥឡូវនេះយើងហូបសេរី ចង់ហូបអីស្រេចនឹងយើង យើងចង់សាច់ មានលុយទិញសាច់ជ្រូកក៏បាន ទិញសាច់គោក៏បាន ទិញត្រីក៏បាន យើងចង់ហូបនំអីក៏ស្រេចនឹងចិត្តយើង បើកាលនោះគេឲ្យយើងហូប ។ យើងនៅក្រោមរដ្ឋអំណាចគេ គ្មានសិទ្ធិតវ៉ានឹងគេសោះហើយ» ។

យាយធ្លាប់បាននិយាយរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមប្រាប់ចៅៗដែរ ប៉ុន្តែចៅៗរបស់យាយមិនជឿឡើយ ។ យាយនិយាយថា «ចៅៗខ្ញុំវាកើតមកឃើញតែសម្បូរសប្បាយវាអត់ជឿទេ ។ ខ្ញុំផ្តាំកូនផ្តាំចៅទុកអត់ឲ្យរបបហ្នឹងត្រឡប់មកវិញទេ លោកអើយអាណិតចៅក្រោយៗណាស់ ។ ខ្ញុំចំណាស់ណេះ វាហួសពេលហើយ មានតែកូនចៅជំនាន់ក្រោយៗខំរៀនសូត្រឲ្យចេះដឹងឡើង កុំឲ្យគេជិះជាន់ដូចជំនាន់ខ្ញុំទៀត» ។

**សាន់ កល្យាណ**

## សេចក្តីជូនដំណឹងរបស់សមាគមអ្នកនិពន្ធខ្មែរ

សមាគមអ្នកនិពន្ធខ្មែរសូមជម្រាបដល់ប្រជាជនកម្ពុជាគ្រប់រូបថា សមាគមបានរៀបចំ «**វេទិការថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ**» ក្រោមកិច្ចសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ វេទិកានេះមានគោលបំណងសំខាន់ៗដូចជា៖

- រួមជាចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់កូនចៅជំនាន់ក្រោយឲ្យបានដឹងនិងសិក្សារៀនសូត្រ ។
- ជាវិធីមួយដើម្បីរំងាប់អារម្មណ៍ដោយយកហេតុការណ៍ សេចក្តីទុក្ខ ការខឹងគុំកួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។
- ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។
- ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

សមាគមអ្នកនិពន្ធខ្មែរសូមអំពាវនាវដល់ប្រជាជនកម្ពុជាចូលរួមសរសេរអត្ថបទទាំងឡាយអំពី៖ ១) រឿងរ៉ាវផ្ទាល់ខ្លួន ២) ព្រឹត្តិការណ៍ដែលលោកអ្នកធ្លាប់បានជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង ៣) ផ្តល់ដំណោះស្រាយចំពោះបញ្ហាប្រវត្តិសាស្ត្រនេះ ។ ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។

សមាគមអ្នកនិពន្ធខ្មែរនិងមជ្ឈមណ្ឌលឯកសារកម្ពុជានឹងមានកិត្តិយសដោយចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តី «ស្វែងរកការពិត» ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ ការចូលរួមរបស់លោកអ្នកគឺជាការរួមចំណែកលើកស្ទួយតម្លៃនៃការសរសេរនិងចំណេះដឹង ។

សូមផ្ញើអត្ថបទរបស់លោកអ្នកមកសមាគមអ្នកនិពន្ធខ្មែរទីស្នាក់ការៈ វត្តបទុមវតី ភ្នំពេញ ឬទាក់ទងតាមទូរស័ព្ទលេខ ០១២ ៨៨៣ ០៧២ និង០១២ ៩៨៨ ១៧៦ ចាប់ពីថ្ងៃទី២០ ខែឧសភា រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៣ ។

**យូ ប៊ូ**
**ប្រធានសមាគមអ្នកនិពន្ធខ្មែរ**

# ការធ្វើកោសល្យវិច័យនៅលើឆ្អឹងនិងលលាដ៍ក្បាលជនរងគ្រោះ នៅក្នុងសម័យខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំអ្នកជំនាញខាងធ្វើកោសល្យវិច័យទៅលើឆ្អឹងសាកសពក្រោយឧបទ្ទវហេតុចំនួនបីរូបមកពីប្រទេសកាណាដាឲ្យមកពិនិត្យឆ្អឹងសាកសពដែលតម្កល់ក្នុងបូជនីយដ្ឋានមួយចំនួននៅក្នុងប្រទេសកម្ពុជា ។ ក្រុមជំនាញបានសិក្សាស្រាវជ្រាវនៅខេត្ត-ក្រុងចំនួន៥គឺខេត្តកំពង់ស្ពឺ ខេត្តកំពង់ចាម ខេត្តកណ្តាល ខេត្តតាកែវនិងទីក្រុងភ្នំពេញ ។ នៅខែសីហា ឆ្នាំ២០០៣ ខាងមុខនេះក្រុមជំនាញធ្វើកោសល្យវិច័យឆ្អឹងក្រោយពេលឧបទ្ទវហេតុ នឹងចុះសិក្សាស្រាវជ្រាវបន្ថែមទៀតទៅលើទីតាំងសម្លាប់មួយចំនួននិងជីករណ្តៅតាមបច្ចេកទេសដោយផ្ទាល់ទៅលើទីតាំងណាដែលពុំទាន់ទទួលរងនូវការជីកកកាយពីពេលមុនមក ។ ក្រុមអ្នកជំនាញដែលបានមកធ្វើការនៅក្នុងប្រទេសកម្ពុជា គឺមកពី “ការិយាល័យពិនិត្យសាកសពក្រោយពេលឧបទ្ទវហេតុ” ដែលមានស្នាក់ការនៅទីក្រុងតូរ៉ុនតូ ប្រទេសកាណាដានិងជាអ្នកដែលមានបទពិសោធន៍គ្រប់គ្រាន់ក្នុងការងារព្រមទាំងធ្លាប់បានចំណាយពេលធ្វើការនៅប្រទេសទីម័រខាងកើតជាច្រើនខែមកហើយដែរ ។ វេជ្ជបណ្ឌិត ម៉ៃឃើល ប៉ូឡេនេន និងបណ្ឌិត ខាធី ហ្គូស្តីយើ ជាអ្នកដែលមានជំនាញច្បាស់លាស់និងធ្លាប់មានបទពិសោធន៍ក្នុងការស៊ើបអង្កេតអំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានធ្វើដំណើរមកប្រទេសកម្ពុជាដើម្បីបំពេញការងារឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាដែលជាស្ថាប័នស្រាវជ្រាវឯករាជ្យ ក្នុងគោលបំណងប្រមែប្រមូលនូវភស្តុតាងបន្ថែមពីលើភស្តុតាងដែលមានស្រាប់ក្នុងការនាំខ្លួនមេដឹកនាំខ្មែរក្រហមទៅសាលាក្តី ដើម្បីកាត់សេចក្តីអំពីទោសកំហុសដែលបានប្រព្រឹត្តកន្លងមកក្នុងការគ្រប់គ្រងអំណាចរបស់ខ្លួនពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ និងដើម្បីស្វែងរកមូលហេតុពិតប្រាកដនៃការស្លាប់មនុស្សអស់ជាង១លាន៧សែននាក់ ។ ជាច្រើនឆ្នាំកន្លងមកនេះការស្លាប់របស់ជនរងគ្រោះហាក់គ្មានរំពឹងពីអ្នកដែលនៅរស់ថានឹងមានការស្វែងរកភាពយុត្តិធម៌មួយឡើយ ទោះបីជាមានការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងការបង្កើតតុលាការក្នុងស្រុកមួយនិងស្នើឲ្យបណ្តាខេត្ត-ក្រុងទូទាំងប្រទេសធ្វើញត្តិគាំទ្រនិងសេចក្តីថ្លែងការណ៍ពីទុក្ខសោកដែលបុគ្គលម្នាក់ៗបានទទួលកាលពីស្ថិតនៅក្រោមរបបខ្មែរក្រហមយ៉ាងណាក៏ដោយ ។ ថ្មីៗនេះ



ភាពអស់សង្ឃឹមនេះត្រូវបានជំនួសវិញដោយការបង្កើតតុលាការអន្តរជាតិមួយដើម្បីកាត់សេចក្តីទៅលើទោសកំហុសរបស់មេដឹកនាំខ្មែរក្រហម ។ នៅថ្ងៃទី៦ ខែមិថុនា

ឆ្នាំ២០០៣ ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរយៈពេលកម្ពុជាប្រជាធិបតេយ្យ បានប្រារព្ធឡើងនៅសាលសន្និសីទចតុមុខ ។

កាលពីឆ្នាំ២០០២កន្លងទៅ ក្រុមធ្វើកោសល្យវិច័យឆ្អឹងសាកសពជនរងគ្រោះសម័យខ្មែរក្រហម បានបំពេញការងាររបស់ខ្លួននៅបូជនីយដ្ឋានចំនួនពីរគឺ វត្តអំពែភ្នំ ស្ថិតនៅភូមិអំពែភ្នំ ឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ និងក្បែរជើងភ្នំអដ្ឋរស្ស ស្ថិតនៅក្នុងភូមិភ្នំ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល ។ នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៣នេះ ក្រុមការងារបានចាប់ផ្តើមធ្វើការនៅទីតាំងដដែលកាលពីឆ្នាំកន្លងទៅ និងនៅកន្លែងផ្សេងទៀតជាច្រើនកន្លែង ។ បេសកកម្មនៃការងារធ្វើកោសល្យវិច័យឆ្អឹងសាកសពជនរងគ្រោះសម័យខ្មែរក្រហម មានរយៈពេល១០ថ្ងៃដំបូង (ពីថ្ងៃទី១៤ ដល់ថ្ងៃទី២៤ ខែមិថុនា) ក្នុងនោះខេត្ត-ក្រុងចំនួន៥បានក្លាយជាគោលដៅនៃការសម្រេចចិត្តរបស់ក្រុមការងារ ។ យោងតាមលទ្ធផលដែលទទួលបានពីការសិក្សាទៅលើឆ្អឹងសាកសពនៅខេត្ត-ក្រុងដែលបានអធិប្បាយខាងលើ និងយោងតាមរបាយការណ៍ដែលបានមកពីការស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាលើទីតាំងប្រល័យពូជសាសន៍នៅទូទាំងប្រទេសកម្ពុជា បានបញ្ជាក់ឲ្យឃើញអំពីការសម្លាប់រង្គាលរបស់ខ្មែរក្រហមតាមរយៈនៃការធ្វើទារុណកម្មដែលមានលក្ខណៈជាប្រពន្ធ័និងមានបែបផែនស្រដៀងៗគ្នាពីខេត្តមួយទៅខេត្តមួយ ។ នៅខេត្តកំពង់ស្ពឺនិងខេត្តកណ្តាលតាមរយៈការពិនិត្យយ៉ាងយកចិត្តទុកដាក់ទៅលើលលាដ៍ក្បាលនិងឆ្អឹងដងខ្លួនរបស់សាកសព បង្ហាញថា ជនរងគ្រោះបានទទួលរងនូវការកាប់កែងជើងនឹងកាំបិត កាប់ក្បាលនឹងកាំបិតបូថៅ និងទទួលរងការបាញ់នឹងកាំភ្លើង ។ នៅខេត្តតាកែវនិងខេត្តកំពង់ចាម ការពិនិត្យបានបញ្ជាក់ថា ជនរងគ្រោះត្រូវសម្លាប់ស្រដៀងគ្នានឹងការសម្លាប់នៅខេត្តកណ្តាលនិងកំពង់ស្ពឺដែរ ។ ឧទាហរណ៍ នៅនឹងបូជនីយដ្ឋានវត្តសូភី ហៅកកោះ ស្ថិតនៅក្នុងស្រុកបាទី ខេត្តតាកែវ មានលលាដ៍ក្បាលជាច្រើនដែលត្រូវបានរើយកមកដាក់តម្រៀបនៅប៉ែកខាងក្រៅបូជនីយដ្ឋាន ដើម្បីត្រៀមពិនិត្យពីក្រុមធ្វើកោសល្យវិច័យឆ្អឹង ។ ជាលទ្ធផល លលាដ៍ក្បាលខ្លះបានទទួលរងការបាញ់នឹងគ្រាប់កាំភ្លើង (ព្រោះឃើញមានស្នាកស្នាមទម្លុះលលាដ៍ក្បាល) ខ្លះទៀតទទួលរងនឹងការប៉ះទង្គិចនឹងវត្ថុផ្សេងៗ (ស្នាមផុងនៅនឹងលលាដ៍ក្បាលប៉ែកខាងក្រោយ) និងខ្លះទៀតទទួលរងការកាប់នឹងកាំបិតបូថៅ (ស្នាមកាំបិតបានកាត់ផ្តាច់ផ្នែកខ្លះនៃលលាដ៍ក្បាល) ។ ក្នុងចំណោមនោះ អ្នកជំនាញខាងកោសល្យវិច័យបានអធិប្បាយអំពីប្រភេទមនុស្សដែលបានសម្លាប់ដោយខ្មែរក្រហមថា មានទាំងស្រី ប្រុស ចាស់ និងក្មេង ។ នៅវត្តស្តុន់និងវត្តនគរក្នុងខេត្តកំពង់ចាម ដែលមានការដាក់តម្កល់អដ្ឋិធាតុចំនួនច្រើននោះ ក៏ត្រូវបានក្រុមធ្វើកោសល្យវិច័យឆ្អឹងចុះទៅពិនិត្យដែរ ប៉ុន្តែរយៈពេលនៃការពិនិត្យមិនបានយូរឡើយ ដោយសារតែបូជនីយដ្ឋានទាំងពីរពុំមានការថែរក្សាត្រឹមត្រូវ ។ ឆ្អឹងស្ទើរតែទាំងអស់ត្រូវពុកផុយ និងបាក់ជាកំណាត់ៗ ។ មានឆ្អឹងតែមួយចំនួនតូចប៉ុណ្ណោះដែលអាចពិនិត្យបាន ។ នៅខេត្តកំពង់ចាមដដែលនេះ ការធ្វើដំណើរតាមផ្លូវទឹកឆ្ពោះទៅកាន់ទីតាំងសម្លាប់"ទ្រាពីរ" និង "កោះផល" បានធ្វើឡើងក្នុងគោលបំណងជីករណ្តៅដែលពុំទាន់បានគាស់ ។ ប៉ុន្តែក្រុមការងារត្រូវត្រឡប់មកក្រោយវិញ ដោយសាររណ្តៅទាំងអស់ត្រូវបានគាស់ និងខ្លះទៀតបាក់ស្រុតចូលទៅក្នុងទន្លេមេគង្គ ។

នៅប៉ុន្មានថ្ងៃចុងក្រោយមុននឹងបញ្ចប់អាណត្តិការងារធ្វើកោសល្យវិច័យឆ្អឹងនៅខែមិថុនា ក្រុមការងារបានអនុវត្តកិច្ចការពិនិត្យយ៉ាងយកចិត្តទុកដាក់ទៅលើឆ្អឹងនិងលលាដ៏ក្បាលចំនួនពីរទូដែលដាក់តម្កល់នៅក្នុងបន្ទប់មួយនៃសារមន្ទីរទួលស្លែង ។ រាល់ការពិនិត្យទៅលើឆ្អឹងឬលលាដ៍ក្បាលនីមួយៗ ចាំបាច់ក្រុមការងារត្រូវការពិភាក្សាគ្នា ថតរូប និងពិនិត្យពិច័យបំផុតទៅលើស្នាកស្នាមដែលបានបន្សល់ពីការធ្វើទារុណកម្មរបស់ខ្មែរក្រហម ដូចជាស្នាមកាប់នឹងកាំបិតឬស្នាមបាញ់នឹងគ្រាប់កាំភ្លើងជាដើម ។ ក្រោយការធ្វើកោសល្យវិច័យនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង (អតីតមន្ទីរស-២១) ក្រុមការងារបានស្រាវជ្រាវរកឃើញនូវភាពស្រដៀងគ្នានៃការធ្វើទារុណកម្មរបស់ខ្មែរក្រហមទៅនឹងខេត្តទាំង៤ ដែលបានស្រាវជ្រាវ

កន្លងមក ។ ការចង់ដឹងកាន់តែខ្លាំងនិងការស្វែងយល់កាន់តែច្បាស់ថែមទៀតអំពីរបបខ្មែរក្រហម បានជំរុញឲ្យក្រុមការងារកោសល្យវិច័យឆ្អឹងនិងមជ្ឈមណ្ឌលឯកសារកម្ពុជា កាន់តែខិតចូលទៅរកដំណោះស្រាយដ៏ប្រពៃមួយសម្រាប់ជនរងគ្រោះទូទាំងប្រទេស ។ នោះគឺ "ការទាមទារយុត្តិធម៌" ដែលជាការរំពឹងដ៏យូរអង្វែងមកហើយ ពីសាច់ញាតិបងប្អូនរបស់ជនរងគ្រោះដែលបានបាត់បង់ជីវិត ។ ក្រៅពីនេះ ការងារធ្វើកោសល្យវិច័យទៅលើឆ្អឹងនិងលលាដ៍ក្បាលជនរងគ្រោះនៅព្រះរាជាណាចក្រកម្ពុជា បានក្លាយទៅជាប្រធានបទមួយយ៉ាងសំខាន់សម្រាប់ការសិក្សាស្វែងយល់ទាំងផ្នែកសារពត៌មាន អ្នកច្បាប់ អ្នកទេសចរណ៍និងបណ្ឌិតនិស្សិតទាំងឡាយ ជាពិសេសនិស្សិតដែលសិក្សាលើមុខវិជ្ជាពេទ្យនិងនរវិទ្យា ។

មានលលាដ៍ក្បាលចំនួន១៥ដែលបានស្នើសុំយកមកពីបណ្ដាបូជនីយដ្ឋានមួយចំនួនក្នុងខេត្ត-ក្រុងខាងលើ មកតម្កល់ទុកនៅក្នុងសារមន្ទីរក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដើម្បីរក្សាទុកជាភស្តុតាងមួយក្នុងចំណោមភស្តុតាងនានាដែលមានស្រាប់ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានគម្រោងដាក់បង្ហាញដល់ភ្ញៀវជាតិនិងអន្តរជាតិ នូវលលាដ៍ក្បាលដែលបានពិនិត្យរួចជាមួយនឹងការអធិប្បាយយ៉ាងលម្អិតពីហេតុការណ៍ដែលបានកើតមានកន្លងមក ។

នៅខែសីហា ឆ្នាំ២០០៣ ខាងមុខនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងចូលរួមយ៉ាងសកម្មជាថ្មីម្ដងទៀត ជាមួយក្រុមអ្នកជំនាញខាងកោសល្យវិច័យឆ្អឹង ដើម្បីធ្វើដំណើរទៅខេត្តមួយចំនួនដែលនឹងសម្រេចនាពេលបន្ទាប់ ។ ដំណើរការការងារលើកក្រោយនេះ នឹងផ្ដោតសំខាន់ទៅលើការជីករណ្ដៅសាកសពដែលពុំទាន់មានការជីកគាស់ ព្រោះបច្ចេកទេសនៃការធ្វើកោសល្យវិច័យទៅលើឆ្អឹងសាកសព ត្រូវប្រព្រឹត្តទៅតាមលក្ខណៈដើមនៃរាងកាយសាកសពបន្ទាប់ពីបានជួបឧបទ្ទវហេតុ ។ **ផេង ពងរ៉ាស៊ី**


វេជ្ជបណ្ឌិត ម៉ៃឃើល ប៉ូឡេនេន កំពុងពិនិត្យលលាដ៍ក្បាលសាកសព នៅវត្តសូទី ខែមិថុនា ឆ្នាំ២០០៣ ។

# មរតកក្រោយសង្គ្រាម

របបកម្ពុជាប្រជាធិបតេយ្យបានបន្សល់ទុកនូវការឈឺចាប់ជាច្រើនដល់ស្ត្រីកម្ពុជា ។ ទោះបីជាបច្ចុប្បន្ន សិទ្ធិមនុស្សបានបើកទូលាយឲ្យមនុស្សអាចនិយាយការពិតក៏ដោយ ប្រពៃណីខ្មែរនៅតែមានឥទ្ធិពលខ្លាំងដែលមិនអាចធ្វើឲ្យស្ត្រីនិយាយអំពីរឿងរ៉ាវពិតរបស់ខ្លួនប្រាប់អ្នកដទៃ ។ ស្ត្រីជាច្រើនពាន់នាក់បានបាត់បង់ជីវិតដោយការធ្វើពលិកម្មដើម្បីបុព្វហេតុបដិវត្តន៍និងមួយចំនួនទៀតត្រូវសម្លាប់និងបង្ខំឲ្យធ្វើពលកម្មជាទម្ងន់ ។ ស្ត្រីខ្លះត្រូវស្លាប់ដោយសារអត់អាហារនិងស្ត្រីខ្លះទៀតត្រូវស្លាប់ដោយការរំលោភ ។ ស្ត្រីដែលបានរស់រានមានជីវិតពីរបបនេះមួយភាគធំបានក្លាយជាស្ត្រីមេម៉ាយទទួលបន្ទុកដ៏ធ្ងន់ក្នុងការចិញ្ចឹមបីបាច់កូនៗ ។

ស្ត្រីមួយចំនួនទទួលការឈឺចាប់ធ្ងន់ធ្ងរហួសប្រមាណ ។ ការឈឺចាប់ដែលមិនហ៊ានបង្ហាញបែបនេះអាចធ្វើឲ្យស្ត្រីជួបប្រទះវិបត្តិផ្លូវចិត្តធ្ងន់ធ្ងរ ។ ថ្វីដ្បិតតែរបបកម្ពុជាប្រជាធិបតេយ្យបានកន្លងផុតអស់ជាច្រើនឆ្នាំហើយក៏ដោយ ក៏ស្ត្រីកម្ពុជានៅតែមិនអាចព្យាបាលជំងឺផ្លូវចិត្តពីរបបអតីតកាលបានជ្រះស្រឡះនៅឡើយ ។ រឿងរ៉ាវឈឺចាប់ទាំងនេះជាមរតកមួយដែលខ្មែរក្រហមបានបន្សល់ទុករហូតមកដល់សង្គមបច្ចុប្បន្ន ។

ក្រោយឆ្នាំ១៩៧៩ ស្ត្រីកម្ពុជាស្ទើរតែ៨០ភាគរយបានក្លាយជាស្ត្រីមេម៉ាយនិងមានកាតព្វកិច្ចចិញ្ចឹមកូនៗ ។

សំរិត យី នៅឃុំជើងកើប ស្រុកកណ្តាលស្ទឹង បាននិយាយថាគាត់ក្លាយជាស្ត្រីមេម៉ាយនៅឆ្នាំ១៩៧៦ នៅពេលដែលខ្មែរក្រហមចាប់ប្តីរបស់គាត់យកទៅសម្លាប់នៅខាងក្រោយភូមិដោយដឹងថាប្តីរបស់គាត់ជាអតីតពេទ្យនៃរបប លន់ ណុល ។ យី និយាយថា កាលពីសម័យដើមគាត់មិនបានចូលរៀនដូចក្មេងៗដទៃទៀតឡើយ (គាត់បានរៀបការជាមួយគ្រូពេទ្យម្នាក់នៅពេលដែលគាត់មានអាយុ១៦ឆ្នាំ) ។ ក្រោយឆ្នាំ១៩៧៩ គាត់បាននាំកូនទាំង៦នាក់ត្រឡប់មកស្រុកកំណើតវិញដើម្បីធ្វើស្រែចិញ្ចឹមជីវិតនៅក្នុងក្រុមសាមគ្គី ។ ការធ្វើស្រែបែបក្រុមសាមគ្គីធ្វើឲ្យជីវភាពរបស់គាត់មានការខ្វះខាត ។ គាត់មិនសូវបានគិតគូរពីការរៀនសូត្ររបស់កូនៗទេ ។ ម្យ៉ាងដោយខ្លួនគាត់មិនចេះអក្សរស្រាប់ផង ម្យ៉ាងទៀតដោយសារតែជីវភាពយ៉ាប់យ៉ឺន គាត់បានសម្រេចចិត្តឲ្យកូនស្រីពីរនាក់ឈប់រៀន ចំណែកឯកូនប្រុសៗវិញកាន់តែមិនបានចូលសាលាទៅទៀត ព្រោះតែត្រូវរត់គេចពីកំណែនកងទ័ព ។ យី មានការពិបាកចិត្តខ្លាំងណាស់ ណាមួយបញ្ហាជីវភាព ណាមួយបញ្ហាកូនដែលត្រូវរត់គេចពីកន្លែងមួយទៅកន្លែងមួយ មួយទៀតបញ្ហាជំងឺប្រចាំកាយ ។ យី និយាយថាបច្ចុប្បន្នគាត់មានជីវភាពធូរស្រាលជាងមុនបន្តិច ប៉ុន្តែគាត់នៅតែមានវិប្បដិសារី ពីព្រោះកូនៗរបស់គាត់ទាំងអស់រៀនពុំបានជ្រៅជ្រះបានត្រឹមតែមើលអក្សរខ្មែររួច ហើយមានកូនខ្លះសេពគប់ជាមួយមិត្តភក្តិមិនល្អ ដើរផឹកស្រាស្រែកឡូឡា ។ យី ត្អូញត្អែរថាកាលពីសង្គមចាស់គាត់មិនដែលស្គាល់អ្វីដែលលំបាកនិងអត់ឃ្លានឡើយ ។ ប្រសិនបើប្តីរបស់គាត់នៅរស់រានមានជីវិតវិញ កូនៗរបស់គាត់មិនវេទនាដូចសព្វថ្ងៃនេះទេ ។ ។

អាង រស់នៅក្នុងជំរំស្ត្រីមេម៉ាយនៅវត្តភ្នូន ឃុំថ្មី ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ត្រូវអង្គការចាប់សម្លាប់ទាំងយប់កណ្តាលអធ្រាត្រដោយចោទពីបទខុសសីលធម៌ជាមួយបុរសមូលដ្ឋានម្នាក់ ។

ដៃ វ៉ែន នៅឃុំធ្លក ស្រុកស្អាង ត្រូវអង្គការបង្ខំឲ្យរៀបការជាមួយបុរសម្នាក់អាយុប្រហែល៥០ឆ្នាំ បន្ទាប់ពីអង្គការចាប់ប្តីរបស់គាត់យកទៅសម្លាប់ ។ ដៃ វ៉ែន បានបដិសេធសំណើរបស់អង្គការ ។ គាត់ក៏ត្រូវខ្មែរក្រហមចាប់អូស ហើយចងដៃទៅខាងក្រោយខ្នង ។ បន្ទាប់មក អង្គការបានយកគាត់


ឡូ ស៊ីម

ទៅដាក់គុកនៅភ្នំកូនខ្វែងដើម្បីសួរចម្លើយនិងបង្ខំឲ្យធ្វើការឆ្ងាយពីកូនតូចៗរបស់គាត់ ។

ឡូ ស៊ីម បច្ចុប្បន្ននៅភូមិប្រធាតុ ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល និយាយថា គាត់ត្រូវអង្គការខ្មែរក្រហមបង្ខំឲ្យចូលធ្វើយុទ្ធនារីនៅសមរភូមិមុខ ទោះបីជាម្តាយរបស់គាត់និងគាត់យំអង្វរយ៉ាងណាក៏អង្គការមិនអនុគ្រោះដែរ ។ ក្រោយពីជ័យជម្នះ ១៧មេសា ឡូ ស៊ីម ត្រូវអង្គការបញ្ជូនមកគុកព្រៃសជាមួយនារីជាច្រើននាក់ទៀត ។ គាត់និងស្ត្រីនៅគុកព្រៃសបានឃើញឡានរបស់អង្គការមកដឹកនារីជាច្រើននាក់យកទៅសម្លាប់ ។ រយៈពេលពី៣ឬ៤ថ្ងៃ គាត់ត្រូវធ្វើប្រវត្តិរូបអំពីជំហរសតិអារម្មណ៍របស់គាត់ជូនអង្គការម្តង ។ ស្ត្រីជាច្រើនដែលនៅក្នុងកងជាមួយ ឡូ ស៊ីម ត្រូវអង្គការចាប់សម្លាប់ ។ ឡូ ស៊ីម ត្រូវប្រធានកងនារីឈ្មោះ តាំង យ៉េង បង្ខំឲ្យធ្វើកោអូសនង្គ័ល ។ ក្នុងមួយយប់គាត់និងអ្នកទោសដទៃទៀតសម្រាកបានតែ២ឬ៣ម៉ោងប៉ុណ្ណោះ ។ ឆ្នាំ១៩៧៨ ឡូ ស៊ីម ត្រូវអង្គការតាមចាប់យកទៅសម្លាប់ ព្រោះតែបដិសេធមិនព្រមការរៀបការ ។ ថ្ងៃ៧មករា ឆ្នាំ១៩៧៩ បានមកដល់ គាត់ក៏រួចខ្លួនពីការសម្លាប់ ។ ប៉ុន្តែបងប្អូនសាច់ញាតិរបស់គាត់ជាង១០នាក់ត្រូវបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។

ឡូ ស៊ីម និយាយថា គាត់ចង់បំភ្លេចរឿងរ៉ាវទាំងអស់ដែលកើតឡើងចំពោះរូបគាត់ខ្លាំងណាស់ ប៉ុន្តែវានៅតែស្ថិតនៅក្នុងអារម្មណ៍គាត់ជានិច្ច ។ តាមការវិភាគរបស់វេជ្ជបណ្ឌិតនៃកម្មវិធីសុខភាពផ្លូវចិត្តសហគមន៍ ដែលធ្លាប់បានព្យាបាលរោគរបស់ ឡូ ស៊ីម បានឲ្យដឹងថា ឡូ ស៊ីម មានជំងឺផ្លូវចិត្តដោយសារតែការភ័យរន្ធត់ពីរបបអតីតកាល ហើយគាត់ត្រូវតែទទួលការព្យាបាលពីអ្នកជំនាញខាងផ្នែកចិត្តសាស្ត្រយ៉ាងយកចិត្តទុកដាក់បំផុត ។

រុន នៅស្រុកត្រាំកក់ ត្រូវកងសន្តិសុខគុកក្រាំងតាចាន់ឈ្មោះ ឌុច ចាប់រំលោភ ។ រុន គ្មានភាពលទ្ធភាពតតាំងនឹងអំពើឃោរឃៅនេះបានឡើយ ។ បច្ចុប្បន្ន រុន នៅតែនឹកឃើញ និងមិនអាចបំភ្លេចនូវរូបភាពព្រៃផ្សៃនេះ ព្រោះឧក្រិដ្ឋជនដែលប្រព្រឹត្តអំពើឃោរឃៅមកលើគាត់ ។

សុភាព ជាបុគ្គលិករាជការម្នាក់ បម្រើការនៅក្រសួងឃោសនាការព័ត៌មានវប្បធម៌ បាននិយាយថា បងស្រីរបស់គាត់ឈ្មោះ វួចនី និងនារី១៩នាក់ទៀត នៅឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម ត្រូវអង្គការបង្ខំឲ្យរៀបការជាមួយយោធាពិការ ។ ដោយសារការបដិសេធមិនព្រមរៀបការ វួចនី និងនារីទាំង១៩នាក់ ត្រូវអង្គការចាប់យកទៅដាក់គុកជាមួយគ្នា ។ ក្រោយពេលចេញពីគុក វួចនី បានធ្វើអត្តឃាតដោយលេបគ្រាប់ស្វែង ។ ចំណែកឯនារីទាំង១៩នាក់ត្រូវអង្គការចាប់យកទៅរំលោភនិងសម្លាប់យ៉ាងព្រៃផ្សៃ ។

នួន ផុក នៅខេត្តសៀមរាប បានបដិសេធមិនព្រមរៀបការជាមួយយុទ្ធជនពិការ ក៏ត្រូវអង្គការចាប់ដាក់គុកនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរដែរ ។

ប៊ុន ហ៊ាង នៅភូមិដីឆ្នែង ស្រុកស្អាង ខេត្តកណ្តាល បាននិយាយថា ខ្មែរក្រហមខ្លួនឯងមិនដែលប្រតិបត្តិតាមនយោបាយរបស់ខ្លួនឡើយ ។ នៅយប់មួយកងទ័ពខ្មែរក្រហមជាច្រើននាក់បានដើរពាសពេញភូមិ ចាប់នារីក្មេងៗយកទៅរំលោភ ។

ប៉ុល សេប បានឲ្យដឹងថា យុទ្ធជនសម័យខ្មែរក្រហមមានសិទ្ធិក្នុងការជ្រើសរើសរកនារីណាស្អាតៗដើម្បីរៀបការ ។ សេប បានបន្ថែមថា ដូចជារូបគាត់ជាដើម បានចំណាយពេលមួយសប្តាហ៍ដើម្បីដើររើសប្រពន្ធក្នុងខេត្តកំពង់ឆ្នាំង ។ ទម្រាំរកបានប្រពន្ធម្នាក់ គាត់បានដើររកនារីគ្រប់មន្ទីរទាំងអស់ ។ សេប បានឲ្យដឹងទៀតថា សូម្បីតែយុទ្ធជនពិការក៏អង្គការដឹកទាំងឡានៗទៅចម្ការក្រូច ខេត្តកំពង់ស្ពឺ ដើម្បីឲ្យទៅរើសប្រពន្ធដែរ ។ នារីដែលយុទ្ធជនពិការជ្រើសរើសនោះ សុទ្ធតែនារីទើបពេញវ័យ ។



ជល់ ស៊ីន

ជល់ ស៊ីន និយាយថា ឆ្នាំ១៩៧៨ អង្គការបានបង្ខំនារីពេទ្យ ៦មករា ក្រុងភ្នំពេញ ចំនួន២៥នាក់ ឲ្យរៀបការជាមួយជនពិការដៃពិការជើងនិងពិការភ្នែកនៅសំឡូត ខេត្តបាត់ដំបង ។ ស៊ីន ផ្ទាល់ក៏ត្រូវបង្ខំឲ្យចូលរួមក្នុងការរៀបការនេះដែរ ។ គាត់មិនហ៊ានជំទាស់នឹងបំណងរបស់អង្គការឡើយ ព្រោះខ្លាចអង្គការសម្លាប់ចោល ។

នៅក្នុងសៀវភៅ "អ្នកទោសខ្មែរក្រហម"ដែលជាស្នាព្រះហស្តរបស់សម្តេច ព្រះនរោត្តម សីហនុ, ខៀវ សំផន បានបញ្ជាក់យ៉ាងច្បាស់ថា អង្គការមិនបង្ខំឲ្យនារីរៀបការជាមួយយុទ្ធជនពិការទេ គឺយុវនារីទាំងនោះមាន "ស្មារតីស្នេហាជាតិខ្ពង់ខ្ពស់ ពួកគេបានយល់ព្រមគិតគូរពីសុខុមាលភាពវីរបុរសទាំងឡាយដែលស៊ូស្លាប់ខ្លួនដើម្បីប្រទេសជាតិ" ។ តាមការសិក្សាស្រាវជ្រាវបានបញ្ជាក់ថា សម្តីរបស់ ខៀវ សំផន គឺមិនមែនជាការពិតឡើយ ។ គ្មាននារីក្មេងៗណាម្នាក់ពេញចិត្តនឹងប្តីពិការនោះទេ ។ នារី យល់ព្រមរៀបការជាមួយជនពិការទាំងបង្ខំចិត្ត ព្រោះខ្លាចអង្គការចាប់យកទៅសម្លាប់ ។

ផាត់ សមុទ្រ និយាយថា វ័យកុមារជាវ័យដែលត្រូវការសិក្សា ប៉ុន្តែគាត់រៀនសូត្រពុំបានជ្រៅជ្រះទេ គាត់រៀនបានត្រឹមតែថ្នាក់ទី១០ប៉ុណ្ណោះ ។ បច្ចុប្បន្នគាត់មិនចេះអាននិងសរសេរទេ ។ នៅពេលដែលគាត់មានអាយុ១២ឆ្នាំ គាត់ត្រូវអង្គការចុចឈ្មោះឲ្យចូលកងកុមារ ។ នៅក្នុងកងកុមារ គាត់ទទួលរងនូវការធ្វើបាបយ៉ាងខ្លាំងពីសំណាក់ប្រធានកងកុមារ ដោយបង្ខំឲ្យធ្វើពលកម្មជាទម្ងន់ ហើយត្រូវប្រធានកងបង្ខំឲ្យងើបនៅម៉ោង៣យប់ដើម្បីត្រៀមធ្វើពលកម្ម ។ ម៉ោង១១កន្លះព្រឹក ទើបកុមារបានឈប់សម្រាកហូបបាយ ហើយម៉ោង១រសៀលចាប់ផ្តើមធ្វើពលកម្មរហូតដល់ម៉ោង៦ល្ងាច ។ គាត់និងក្មេងរាប់ពាន់នាក់ទៀតត្រូវអង្គការបញ្ជូនឲ្យមកនៅមន្ទីរក៥និងទីក្រុងភ្នំពេញ ។ បច្ចុប្បន្ន ផាត់ សមុទ្រ ស្នាក់អាស្រ័យនៅក្នុងខ្ទមតូចមួយដែលសង់លើដីអ្នកជិតខាង គ្មានបងប្អូនសាច់ញាតិជាទីពំនាក់ទេ ជីវភាពស្ថិតនៅក្នុងសភាពក្រតោកយ៉ាក រកព្រឹកខ្វះល្ងាច ។ គាត់គ្មានសមត្ថភាពនឹងរកការងារដើម្បីចិញ្ចឹមជីវិតឡើយ ។ មរតកដែលគាត់ទទួលបានពីរបបខ្មែរក្រហម គឺបានត្រឹមតែឈឺចាប់ដោយសារការនិរាសព្រាត់ប្រាសបងប្អូន និងមានរោគប្រចាំកាយប៉ុណ្ណោះ ។

ងិន ហាន អតីតនារីពេទ្យស្រុកត្រាំកក់ បានចូលបម្រើបដិវត្តន៍ដើម្បីតស៊ូរំដោះជាតិ រំដោះវណ្ណៈតាំងពីឆ្នាំ១៩៧១ ។ ហាន ខកចិត្តយ៉ាងខ្លាំងចំពោះជីវិតបដិវត្តន៍របស់គាត់ ។ គាត់មិននឹកស្មានថាទីបំផុតគាត់បានទទួលលទ្ធផលជាអ្នកទោសនៅគុកក្រាំងតាចាន់ឡើយ ។ ហាន និយាយទាំងកំហឹងថា "បើតាមចិត្តខ្ញុំចង់តែសងឈាម ប៉ុន្តែគិតសព្វគ្រប់ទៅខ្ជិល ព្រោះអ្នកណាធ្វើល្អជួបល្អ ធ្វើអាក្រក់ជួបអាក្រក់ អ្នកណាសាងអីទទួលផលហ្នឹងតាមផលកម្មព្រេងវាសនា" ។

សព្វថ្ងៃ ហាន រស់នៅជាមួយកូនស្រីៗក្នុងផ្ទះតូចមួយសង់ផុតពីដីស្ថិតនៅក្បែរវាលស្រែ ។ ប្តីដែលអង្គការរៀបការឲ្យបានលែងលះជាមួយមីងហើយរៀបការប្រពន្ធមួយទៀត ។ កូនៗរបស់គាត់បានឈប់ពីការសិក្សាមកជួយធ្វើស្រែដើម្បីចិញ្ចឹមជីវិត ។

អំពើហិង្សា ការរំលោភបំពានផ្លូវកាយផ្លូវចិត្ត ការកាប់សម្លាប់និងការគុំកួន នៅតែមានដក់ជាប់ក្នុងអារម្មណ៍ស្ត្រីខ្មែរជាច្រើនរហូតដល់បច្ចុប្បន្ន ។

បច្ចុប្បន្នស្ត្រីជនរងគ្រោះនៅតែសង្ឃឹមនិងរង់ចាំជានិច្ចក្នុងការកាត់មេដឹកនាំខ្មែរក្រហម ដើម្បីផ្តល់ភាពយុត្តិធម៌ចំពោះខ្លួន ។ ប្រសិនបើឧក្រិដ្ឋជនបានរួចផុតពីការដាក់ទោសនោះ ស្ត្រីដែលជាជនរងគ្រោះគឺពិតជាមិនស្ងប់ចិត្តឡើយ ។

**វ៉អែម សុខឃីម**

# សំណល់បដិវត្តន៍

ស្រុកកោះធំជាស្រុកមួយស្ថិតនៅតាមបណ្តោយដងទន្លេបាសាក់នៅក្នុងខេត្តកណ្តាល មានព្រំប្រទល់មួយផ្នែកជាប់នឹងប្រទេសវៀតណាម ។ បន្ទាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ស្ទើរតែគ្រប់ភូមិទាំងអស់នៅក្នុងស្រុកកោះធំ បានធ្លាក់នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ដែលកាលនោះមានឈ្មោះថា ខ្មែររំដោះ ។ ភូមិពោធិ៍រាមា ជាភូមិមួយស្ថិតនៅក្នុងឃុំព្រែកស្តីស្រុកកោះធំ ។ ក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានទៅជួបជាមួយ ម៉ាក ទក រួមនិងកូនស្រីបីនាក់និងកូនប្រុសម្នាក់ ។ ប្រពន្ធរបស់គាត់ទើបតែនឹងស្លាប់កាលបីឆ្នាំមុន ដោយសារជំងឺមហារីកសួត ។ សព្វថ្ងៃ ទក រស់នៅដោយពឹងផ្អែកលើដីស្រែដែលមានទំហំតូច មិនសមាមាត្រនឹងចំនួនសមាជិកគ្រួសារគាត់ឡើយ ។ គាត់និយាយថា គាត់បានមករស់នៅទីនេះក្រោយពេលដែលគាត់រៀបការ និងដោយសារទីនេះជាផ្ទះកំណើតរបស់ប្រពន្ធគាត់ ។ បន្ទាប់ពីប្រពន្ធរបស់គាត់ស្លាប់ទៅ គាត់មានគំនិតនាំកូនៗទៅរស់ឯភូមិកំណើតរបស់គាត់វិញ ព្រោះនៅទីនេះគាត់មិនសូវមានញាតិពឹងពាក់ ហើយក៏គ្មានដីសម្រាប់ធ្វើផ្ទះដែរ ។ នៅឯស្រុកកំណើត គាត់មានដីមួយកន្លែងតូច ប៉ុន្តែគាត់មិនទាន់មានលុយគ្រប់គ្រាន់ដើម្បីធ្វើផ្ទះនៅឡើយទេ ។

ម៉ាក ទក កើតនៅក្នុងឆ្នាំជូត (ត្រូវនឹងឆ្នាំ១៩៦០) នៅក្នុងភូមិព្រែកតាមេម ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល ចម្ងាយប្រមាណតែបីបួនគីឡូម៉ែត្រប៉ុណ្ណោះពីផ្ទះរបស់គាត់បច្ចុប្បន្ន ។ ឪពុករបស់គាត់ឈ្មោះ នូ ម៉ាក ម្តាយឈ្មោះ ស្រុត អ៊ុត ស្លាប់តាំងពីឆ្នាំ១៩៧២ ។ បើតាមឯកសារប្រវត្តិរូបរបស់ ម៉ាក ទក ដែលធ្វើឡើងនៅក្នុងរបប ប៉ុល ពត បានសរសេរថា គាត់បានចូលធ្វើបដិវត្តនៅថ្ងៃ១៣ ខែ១ ឆ្នាំ១៩៧៣ អ្នកនាំចូលឈ្មោះ ខៀន ។ កាលនោះ ស្រុកកោះធំត្រូវបានប្តូរទៅជាស្រុក១៨ ហើយខេត្តកណ្តាលក៏ត្រូវខ្មែរក្រហមប្រែទៅជាតំបន់២៥វិញ ។ តាមសម្តីរបស់ ម៉ាក ទក បានប្រាប់ថា គាត់ចេញទៅធ្វើបដិវត្តដំបូងនៅខែកក្កដា ឆ្នាំ១៩៧២ ពេលនោះ គាត់ទើបតែមានអាយុ១៦-១៧ប៉ុណ្ណោះ ។ ការចូលបម្រើបដិវត្តន៍នេះដោយសារតែប្រធានភូមិឈ្មោះ ឡឹម ឃោសនាថា ឲ្យចូលទៅធ្វើទ័ព ដើម្បីរំដោះជាតិចេញពីពួក លន់ ណុល ។ គាត់បានបញ្ជាក់ថា “កាលហ្នឹងអត់មាននរណាបង្ខំទេ គឺទៅដោយស្ម័គ្រចិត្ត ។ ទាំងខ្ញុំ ទាំងគេចង់បានសម្តេចឪមកវិញ” ។

នៅក្នុងភូមិព្រែកតាមេម មានតែ ម៉ាក ទក ម្នាក់គត់ដែលចូលបម្រើបដិវត្តន៍ ។ ពេលនោះម្តាយឪពុករបស់គាត់មិនបានហាមឃាត់គាត់ទេ ថែមទាំងពេញចិត្តឲ្យគាត់ទៅទៀតផង ។ ម៉ាក ទក ចូលទៅមុនដំបូង គឺធ្វើជាយុទ្ធជននៅក្នុងអង្គភាពទ័ពស្រុកកោះធំ ក្រោមការដឹកនាំរបស់ តាកាត មានឋានៈជាប្រធានកងទ័ពស្រុក ។ អង្គភាពនេះមានទីតាំងនៅភូមិខ្ពប ឃុំសំពៅពូនស្រុកកោះធំ ចំណុះឲ្យតំបន់២៥ ។ នៅទីនោះ គាត់មានតួនាទីយាមការពារខ្សាចក្រែងមានជនជាតិវៀតណាមឡើងមករត់ពន្ធទំនិញ ។ នៅក្នុងអង្គភាពបានមួយឆ្នាំ គាត់ក៏មកលេងផ្ទះ ។ ពេលមកដល់ផ្ទះគាត់បែរជាមិនចង់ត្រឡប់ទៅវិញ គាត់ថា “ខ្ជិលទៅវិញ ចង់នៅធ្វើស្រែ កាលហ្នឹងនៅក្នុងភូមិគេរៀបចំក្រុមតូចធ្វើស្រែ” ។

នៅក្នុងខែកក្កដា ឆ្នាំ១៩៧៣ ម៉ាក ទក បានចូលទៅក្នុងជួរបដិវត្តន៍ម្តងទៀតខណៈដែលយន្តហោះរបស់អាមេរិក និង កងទ័ពវៀតណាមខាងត្បូងបានទម្លាក់គ្រាប់បេ៥២យ៉ាងខ្លាំង នៅក្នុងស្រុកកោះធំ ។ ម៉ាក ទក បាននិយាយថា ក្នុងទឹកដីស្រុកកោះធំនេះ មានសង្គ្រាមតាំងពីឆ្នាំ១៩៧០ម្ល៉េះ ។ សង្គ្រាមបានធ្វើឲ្យឆេះផ្ទះសម្បែងជាច្រើនខ្នង ហើយទាហានធីវគីចូលលុកលុយក្នុង

ភូមិចាប់មាន់ចាប់ទារបស់អ្នកស្រុកតាមតែអំពើចិត្ត ។ សកម្មភាពទាំងនេះបានជំរុញឲ្យគាត់សម្រេចចិត្តចូលបម្រើអង្គភាពទ័ពភូមិភាគនិរតី ដើម្បីប្រមូលផ្តុំកម្លាំងវាយជាមួយកងទ័ពអាមេរិក និង លន់ ណុល ឲ្យកាន់តែខ្លាំងឡើង ។ ម៉ាក ទក នៅក្នុងវរសេនាតូច ១១៧ ដែលមាន ហ៊ុន ជាប្រធានក្នុងវរសេនាធំ១២៧ ក្រោមការដឹកនាំរបស់ ឈុន និងក្នុងកងពល១២ចំណុះឲ្យភូមិភាគពិសេស ដែលស្ថិតនៅក្រោមការបញ្ជារបស់ តាណាត និង ពីន ។ មុនដំបូង គាត់ត្រៀមនៅភូមិព្រែកតាអេម រួចចេញពីនោះទៅត្រៀមនៅភូមិរបោះអង្កាញ់ ភូមិព្រែកប្រា ភូមិចំពុះក្អែក និង ភូមិកោះក្របី ។ អង្គភាពបានរៀបចំឲ្យមានការហ៊ឹកហ៊ឺនផ្នែកនយោបាយនិងយុទ្ធសាស្ត្រប្រយុទ្ធ ដែលបង្ហាត់បង្រៀនដោយ ឡូញ និង ឆាន ។

ម៉ាក ទក បាននិយាយបន្តថា អង្គភាពរបស់គាត់ទទួលបានជ័យជម្នះជាច្រើនកន្លែង ដូចជានៅសមរភូមិគល់ទទឹង ភូមិចំពុះក្អែកជាដើម ។ នៅក្នុងឆ្នាំ១៩៧៤ ទ័ពខាង លន់ ណុល បានវាយបកមកវិញ ប៉ុន្តែនៅក្នុងឆ្នាំដដែលនោះ កងទ័ពខ្មែរក្រហមបានវាយបកវិញរហូតដល់ដណ្តើមកាន់កាប់បានទីក្រុងភ្នំពេញតែម្តង ។ ក្នុងអំឡុងពេលវាយនៅសមរភូមិកោះក្របី (វត្តកោះក្របីសព្វថ្ងៃ) អង្គភាពរបស់ ម៉ាក ទក ត្រូវបានបញ្ចូលក្នុងកង១៨២វិញ ស្ថិតក្នុងចំណុះវរសេនាធំ១២៧ និងនៅក្នុងកងពលលេខ១២ដដែល ។ ពេលវាយចូលទីក្រុងភ្នំពេញនាឆ្នាំ ១៩៧៥ គាត់ស្ថិតនៅមុខព្រួញត្រើយខាងកើតទន្លេបាសាក់ ទៅតាមភូមិកោះក្របី ភូមិចំពុះក្អែក វាយបុកឡើងទៅច្បារអំពៅ ។



ម៉ាក ទក



ផ្ទះរបស់ ម៉ាក ទក

ក្រោយឆ្នាំ១៩៧៥ កងវរសេនាតូចលេ១១៧បានទទួលបញ្ជាឲ្យទៅការពារព្រំប្រទល់កម្ពុជា-វៀតណាម ត្រង់ខេត្តស្វាយរៀងនិងខេត្តតាកែវិញ ។ ចំណែក ម៉ាក ទក នៅក្នុងវរសេនាតូចលេខ១៨២បានទទួលការចាត់តាំងឲ្យទៅធ្វើស្រែដីកប្រឡាយនៅព្រៃសក្រោមចំណុះមន្ទីរស-២១ ។ នៅទីនោះគាត់បានជួបជាមួយអ្នកមកពីភូមិកំណើតរបស់គាត់មួយចំនួន ដែលអ្នកទាំងអស់នោះបានចេញពីភូមិទៅចូលក្នុងជួរបដិវត្តន៍ ដូចជាមិត្តនារីតែគ្រី មិត្តនារី ស្រេង ជាដើម ដោយអ្នកទាំងនោះត្រូវបានចោទថាមានប្រវត្តិរូបមិនស្អាតស្អំ និងធ្លាប់រត់មកផ្ទះ ។ គាត់និងមិត្តរួមក្រុមទាំងអស់ត្រូវបានបង្ខំឲ្យធ្វើការយ៉ាងទម្ងន់ ទាំងយប់ទាំងថ្ងៃនិងហូបបាយលាយពោតក្រហម ។ គាត់និយាយថា “ខ្ញុំខំចេញពីផ្ទះលះបង់ឪពុកម្តាយមកធ្វើបដិវត្តន៍ដើម្បីជាតិ តែបែរជាទទួលលទ្ធផលបែបនេះទៅវិញ” ។ ក្រៅពីម៉ោងធ្វើការ អង្គការតម្រូវឲ្យគាត់ចូលរួមប្រជុំទិតៀនគ្នាពីការធ្វើការងារនិងសតិអារម្មណ៍ថែមទៀត ។

មន្ទីរព្រៃសមានឈ្មោះថា មន្ទីរស-២៤ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ហ៊ុយ ហើយក៏ជាសាខារបស់មន្ទីរស-២១ដែរ ។ កាលនោះ ម៉ាក ទក មិនទាន់ស្គាល់គុកទួលស្លែងទេ គាត់ស្គាល់តែមន្ទីរស-២១ ទើបតែក្រោយឆ្នាំ១៩៧៩ ទើបគាត់ឮថាគុកទួលស្លែង ។ នៅក្នុងឆ្នាំ១៩៧៨ គាត់ត្រូវបានបញ្ជូនឲ្យមកនៅមន្ទីរពេទ្យក្រុងតាខ្មៅធ្វើជាអ្នកនេសាទ ពេលនោះគាត់មានការភ័យខ្លាចយ៉ាងខ្លាំង ព្រោះគាត់គិតថា ឲ្យតែបញ្ជូនចេញពីមន្ទីរគឺពិតជាត្រូវយកទៅសម្លាប់ចោលហើយ ។ ប៉ុន្តែសំណាងល្អ គាត់មិនត្រូវបានយកទៅសម្លាប់ឡើយ ។ នៅមន្ទីរពេទ្យក្រុងតាខ្មៅ (ចំណុះឲ្យមន្ទីរស-២១ដែរ) ម៉ាក ទក បានឃើញខ្មែរក្រហមយកសាកសពទៅដុតនៅកន្លែងអគារពេទ្យឆ្លបសព្វថ្ងៃ ។ ពេលដុតម្តងៗមានរហូតទៅពីរបីឡានឯណោះ ។ ខ្មោចទាំងនោះយកមកពីភ្នំពេញដោយលាយជាមួយឈើគ្រឿងផ្ទះ ហើយឡានទាំងនោះ

សុទ្ធតែបិទជិតទាំងអស់ ។ ពេលដុតម្តងៗខ្មែរក្រហមបិទចរាចរ មិនអនុញ្ញាតឲ្យអ្នកណាចូលទៅតាមផ្លូវនោះទេ ។ ម៉ាក ទក គិតថា អ្នកទាំងនោះ ភាគច្រើនជាកងទ័ព និងជាអ្នកទោសដែលដឹកមកពីគុកទួលស្លែង ។ គាត់បានដើរទៅមើលកន្លែងដុតនោះភ្លាម បន្ទាប់ពីយុទ្ធជនខ្មែរក្រហមចេញទៅបាត់ ។ ក្រៅពីការងារនេសាទនៅពេលយប់ អង្គការឲ្យគាត់ទៅស្ទូចថ្នាំអំពូលនិងថ្នាំគ្រាប់ ។

នៅខែមករា ឆ្នាំ១៩៧៩ ម៉ាក ទក បានរត់ទៅជាមួយ ប៉េង ស្រេង រួមជាមួយមិត្តភក្តិផ្សេងទៀត ។ គាត់បានជួប ឌុច នៅភូមិបឹងត្នោតជិតអមលាំង ហើយបានរួមដំណើរជាមួយគ្នា ។ ឌុច បញ្ជាឲ្យយុទ្ធជនក្មេងៗជីកលេណដ្ឋាន ។ ម៉ាក ទក រអ៊ូថា "គ្រាន់តែគ្រាប់ផ្លោង នាំគ្នាជីកត្រង់សេឲ្យគេនឿយហត់ អត់ងងុយចង់ងាប់ ភ្លឹកម្ពស់ៗណាណី គ្រាន់តែអង្គុយក៏បាត់ដែរ គ្រាប់ផ្លោងគ្រាន់តែផ្ទុះចេញពីកាណុងមក គេដឹងធ្លាក់នៅកន្លែងណាបាត់ទៅហើយ" ។ ពេលនោះ ទុយ បានឮ ក៏ទៅរាយការណ៍ឲ្យ ឌុច ។ ឌុច, ហ៊ី និង ចាន់ បម្រុងបាញ់ ម៉ាក ទក សម្លាប់ចោល ប៉ុន្តែមិនហ៊ាន ដោយសារ ម៉ាក ទក គំរាមបោកគ្រាប់បែកឲ្យស្លាប់ទាំងអស់គ្នា ។ ក្រុមរបស់ ម៉ាក ទក ក៏ដើរបែកគ្នាពីក្រុមរបស់ ឌុច ។ ក្រោយមក ម៉ាក ទក ឮថា ហ៊ី និងប្រពន្ធ ត្រូវក្រុមខ្មែរក្រហមសម្លាប់ចោលដោយអារកនឹងធាងត្នោត ។

ក្រោយមកទៀត ម៉ាក ទក បានជួបជាមួយ តាម៉ុក ហើយបានបន្តដំណើរហូតដល់ព្រំដែនថៃ ដោយដើរទាំងយប់ទាំងថ្ងៃឆ្លងកាត់ភ្នំជាច្រើន និងគ្មានអាហារបរិភោគគ្រប់គ្រាន់ ។ ដោយសារការឃោសនារបស់ខ្មែរក្រហមនៅក្នុងព្រៃ និងការភ័យខ្លាចវៀតណាមពីមុនមកផង ម៉ាក ទក មិនហ៊ានត្រឡប់មកស្រុកកំណើតវិញទេ ។ មកដល់ឆ្នាំ១៩៨០ ទើបគាត់ហ៊ានចុះពីលើភ្នំរួមជាមួយមិត្តភក្តិជាង២០នាក់ទៀត ។ គាត់ចុះមកធ្វើស្រែវស្សាមួយឆ្នាំទៀត នៅម្តុំភូមិអំពិល ។ ដោយសារការធ្វើស្រែមិនបានផល គាត់ក៏នាំគ្នារត់ទៅជំរំជនភៀសខ្លួននៅព្រំដែនកម្ពុជា-ថៃ ។

ម៉ាក ទក បានត្រឡប់មកដល់ផ្ទះវិញនៅក្នុងឆ្នាំ១៩៨១ ហើយបានជួបជុំតែឪពុកនិងបងស្រីម្នាក់ប៉ុណ្ណោះ ចំណែកបងគាត់ម្នាក់ទៀតបាត់ខ្លួនតាំងពីជំនាន់ ប៉ុល ពត ។ គាត់ព្រមទាំងគ្រួសាររបស់មានការត្រេកអរណាស់បន្ទាប់ពីបានបែកគ្នាអស់រយៈពេលជាច្រើនឆ្នាំមក ។ គាត់បានរៀបការនៅក្នុងឆ្នាំ១៩៨១ និងមានកូនបួននាក់ ។ បច្ចុប្បន្នគាត់ជាបុរសពោះម៉ាយ រស់នៅជាមួយកូនទាំងបួន ។ ការងារប្រចាំថ្ងៃរបស់គាត់គឺធ្វើស្រែ គាត់លែងគិតគូរខ្វល់ខ្វាយអំពីរឿងសង្គមទៀតហើយ ។ គាត់ឆ្អែតចិត្តយ៉ាងខ្លាំងទៅលើអ្វីដែលគាត់បានលះបង់កន្លងមក ដើម្បីប្រទេសជាតិ ។ គាត់រស់នៅក្នុងជីវភាពយ៉ាងលំបាក ហើយសូម្បីតែដីសម្រាប់លំនៅដ្ឋានមួយកន្លែងដែលគាត់រស់នៅសព្វថ្ងៃ ក៏ជាដីរបស់សាច់ញាតិខាងប្រពន្ធគាត់ដែរ ។ គាត់មិនដឹងថាអនាគតគាត់និងកូនរបស់គាត់ទៅថ្ងៃមុខទៅជាយ៉ាងណាទេ ។ កូនរបស់គាត់មិនបានរៀនជ្រៅជ្រះ ហើយគាត់វិញក៏មិនអាចក្លាយទៅអ្វីផ្សេងទៀតក្រៅពីកសិករដែរ ។ គាត់និយាយថា "កាលខ្ញុំនៅតូចខ្ញុំមិនបានរៀនសូត្រឲ្យជ្រៅជ្រះទេ ព្រោះរវល់តែរត់គេចពីសង្គ្រាម ហើយក្រោយមកខ្ញុំក៏ចូលទៅបម្រើបដិវត្តន៍ទៀត" ។

នេះហើយជាសំណល់ពីអតីតកាល ដែលបានបន្សល់ទុកដល់ប្រជាជនកម្ពុជាសព្វថ្ងៃ ។ តើអ្វីទៅដែលជាដំណោះស្រាយក្នុងចំណោទទាំងនេះ? តើបញ្ហាទាំងនេះអាចដោះស្រាយតាមវិធីណាខ្លះ? តើប្រជាជនត្រូវបន្តជាចំណាប់ខ្មាំងនៃភាពក្រីក្រនេះតទៅទៀតឬមួយយ៉ាងណា?

**ផាន់ សុជា**

# ពន្យល់ពាក្យខ្មែរក្រហម

◆ **ជនកុម្មុយនិស្តៈ** គឺជាអ្នកអង់អាចក្លាហាន ពុះពារនូវរាល់ឧបសគ្គគ្រប់បែបយ៉ាងមោះមុត ហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាងមានការលះបង់ស្ងួនតួបុគ្គលអាត្មាខ្លួន រហូតដល់ជីវិតខ្លួនទៀតក៏ឥតរុញរា ។ រូបភាពគឺជាមនុស្សដូចគ្នា តែខ្លឹមសារវិញខ្ពស់ខ្ពង់ឧត្តមណាស់ ។

**(ដកស្រង់ពីសៀវភៅកំណត់ហេតុ១៨១)**

# តើការបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម គឺជាបញ្ហាកម្មផលឬ?


ខៀវ យ៉េន

ឆ្នាំ១៩៧៧ គឺជាឆ្នាំអាក្រក់បំផុតសម្រាប់លោកយាយ ខៀវ យ៉េន ។ កូនប្រុសស្រីចំនួនបីនាក់ និងចៅប្រុសម្នាក់របស់លោកយាយត្រូវបានខ្មែរក្រហមសម្លាប់ និងបាត់ដំណឹងរហូតមកដល់បច្ចុប្បន្ន ។

លោកយាយ ខៀវ យ៉េន មានអាយុ៧៨ឆ្នាំ រស់នៅភូមិស្វាយស្រណោះ១ ឃុំរការអារ ស្រុកកងមាស ខេត្តកំពង់ចាម ។ លោកយាយ យ៉េន មានកូនទាំងអស់បួននាក់ ស្រីបីនាក់ ប្រុសម្នាក់ ។ សព្វថ្ងៃ លោកយាយ យ៉េន រស់នៅជាមួយកូនស្រីច្បង ដែលបានរួចផុតពីការយកទៅសម្លាប់របស់ខ្មែរក្រហម ។ លោកយាយ យ៉េន បានរំឭកឡើងវិញថា នៅអំឡុងឆ្នាំ១៩៧២ កូនប្រុសរបស់គាត់ឈ្មោះ សុក នីន បានចេញទៅធ្វើបដិវត្តតាមមិត្តភក្តិដែលរស់នៅក្នុងភូមិស្វាយស្រណោះជាមួយគ្នា ។ សុក យឹម ដែលជាកូនស្រីទី៣ បានចេញទៅធ្វើបដិវត្តន៍នៅអំឡុងឆ្នាំ១៩៧៣ តាមរយៈសមមិត្ត ហង់ ។ ចំណែក កូនស្រីពៅឈ្មោះ សុក ស៊ីយឹម ចូលបដិវត្តន៍តាមរយៈបងប្រុសឈ្មោះ នីន នៅទីក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៧៦ ។


សុក នីន

បន្ទាប់ពីថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ បានប្រមាណបីខែ នីន បានមកយកម្តាយប្អូនស្រី ឈ្មោះ ស៊ីយឹម ក្មួយប្រុសឈ្មោះ ញ៉ែម តុល និងប្អូនស្រីជីដូនមួយពីរនាក់ទៀតឈ្មោះ ហឿន និង ដុន នៅឯស្រុកកំណើតទៅរស់នៅភ្នំពេញដែរដើម្បីរៀនសូត្រចូលធ្វើនារីពេទ្យ ។ នៅភ្នំពេញ លោកយាយ យ៉េន គឺជាអ្នកដាំបាយសម្រាប់កូនៗ ។

នៅក្នុងឆ្នាំ១៩៧៧ ដោយសារលោកយាយមិនទម្លាប់រស់នៅទីក្រុង និងដោយនឹករឭកដល់កូនស្រីច្បង ឈ្មោះ យឿន ខ្លាំងពេក លោកយាយក៏បានឲ្យកូនឈ្មោះ នីន ជូនគាត់មកស្រុកកំណើតវិញ ។ លោកយាយបានធ្វើដំណើរតាមកាណូតរហូតដល់ម៉ោង១១យប់ ទើបមកដល់ភូមិស្វាយស្រណោះ ។

បន្ទាប់ពីលោកយាយ ត្រឡប់មកដល់ស្រុកកំណើតបានប្រមាណពីរខែ លោកយាយបានទទួលដំណឹងថា នីន ត្រូវអង្គការខ្មែរក្រហមចាប់យកទៅដាក់គុកនិងសម្លាប់ចោល ។ លោកយាយមានអារម្មណ៍ក្តុកក្តួលយ៉ាងខ្លាំង ប៉ុន្តែនៅកាលៈទេសៈនោះ គ្មានអ្វីអាចជួយគាត់បានក្រៅអំពីខិតខំធ្វើការងារឲ្យបានតាមផែនការរបស់អង្គការឡើយ ពីព្រោះបើមិនដូច្នោះទេអង្គការខ្មែរក្រហមនឹងស្រាវជ្រាវយកទៅសម្លាប់បន្តៗទៀត ។

ក្រោយថ្ងៃ៧ មករា ឆ្នាំ១៩៧៩ លោកយាយ យ៉េន បានរកហោរាទស្សន៍ទាយអំពីជោគវាសនាកូននិងចៅរបស់គាត់ ។ គ្រូទាយបានប្រាប់ថា ក្នុងចំណោមកូនទាំងបីនាក់នោះ មានតែ សុក ស៊ីយឹម ម្នាក់គត់ដែលនៅរស់រានមានជីវិត ។ ចំណែក សុក នីន, សុក យឹម និងចៅម្នាក់ឈ្មោះ តុល ត្រូវស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមអស់ទៅហើយ ។ រៀងរាល់ពេលដែលទៅវត្តម្តងៗ លោកយាយតែងតែឧទ្ទិសកុសលដល់កូននិងចៅ ដើម្បីឲ្យបានទៅកាន់សុគតិភព ។ លោកយាយ យ៉េន បាននិយាយថា “វាពិបាកនឹងរៀបរាប់អំពីទំហំនៃសេចក្តីនឹករឭក និងការសោកស្តាយពន់ពេកណាស់ ហើយក៏គ្មានអ្វីមកសងជីវិតកូនរបស់ខ្ញុំទាំងនោះបានដែរ ”។


សុក ស៊ីយឹម

ចំពោះកូនស្រីម្នាក់ឈ្មោះ សុក ស៊ីយឹម ដែលគ្រូទាយថានៅរស់នោះ រហូតមកដល់សព្វថ្ងៃ

ក៏លោកយាយ យ៉េន មិនដែលបានដឹងដំណឹងដែរ ។

បើតាមឯកសារប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំងនៅទួលស្លែង (ស-២១) សុក នីន ហៅ ដាន់ ភេទប្រុស អាយុ២៤ឆ្នាំ ចូលបដិវត្តន៍នៅឆ្នាំ១៩៧២ នៅសមរភូមិផ្សារ ។ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នីន មានតួនាទីជានិរសាកងពល៣១០ ភូមិភាគឧត្តរ ដែលមានសមមិត្ត អឿន ជាលេខា និងសមមិត្ត វឿង ជាអនុលេខា ។ នីន ត្រូវបានអង្គការខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅមន្ទីរកងពល៣១០ ។


សុក យឹម

សុក យឹម អាយុ២០ឆ្នាំជាយុទ្ធនារីនៅមន្ទីរពេទ្យ៩៨ ។ សុក យឹម ត្រូវបានអង្គការខ្មែរក្រហមចាប់នៅមន្ទីរពេទ្យ៩៨ក្នុងឆ្នាំ ១៩៧៧ ។

នៅក្នុងប្រវត្តិរូបសង្ខេបដែលបន្សល់ពីរបបខ្មែរក្រហម សុក យឹម អាយុ១៥ឆ្នាំ ជាយុទ្ធនារីរៀនពេទ្យផ្នែកពិសោធនៅមន្ទីរពេទ្យ៩៨ កងពល៣១០ ចូលបដិវត្តន៍នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៧៦ តាមរយៈបងប្រុសឈ្មោះ ដាន់ ។

ញ៉ែម គុល អាយុ៧ឆ្នាំ ជាកុមាររស់នៅជាមួយកូនៗកម្មាភិបាលជាន់ខ្ពស់របស់កងពល៣១០ ។ គុល ចូលបដិវត្តន៍តាមរយៈ នីន នៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

ម៉ឹង ហឿន ត្រូវជាប្អូនជីដូនមួយស្រីរបស់ នីន បានចូលបដិវត្តន៍តាមរយៈ នីន ។ ហឿន ត្រូវបាន នីន យកទៅភ្នំពេញជាមួយប្អូនៗនិងក្មួយដែរ ។ ហឿន បាននិយាយថា សុក យឹម ត្រូវខ្មែរក្រហមយកទៅសម្លាប់ដោយចោទថាខុសសីលធម៌ ។ បន្ទាប់ពី សុក យឹម ត្រូវខ្មែរក្រហមចាប់ ម៉ឹង ហឿន, សុក យឹម និង ញ៉ែម គុល ត្រូវបានបញ្ជូនចេញពីមន្ទីរពេទ្យព្រះកេតុមាលាឲ្យទៅដាំដំណាំនៅម្តុំទួលគោក ។ បន្ទាប់ពីស្នាក់នៅទួលគោកបានរយៈពេលបីខែ យឹម និង គុល ត្រូវបានអង្គការ


ញ៉ែម គន

ខ្មែរក្រហមហៅឡើងឡានចេញពីកសិដ្ឋានទៅទៀត ។ ហឿន មិនបានទទួលដំណឹងពី យឹម និង គុល ឡើយ ។

ញ៉ែម គន អាយុ៦២ឆ្នាំ ត្រូវជាឪពុករបស់ គុល បាននិយាយថា នៅចុងឆ្នាំ១៩៧៩ គាត់បានទៅចូលមើលសារមន្ទីរទួលស្លែងដែលជាអតីតមន្ទីរស-២១ ដើម្បីស៊ើបពីដំណឹងប្អូននិងកូនដែលបានបែកគ្នាយូរមកហើយ ។ គាត់ជុំគិតអាសោចសាកសពអ្នកទោសនិងឧបករណ៍ធ្វើទារុណកម្មដែលសេសសល់នៅទីនោះ ។ រយៈពេលពីរម៉ោងបន្ទាប់ពីដើរទស្សនាតាមបន្ទប់នីមួយៗនៅក្នុងបរិវេណនោះគាត់បានឃើញរូបថតរបស់ នីន ចំនួនបីសន្លឹកព្យួរក្បែរៗគ្នានៅជញ្ជាំងបន្ទប់មួយ ។ រូបថតទី១ ស្លៀកខោវែងពាក់អាវដៃខ្លី (ថតមួយជំហរដោយដៃទាំងពីរត្រូវចងស្ពាយសេក) ។ រូបថតទី២ ថតពាក់កណ្តាលខ្លួននៅផ្នែកខាងក្រោមមានសរសេរថា «ទោសក្បត់សមូហភាព» និងរូបថតទី៣ ស្លៀកខោខ្លី ហើយដៃទាំងពីរត្រូវចងស្ពាយសេក ។ ជាមួយគ្នានោះគាត់បានឃើញរូបថត អឿន (លេខាភូមិភាគឧត្តរ) ប្រពន្ធរបស់ អឿន និងកូនបីនាក់ក្នុងនោះស្រីម្នាក់ ។ គាត់យល់ថាមកពីមានការចាប់ខ្លួន អឿន ទើបនាំឲ្យមានការចាប់ នីន ។ ក្នុងខណៈពេលនោះ ប្រសិនបើគាត់បានឃើញខ្មែរក្រហមគាត់នឹងសម្លាប់វិញភ្លាម ក៏ប៉ុន្តែសម្រាប់កាលៈទេសៈបច្ចុប្បន្ននេះគាត់គិតថាវិធីនេះមិនល្អឡើយ ត្រូវតែធ្វើតាមផ្លូវច្បាប់វិញ ។

រយៈពេល២៦ឆ្នាំបានកន្លងផុតទៅហើយ ប៉ុន្តែ លោកយាយ យ៉េន នៅតែមិនអាចបំភ្លេចបាននូវការនឹករឭកដល់កូននិងចៅឡើយ ។ បច្ចុប្បន្ន លោកយាយ យ៉េន ជាពុទ្ធសាសនិកមួយរូប លោកយាយគិតថា ការស្លាប់របស់កូនៗនិងចៅរបស់គាត់ជាកម្មផល ។ លោកយាយមានប្រសាសន៍ថា «នេះជាផលកម្មកូនរបស់ខ្ញុំ ដែលត្រូវស្លាប់ទាំងនៅក្មេង» «បើខ្មែរក្រហមមិនយកកូនខ្ញុំទៅសម្លាប់ ប្រហែលជារហូតមកដល់ពេលនេះ ខ្ញុំបានរស់នៅជួបជុំគ្នាទៅហើយ» ។ តើការបាត់បង់កូនចៅទាំង៤នាក់របស់លោកយាយ យ៉េន ក្នុងរបបខ្មែរក្រហម វាជាបញ្ហាកម្មផលដូចលោកយាយ យ៉េន បានគិតឬយ៉ាងណា?

**ឡុង ដានី**

*អត្ថបទពីមិត្តអ្នកអាន៖*

# រឿងរ៉ាវមនុស្សស៊ីសាច់មនុស្ស

រឿងរ៉ាវមនុស្សស៊ីសាច់មនុស្សបានកើតឡើងនៅសម័យខ្មែរក្រហម ក្នុងសហករណ៍ភូមិអូរ ឃុំកោះជុំ ស្រុកសំពៅមាស (បច្ចុប្បន្នស្រុកបាកាន) ខេត្តពោធិ៍សាត់ ។ ដើម្បីឲ្យបានដឹងរឿងហេតុដ៏គួរឲ្យព្រឺព្រួច ភ័យរន្ធត់ តក់ស្លុត និងជាអំពើដ៏ព្រៃផ្សៃ ដែលបង្កឡើងដោយកងឡើងត្នោតមួយក្រុមដែលដាច់ចិត្តស៊ីសាច់កូនក្មេងដើម្បីធ្វើជាអាហារបំបាត់ការស្រេកឃ្លាន ។ ការពិតនៃរឿងទាំងនេះប្រិយមិត្តអ្នកអានទស្សនាវដ្ដីស្វែងរកការពិតនឹងបានជ្រាបដូចតទៅ÷

តាមរយៈមីង ប៊ូ ផល បានឲ្យដឹងថានៅក្នុងសហករណ៍របស់គាត់មានកងឡើងត្នោតស៊ុសាច់កូនក្មេងតូចៗ ។ ប៊ូ ផល បានអះអាងថាគាត់បានឃើញផ្ទាល់ភ្នែក នៅពេលដែលពួកក្រុមឡើងត្នោតមួយក្រុមបានសង់រោងមួយ ឋិតក្នុងភូមិអូរ ក្បែរមាត់បឹងមួយ ដើម្បីឡើងត្នោតធ្វើទឹកនិងប្រមូលទឹកត្នោតដែលពួកគេធ្វើបានទាំងប៉ុន្មាន យកមកចាក់ដាក់ខ្ទះត្នោតរំងាស់យកស្ករត្នោតរៀងរាល់ថ្ងៃ។ ចំណែកកូនក្មេងចេះតែបាត់ខ្លួនជាបន្តបន្ទាប់ ។ ប៊ូ ផល ក៏ដូចប្រជាជនទាំងអស់ក្នុងសហករណ៍ភូមិអូរ មានការងឿងឆ្ងល់ថា រៀងរាល់ថ្ងៃ ពួកក្មេងៗតែងតែបាត់ខ្លួនដោយមិនដឹងមូលហេតុអ្វីឡើយ ។ ឪពុកម្ដាយដឹងថាបាត់កូនចៅដែរក៏ប៉ុន្តែមិនដឹងទៅរកនៅទីណា ព្រោះថារបបនោះ ប្រជាពលរដ្ឋមិនអាចមានសិទ្ធិដើរហើរសេរីបានទេ។ ប៊ូ ផល បាននិយាយថា មិនដឹងជាថ្ងៃអ្វី ស្រាប់ថ្ងៃមួយនោះគាត់ទៅចម្ការដើម្បីស្រោចទឹកបន្លែ ស្រាប់តែបានប្រទះឃើញពួកក្រុមឡើងត្នោតកំពុងតែលាងពោះវៀនកូនក្មេង ។ គាត់លបៗ ឱនៗកំបាំងស្រូវទុំខ្ពស់ៗ មិនហ៊ានឲ្យពួកនោះឃើញគាត់ទេ គាត់ក៏លបរត់ទៅរាយការណ៍ជូនប្រធានសហករណ៍អំពីករណីក្រុមឡើងត្នោតស៊ីសាច់កូនក្មេង ។

នៅពេលសួរ ប៊ូ ផល ថាហេតុអ្វីពួកនោះចាប់ក្មេងបានដោយគ្មាននរណាដឹង? ប៊ូ ផល និយាយបន្តប្រាប់ថា ពួកក្មេងតូចៗវាឃ្លានអាហារណាស់ ពួកវាស្គមៗស្បែកដណ្ដប់ឆ្អឹង ព្រោះតែហូបបបររាវ ។ ដោយសារសេចក្ដីស្រេកឃ្លានខ្លាំងពេក ទើបពួកក្មេងៗទាំងនោះនាំគ្នាទៅលិទ្ធស្ករដែលនៅសេសសល់បន្តិចបន្តួចជាប់នៅបាតខ្ទះត្នោត ជារៀងរាល់ៗថ្ងៃ ក្រោយពេលដែលក្រុមឡើងត្នោតបានរំងាស់រួចនិងដួសស្ករចេញអស់ ។ នៅកន្លែងរំងាស់ស្ករត្នោត ក្រៅពីពួកឡើងត្នោតនិងកម្មាភិបាលខ្មែរក្រហម គ្មាននរណាម្នាក់អាចចេញចូលឡើយ ។

យើងបានសួរគាត់ទៀតថា តើពួកដែលស៊ីសាច់កូនក្មេងនោះមានទោសអ្វីទេ? ប៊ូ ផល និយាយថា ពួកអ្នកស៊ីសាច់កូនក្មេងទាំងអស់ ត្រូវបានពួកសន្តិសុខវត្តកោះជុំយកទៅសម្លាប់នៅកោះឈើកឹមទាំងអស់ ក្រោយពីបានពិនិត្យនៅរោងរំងាស់ស្ករត្នោតឃើញថាមានលាក់ក្បាលកូនក្មេងជាច្រើនទុកដោយច្រកក្នុងបាវនៅលើធ្នើរោងរំងាស់ស្ករត្នោតនោះ ។

ប៊ូ ផល បានរៀបរាប់ពីការស្លាប់របស់កូនគាត់ទាំង៦នាក់ថា ក្នុងរយៈពេលតែជាង២ខែ គឺ២ថ្ងៃ ៣ថ្ងៃស្លាប់មួយ ស្លាប់បន្តបន្ទាប់ ហើយគាត់បានយកកូនគាត់ទៅកប់ដោយផ្ទាល់ដៃ គ្មាននរណាជួយគាត់ទេ ។ ការស្លាប់របស់កូនគាត់នោះមូលហេតុគ្មានអាហារបរិភោគគ្រប់គ្រាន់ ។ មូលហេតុម៉្យាងទៀត ប៊ូ ផល បានរៀបរាប់ថា បណ្ដាកូនគាត់ទាំង៦នាក់នោះ មានអាយុមិនទាន់ពេញកម្លាំងពលកម្មនៅឡើយទេ ប៉ុន្តែអង្គការឲ្យឃ្វាលគោជារៀងរាល់ថ្ងៃ។ កូនៗគាត់តែងតែទៅហូបបបររាវនៅរោងបាយដោយសារជីវជាតិអាហារតិចតួចពេក កូនគាត់ខ្សោយកម្លាំង ក៏ចាប់ផ្ដើមមានជំងឺហើមពោះ រាគរូសយ៉ាងខ្លាំង មិនអាចដើរទៅហូបបបរនៅរោងបាយបាន ។ ដូច្នេះហើយ គាត់ទៅសុំអង្ករពីប្រធានរោងបាយ ។ ប្រធានរោងបាយបានឲ្យអង្ករគាត់មួយស្លាបព្រាបាយសម្រាប់កូនឈឺម្នាក់ៗនិងអំបិលចំនួន១០គ្រាប់ ។ គាត់បានយកអង្ករទៅចម្អិនឲ្យកូនហូប ។ ដោយអាហារតិចហើយកូនមានជំងឺធ្ងន់ធ្ងរ និងគ្មានថ្នាំសង្កូវព្យាបាល ទើបកូនៗគាត់ស្លាប់

បន្តបន្ទាប់ដូច្នេះ ។ ប៉ូ ផល និយាយទាំងអួលដើមកនិងមានទឹកភ្នែកហូរស្រក់ផងថា ទុក្ខដួនៗគ្នាជាប់ ដោយនឹកអាណិតអាសូរកូនពេក ពេលនោះគាត់ឡប់សតិចង់ឆ្កួតម្តងៗ ។ នៅសហករណ៍ភូមិអូរ ក៏ដូចជានៅតាមសហករណ៍នៅភូមិក្បែរៗនោះដែរ ខ្មែរក្រហមបានផ្តល់របបអង្ករ១០កំប៉ុង សម្រាប់ដាំបបរមួយខ្ទះត្នោត ។ បបរដែលដាំពុះរួច ពួកកម្មាភិបាលរោងបាយបានដួសទឹកបបរចេញម្តង រួចចាក់ទឹកថ្មីចូល រួចមកយកទឹកបបរដែលដួសទុកលើកទី១នោះមកកូររំលាយបញ្ចូលគ្នា ធ្វើឲ្យទឹកបបរមិនអាចឆ្អិនបានល្អទេ ។ បន្ទាប់មក យកបបរនោះមកចែកឲ្យប្រជាជនម្នាក់ៗពីរវែកសម្លរ ។ ក្រោយពីហូបបបរនោះរួចប្រជាជនទាំងចាស់ទាំងក្មេង ហើមពោះរាគរូស ឈឺស្លាប់ជារៀងរាល់ថ្ងៃ និងមួយចំនួនទៀតបានស្លាប់នៅមន្ទីរពេទ្យ ។ ប៉ូ ផល បានបញ្ជាក់ប្រាប់ថា ពេលគាត់សម្រាកព្យាបាលនៅមន្ទីរពេទ្យវត្តកោះដុំសម័យនោះ គាត់បានឃើញអ្នកជំងឺភាគច្រើនគឺកូនក្មេងតូចៗ ហើយស្លាប់ច្រើនណាស់ សាកសពប្រមូលបោះដាក់លើរទេះដូចបោះកណ្តាប់ស្រូវ ហើយសាកសពបានពីររទេះ ខ្មែរក្រហមយកទៅកប់ម្តង ។

ប៉ូ ផល បាននិយាយទៀតថា នៅក្នុងឃុំកោះដុំ មានសហករណ៍ជាច្រើន ដូចជាសហករណ៍ភូមិអូរ សហករណ៍ភូមិផ្ទះព្រីង សហករណ៍ភូមិអន្ទង់សំបួរ សហករណ៍ភូមិស្តុកដុំ សហករណ៍ភូមិស្វាយ ហើយនៅក្នុងសហករណ៍នីមួយៗគាត់បានដឹងថា មានប្រជាជនប្រហែលពី៣០០ទៅ៤០០គ្រួសារ ។ លុះដល់ដើមឆ្នាំ១៩៧៩ ប្រទេសត្រូវបានរំដោះ គឺនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនដែលរស់នៅតាមបណ្តាសហករណ៍ទាំងអស់គាត់បានឃើញនៅសេសសល់រួចពីស្លាប់ប្រហែល៤០០គ្រួសារប៉ុណ្ណោះ ក្រៅពីនោះជនរងគ្រោះដែលជាប្រជាជនប្រហែលពី៧០០ទៅ៨០០គ្រួសារបានស្លាប់ដោយការសម្លាប់ ជំងឺ និងអត់អាហារ ។ យើងបានសួរគាត់ថា តើប្រជាជនចាស់រស់នៅទីនោះក្នុងសម័យខ្មែរក្រហម១៩៧០-១៩៧៥ និងប្រជាជន១៧មេសា ខុសគ្នាយ៉ាងណា? ប៉ូ ផល ប្រាប់យើងថា នៅតំបន់នោះគឺដូចគ្នាទាំងអស់ មិនថាចាស់ថ្មីទេ ។ ការហូបចុកហូបបបររាវដូចគ្នា ធ្វើការងារដូចគ្នា ។

ប្រជាជននៅភូមិអូរ បានឲ្យដឹងថា សហករណ៍ភូមិអូរ ក៏ដូចជាសហករណ៍ទាំងអស់នៅក្នុងឃុំកោះដុំ ស្រុកសំពៅមាស (បច្ចុប្បន្នជាស្រុកបាកាន) ខេត្តពោធិ៍សាត់ដែរ ។ មូលហេតុនាំឲ្យមនុស្សស្លាប់យ៉ាងច្រើនពី៧០០ទៅ៨០០គ្រួសារ គឺមកពីគ្មានថ្នាំសង្កូវព្យាបាលនិងការបង្អត់អាហារ និងមួយចំនួនទៀតត្រូវពួកសន្តិសុខគុកវត្តកោះដុំចាប់មកដាក់គុកធ្វើទារុណកម្ម និងសម្លាប់ចោលដោយសារតែនិន្នាការនយោបាយនិងខុសឆ្គងបន្តិចបន្តួច ។ វិធីសម្លាប់មួយទៀត ដោយពួកកម្មាភិបាលឃុំ-ភូមិ និង ប្រធានសហករណ៍ដែលជាអ្នកអនុវត្តផ្ទាល់ដាក់ស្តែងគឺ អង្ករ១០កំប៉ុងសម្រាប់មនុស្សពី៣០០ទៅ៤០០នាក់ក្នុងមួយខ្ទះត្នោត នៅក្នុងសហករណ៍នីមួយៗ ។ ដូច្នេះហើយទើបធ្វើឲ្យពួកកងឡើងត្នោតទ្រាំនឹងការអត់ឃ្លានពុំបាន ក៏ដាច់ចិត្តសម្លាប់ក្មេងស៊ីសាច់ធ្វើជាអាហារយ៉ាងព្រៃផ្សៃបំផុតដូច្នេះ ។

រយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ ក្រោមការគ្រប់គ្រងរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ អំពើឧក្រិដ្ឋកម្មនិងវិធីសម្លាប់និងការធ្វើទារុណកម្មគ្រប់បែបគ្រប់យ៉ាង បានធ្វើឲ្យប្រជាជនស្លាប់អស់ជាងពីរលាននាក់ ។ អ្នកនៅរួចពីស្លាប់រងទុក្ខវេទនាយ៉ាងធ្ងន់ធ្ងរ ។ ទង្វើជាក់ស្តែងទាំងអស់នោះពួកមេដឹកនាំខ្មែរក្រហមសមល្មមឲ្យតុលាការកាត់ក្តីរកយុត្តិធម៌ជូនជនរងគ្រោះដែលបានស្លាប់ដើម្បីឲ្យវិញ្ញាណក្ខន្ធអ្នកទាំងនោះបានស្ងប់ចិត្ត ។ ពួកមេដឹកនាំខ្មែរក្រហមត្រូវតែទទួលខុសត្រូវនូវរាល់ទង្វើរបស់ខ្លួនមិនអាចគេចវេះបានឡើយ ។

**ឌុម ឌិទា**

# សេចក្តីជូនដំណឹង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតដែលចាក់ផ្សាយរៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៣:៣០-៣:៤៥នាទី តាមរយៈវិទ្យុ ១០២ MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា ។

**ផាត រចនា និង លី សុផល**

# តើសហគមន៍អន្តរជាតិអាចបញ្ឈប់អំពើប្រល័យពូជសាសន៍ នៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោបានដែរឬទេ?

«ការវាយតម្លៃរបស់យើងតាមការយល់ដឹងរបស់យើង គឺវាអាចជាអំពើប្រល័យពូជសាសន៍» ។ នេះគឺជាសម្តីរបស់លោក កាឡា ឌែល ប៉ុង ព្រះរាជអាជ្ញាអមតុលាការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិសម្រាប់យូហ្គោស្លាវីនិងរ៉ាន់ដា នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៣ ទាក់ទិននឹងការកើតឡើងនូវអំពើហិង្សាចុងក្រោយបង្អស់នៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ។

សម្តីរបស់ព្រះរាជអាជ្ញា ឌែល ប៉ុង លេចចេញនៅពេលដែលដំណើរការស្វែងរកសន្តិភាពដែលងាយនឹងប្រេះស្រាំនៅឡើយ នៅក្នុងប្រទេសកុងហ្គោត្រូវបានគំរាមកំហែងដោយការសម្លាប់រង្គាល ដែលតាមសេចក្តីរាយការណ៍ថាបានកើតឡើងនៅប៊ូនីញ៉ា រដ្ឋធានីនៃខេត្តអ៊ីតូរី នៅភាគបូព៌ានៃប្រទេសកុងហ្គោ ។ តំបន់ អ៊ីតូរី គឺជាកន្លែងដែលមានការប្រយុទ្ធគ្នាយ៉ាងសាហាវបំផុតនៅអំឡុងពេលសង្គ្រាមដែលបាននិងកំពុងឆាបឆេះនៅប្រទេសកុងហ្គោក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ។ ជាផ្នែកមួយនៃដំណើរការស្វែងរកសន្តិភាព កងទ័ពអ៊ូហ្គង់ដា ដែលបានកាន់កាប់តំបន់នេះ បានដកថយពីប៊ូនីញ៉ានៅថ្ងៃទី៧ ខែឧសភា ។ ប៉ុន្តែការដកថយរបស់កងទ័ពទាំងនេះបាននាំដល់ការប៉ះទង្គិចគ្នាសាជាថ្មីរវាងកងជីវពលនៃក្រុមជាតិពន្ធុនានាដែលមានជម្លោះជាពិសេស ឡេនឌូ និង ហេម៉ា ។

អ្នកស្រុកអ្នកភូមិរាប់ពាន់នាក់បានចាកចេញពីប៊ូនីញ៉ា ហើយបើយោងតាមបេសកកម្មរបស់អង្គការសហប្រជាជាតិប្រចាំនៅកុងហ្គោបានឲ្យដឹងថា យ៉ាងហោចណាស់មានប្រជាជន ២៨០នាក់ ត្រូវបានសម្លាប់ចាប់តាំងពីថ្ងៃទី៤ ខែឧសភា ក្នុងនោះមានទាំងស្ត្រីនិងកុមារ ។ មានសាកសពមួយចំនួនត្រូវកាត់ក្បាលចោល ហើយសាកសពផ្សេងទៀតត្រូវគេរូងយកថ្លើម បេះដូងនិងសួត ។ សាក្សីនានាបានរៀបរាប់អំពីការស្លាប់ និងការធ្វើកាយវិកលកម្មដែលកើតឡើងនៅពេលដែលអ្នកប្រយុទ្ធជាក្រុមកុលសម្ព័ន្ធសម្លាប់ជនស៊ីវិលនិងយុទ្ធជនរួច ហើយហែកយកបេះដូងយកមកស៊ីទាំងក្តៅៗតែម្តង ។ និស្សិតពេទ្យម្នាក់ឈ្មោះអាគីតគេ គីសេមបូ អាយុ២៨ឆ្នាំ បាននិយាយប្រាប់សារពត៌មានអាសូស៊ីអេតធីតប្រេសថា «ពេលឃើញសាកសពមនុស្សដែលគ្មានថ្លើមនិងគ្មានបេះដូងយ៉ាងដូច្នេះមើលទៅគួរឲ្យព្រឺមែនទែនជាពិសេសពេលអ្នកឃើញមនុស្សស៊ីសាច់មនុស្សដូចគ្នាយ៉ាងនេះ» ។

បេសកកម្មអង្គការសហប្រជាជាតិនៅកុងហ្គោនិយាយថាខ្លួននឹងចុះធ្វើការស៊ើបអង្កេតបទចោទប្រកាន់អំពីករណីមនុស្សស៊ីសាច់មនុស្សគ្នាឯងនេះ ។ ប៉ុន្តែនិយាយថា នេះមិនមែនជាលើកទីមួយទេដែលមានការចោទប្រកាន់បែបនេះនៅតំបន់ អ៊ីទូរី ។ នៅថ្ងៃទី១៥ ខែមករា អ្នកស៊ើបអង្កេតរបស់អង្គការសហ-ប្រជាជាតិបានបញ្ជាក់ថា ក្រុមខ្ទាមបានប្រព្រឹត្តបទល្មើសស៊ីសាច់មនុស្ស រំលោភ ធ្វើទារុណកម្ម និងមនុស្សឃាត» ។ លោក ស៊ែជីអូ វៀរ៉ា ដឺមេឡូ ឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍របស់លោក នាថ្ងៃទី៨ ខែមេសា កន្លងទៅថា «ចារីប្រព្រឹត្តអំពើឃោរឃៅទាំងនេះនឹងត្រូវបានតាមដានស៊ើបអង្កេត និងមានកាតព្វកិច្ចឡើងមកបំភ្លឺចំពោះទង្វើរបស់ខ្លួន ។ ពួកគេអាចនឹងក្លាយជាមុខសញ្ញាដែលត្រូវកាត់ទោសទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ» ។ សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោគឺជាភាគីហត្ថលេខីនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ដូចនេះតុលាការមានយុត្តាធិការទៅលើឧក្រិដ្ឋកម្មសង្គ្រាមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង អំពើប្រល័យពូជសាសន៍នៅលើទឹកដីរបស់ខ្លួន ។

### ការអំពាវនាវឲ្យមានចំណាត់វិធានការ

ហ្សង់-ម៉ារី ហ្គូហេណូ ប្រមុខប្រតិបត្តិការថែរក្សាសន្តិភាព

របស់អង្គការសហប្រជាជាតិ ប្រាប់ឲ្យដឹងជាមុនថា បើគ្មានចំណាត់វិធានការភ្លាមៗទេ នឹងមាន"ថ្មុកឈាម" មិនខានឡើយនៅក្នុងខេត្តអ៊ីតុទូរី នៃសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ដែលបង្កឡើងដោយជនជាតិភាគច្រើន ឡេនឌូ និងជនជាតិភាគតិចហេម៉ា ។

ជនជាតិ ឡេនឌូ ភាគច្រើនជាកសិករ ចំណែកឯជនជាតិភាគតិច ហេម៉ា តាមប្រពៃណីរៀងមកប្រកបរបរជាអ្នកចិញ្ចឹមគោក្របី ។ ជនជាតិទាំងពីរនេះមានជម្លោះនឹងគ្នាអស់ច្រើនសតវត្សរ៍មកហើយទៅលើបញ្ហាស្រទាប់រ៉ែដីសម្បូរបែប ព្រៃឈើនៅខេត្តអ៊ីតុទូរីនិងដីមានជីវជាតិ ។ ការប្រកួតប្រជែងគ្នាកាន់តែមានលក្ខណៈអាក្រក់ទៅៗ នៅពេលដែលសង្គ្រាមផ្ទុះឡើងនៅឆ្នាំ១៩៩៨ នៅពេលដែលប្រទេសរ៉ាន់ដា និងអ៊ូហ្គង់ដាចូលលុកលុយឈ្លានពានប្រទេសកុងហ្គោដើម្បីទម្លាក់ប្រធានាធិបតី ឡូរ៉ង់ កាប៊ីឡា ។ ប្រទេសរ៉ាន់ដា និងអ៊ូហ្គង់ដា ព្រួតគ្នាធ្វើសង្គ្រាមជាមួយកុងហ្គោ ប៉ុន្តែនៅចុងបញ្ចប់បែរជាគាំទ្រក្រុមខុសៗ ដែលជាគូប្រជែងគ្នា ។ នៅពេលដែលកងទ័ពអ៊ូហ្គង់ដាដកចេញពីកុងហ្គោនៅថ្ងៃទី៧ ខែឧសភា គេសង្ស័យថា កងទ័ពអ៊ូហ្គង់ដា បានចែកអាវុធទៅឲ្យកងជីវពល ហេម៉ា ដែលកំពុងតែរៀបចំខ្លួនកាន់កាប់តំបន់ប៊ូនីញ៉ា នៅពេលកងទ័ពអ៊ូហ្គង់ដាចំនួន៦ពាន់នាក់បានចាកចេញពីតំបន់នេះ ដែលប្រការនេះកើតចេញជាអំពើឃោរឃៅមួយឈុតឡើង ។

យោងតាមការសិក្សាដែលចេញផ្សាយដោយគណៈកម្មាធិការសង្គ្រោះអន្តរជាតិនៅក្នុងខែកុម្ភៈ យ៉ាងហោចណាស់មានប្រជាជនចំនួន៣លាន៣សែននាក់បានស្លាប់បាត់បង់ជីវិតដោយសារសង្គ្រាមនៅប្រទេសកុងហ្គោចាប់តាំងពីខែកុម្ភៈ ឆ្នាំ១៩៩៨ (ជាពេលដែលសង្គ្រាមផ្ទុះឡើងរហូតដល់ខែវិច្ឆិកា ឆ្នាំ២០០២) ។ ការស្ទាបស្ទង់មតិនេះត្រូវបានបញ្ចប់នៅឆ្នាំ២០០២ ។ លោក ហ្សុក វ៉ាប់ ប្រធានគណៈកម្មាធិការជួយសង្គ្រោះអន្តរជាតិ បាននិយាយថា "នេះគឺជាមហន្តរាយផ្នែកមនុស្សធម៌ ដែលគួរឲ្យខ្ពើមនិងគួរឲ្យរន្ធត់ ។ ចំនួនមនុស្សស្លាប់នៅក្នុងសង្គ្រាមអូសបន្លាយនៅអ៊ីរ៉ាក់ និងចំនួនមនុស្សស្លាប់នៅក្នុងសង្គ្រាមទាំងប៉ុន្មានដែលកើតឡើងថ្មីៗនេះនៅតំបន់បាល់កង់ ក៏មិនអាចយកមកប្រៀបផ្ទឹមបានដង ។ ប៉ុន្តែវិបត្តិនេះមិនសូវមានការយកចិត្តទុកដាក់ពីសំណាក់អ្នកផ្តល់ជំនួយអន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានប៉ុន្មានឡើយ" ។

កាលពីសប្តាហ៍មុន អគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ បានសរសេរលិខិតទៅកាន់សមាជិកក្រុមប្រឹក្សាសន្តិសុខទាំង១៥ សុំឲ្យពិចារណាក្នុងការបញ្ជូនកងទ័ពមួកខៀវទៅភាគបូព៌ានៃប្រទេសកុងហ្គោ ។ ប្រទេសបារាំងបានបង្ហាញសញ្ញាថាខ្លួនរៀបចំជាស្រេចដើម្បីបញ្ជូនកងកម្លាំងថែរក្សាសន្តិភាពមកកាន់សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ប្រសិនបើមានអាណត្តិច្បាស់លាស់ និងមានការចូលរួមសហការពីបណ្តារដ្ឋាភិបាលនានា ។ លោក ហ្វ្រង់ស្វ័រ រីវ៉ាសសូ អ្នកនាំពាក្យក្រសួងការបរទេសបារាំង បានមានប្រសាសន៍ថា "បារាំងមានឆន្ទៈចង់ចូលរួមពង្រឹងស្ថិរភាពដល់តំបន់ អ៊ីតុទូរី ហើយឥឡូវនេះយើងកំពុងតែសិក្សាស្វែងរកវិធីនានាក្នុងការចូលរួមនៅក្នុងកងកម្លាំងអន្តរជាតិ" ។

ចក្រភពអង់គ្លេសបានប្រកាសថា ខ្លួនក៏កំពុងតែគិតពិចារណាទៅលើសំណើរបស់លោក កូហ្វី អាណាន់ ដែលចង់បានកងកម្លាំងថែរក្សាសន្តិភាពចំនួន១ពាន់នាក់ដើម្បីបញ្ជូនទៅខេត្តអ៊ីតុទូរី ។ ឡេឌី អាម៉ូស លេខាថ្មីរបស់ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ បាននិយាយទៅកាន់កម្មវិធី "អាហារពេលព្រឹកក្រោមតំណក់សន្សើម" នៃទូរទស្សន៍ប៊ីប៊ីស៊ីថា "ចក្រភពអង់គ្លេសមានអាទិភាពច្បាស់លាស់ហើយ ពោលគឺត្រូវធ្វើការអំពីការដោះស្រាយជម្លោះនៅទ្វីបអាហ្វ្រិក ជាពិសេសនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ តែម្តង..." ។

យោងតាមសម្តីរបស់មន្ត្រីម្នាក់នៅការិយាល័យទទួលបន្ទុកបញ្ហាឧក្រិដ្ឋសង្គ្រាមនៃក្រសួងការបរទេសអាមេរិកសហរដ្ឋអាមេរិកមិនទាន់បញ្ចេញយោបល់អ្វីនៅឡើយទេ ទាក់ទងនឹងការបញ្ជូនកងទ័ពមកកាន់ប្រទេសកុងហ្គោ ប៉ុន្តែកំពុងតែពិនិត្យលើបញ្ហានេះឡើងវិញ ។ សហរដ្ឋអាមេរិកបានផ្តល់ថវិកាចំនួន២សែន៥ម៉ឺនដុល្លារទៅឲ្យគណៈកម្មាធិការសន្តិភាវកម្មដែលចាប់បដិសន្ធិឡើងនៅខែមេសា ។ គណៈកម្មាធិការនេះមានតួនាទីបង្កើតនូវអាជ្ញាធររដ្ឋបាលថ្នាក់មូលដ្ឋានថ្មីមួយនៅខេត្តអ៊ីតុទូរី និងបង្កើតរចនាសម្ព័ន្ធមួយដែលអាចទទួលយកបាន ដើម្បីថែរក្សា

ច្បាប់និងសណ្តាប់ធ្នាប់សាធារណៈក្នុងគោលបំណងធានាឲ្យមានការដកកងទ័ពរបស់អ៊ូហ្គង់ដាឲ្យអស់ពីទឹកដីកុងហ្គោ ។

## ការប្រាប់ឲ្យដឹងមុននូវអំពើប្រល័យពូជសាសន៍

អង្គការសហប្រជាជាតិមានកងទ័ពប្រមាណ៧រយនាក់នៅតំបន់នោះ ប៉ុន្តែខ្វះនូវគ្មានទាំងអាណត្តិនិងសម្ភារដើម្បីបញ្ឈប់ការប្រយុទ្ធគ្នានោះឡើយ ។ មន្ត្រីអង្គការសហប្រជាជាតិបានប្រាប់ជាមុនថានឹងមានមហន្តរាយផ្នែកមនុស្សធម៌ប្រសិនបើសហគមន៍អន្តរជាតិមិនបញ្ឈប់ការប្រយុទ្ធគ្នានេះទេ ។ យោងតាមទូរទស្សន៍ប៊ីប៊ីស៊ីបានឲ្យដឹងថា មន្ត្រីមួយចំនួនបាននិយាយថា មនុស្សឃាតថ្មីៗនេះ និងភាពតានតឹងនៅក្នុងតំបន់ មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងការចាប់ផ្តើមប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅប្រទេសរ៉ាន់ដានៅឆ្នាំ១៩៩៤ ។

ស៊ែជីអូ វៀរ៉ា ដឺមេឡូ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស បាននិយាយថា «ទោះបីជាសភាពការណ៍មានស្ថិរភាពនៅក្នុងប៉ុន្មានថ្ងៃកន្លងទៅនេះចាប់ពីពេលដែលក្រុមមានជម្លោះចូលមកចរចានឹងគ្នាក៏ដោយ ក៏គេមិនអាចបញ្ចៀសបាននូវអំពើរំលោភសិទ្ធិមនុស្ស និង(ប្រហែលជា)ជម្លោះប្រល័យពូជសាសន៍បានទេ លុះត្រាណាតែមានសមត្ថភាពធ្វើឲ្យខ្លាចរអាតាមរយៈការបង្កើតនូវរដ្ឋាភិបាលកណ្តាលមួយទើបទប់ទល់បាន» ។

ប្រសិនបើអំពើឃោរឃៅនៅក្នុងប្រទេសកុងហ្គោក្លាយទៅជាអំពើប្រល័យពូជសាសន៍ ច្បាប់មនុស្សធម៌អន្តរជាតិតម្រូវឲ្យមានតួអង្គអន្តរជាតិមកទប់ស្កាត់កុំឲ្យមានអំពើឃោរឃៅបន្តទៅទៀត និងកាត់សេចក្តីឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងតំបន់ ។ អនុសញ្ញាឆ្នាំ១៩៤៨ស្តីពីការទប់ស្កាត់និងផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឲ្យនិយមន័យនៃពាក្យអំពើប្រល័យពូជសាសន៍ ទោះបីជាប្រព្រឹត្តនៅក្នុងពេលមានសង្គ្រាម ឬសន្តិភាពក៏ដោយថា «អំពើណាមួយក្នុងចំណោមអំពើរៀបរាប់ខាងក្រោមនេះដែលប្រព្រឹត្តឡើងដោយមានចេតនាកម្ទេចទាំងស្រុង ឬដោយផ្នែក នូវក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ ដូចជាៈ មនុស្សឃាតទៅលើសមាជិកនៃក្រុម ការធ្វើឲ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬដល់សតិបញ្ញាសមាជិកនៃក្រុម ការធ្វើដោយចេតនាឲ្យក្រុមនេះទទួលរងនូវស្ថានភាពរស់នៅដែលនាំដល់ការបំផ្លិចបំផ្លាញក្រុមទាំងស្រុង ឬដោយផ្នែក, ការដាក់នូវវិធានការនានាដែលមានបំណងរារាំងមិនឲ្យមានការផ្តល់កំណើតទារក ការបញ្ជូនកុមារដោយបង្ខំពីក្រុមមួយទៅក្រុមមួយផ្សេងទៀត» ។

អនុសញ្ញាប្រល័យពូជសាសន៍ដាក់កំហិតដល់រដ្ឋជាភាគី «ក្នុងការទប់ស្កាត់និងផ្តន្ទាទោស» ការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ ភាគីនៃអនុសញ្ញាអាចដាក់ពាក្យបណ្តឹងទៅកាន់តុលាការអន្តរជាតិចោទប្រកាន់ថារដ្ឋជាភាគីមួយទៀតមានការទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ។ ករណីទីមួយដែលមានលក្ខណៈបែបនេះត្រូវបានប្តឹងប្រឆាំងនឹងយូហ្គោស្លាវីដោយបូស្នៀ-ហឺស៊ីហ្គោវីនណា នៅឆ្នាំ១៩៩៣ ហើយរឿងក្តីនេះកំពុងតែដំណើរការមិនទាន់ចប់នៅឡើយ ។

ទោះបីជាសន្ធិសញ្ញាមានកាតព្វកិច្ចចាប់បង្ខំទៅលើតែរដ្ឋដែលជាភាគីចុះសន្ធិសញ្ញាទាំងនេះក៏ដោយ ប៉ុន្តែនៅក្នុងការផ្តល់ជាប្រឹក្សាយោបល់នៅឆ្នាំ១៩៥១ ឃើញថាតុលាការអន្តរជាតិកត់សម្គាល់ឃើញថាគោលការណ៍នានាដែលសង្កត់ធ្ងន់ទៅលើអំពើប្រល័យពូជសាសន៍គឺជាផ្នែកមួយនៃច្បាប់ទម្លាប់អន្តរជាតិដែលភាគីទាំងអស់ត្រូវតែមានកាតព្វកិច្ចចាប់បង្ខំឲ្យអនុវត្តតាម ។

**ទីជីនី ឡាឌីស**

**កម្មវិធីឧក្រិដ្ឋសង្គ្រាម**

# ពាក្យស្លោកខ្មែរក្រហម

- ◆ ប្តេជ្ញាអនុវត្តមាគ៌ាដឹកនាំ និងធ្វើការងារតាមផែនការ និងតាមកម្មវិធីច្បាស់លាស់ ម៉ត់ចត់ជាច់ខាត។
- ◆ កម្ចាត់របៀបរបបដឹកនាំនិងធ្វើការងាររាយមាយ រយីករយាកប៉ាតណាបាតណី ប្រថុយប្រថាន គ្មានស្មារតីទទួលខុសត្រូវជាច់ខាត។
- ◆ ប្តេជ្ញាកសាងមោះមុត ធ្វើបដិវត្តសតិអារម្មណ៍តាមគោលជំហរវណ្ណៈអធននៅក្នុងបក្ស ជាច់ខាតនិងជាប់ជានិច្ច។

(ដកស្រង់ពីសៀវភៅទង់បដិវត្តលេខ៧-កក្កដា ១៩៧៦)

# ការអប់រំប្រវត្តិសាស្ត្ររបបខ្មែរក្រហម

យុវជនខ្មែរបច្ចុប្បន្នតែងតែលេចមុខនៅតាមប្រព័ន្ធផ្សព្វផ្សាយពត៌មានដោយសារជាប់ពាក់ព័ន្ធក្នុងបទឧក្រិដ្ឋកម្មនិងអំពើហិង្សាផ្សេងៗ មានដូចជាការឆក់ប្លន់ អំពើមនុស្សឃាត ការស៊ីផឹកពាលាអាវ៉ាសែ ការរំលោភ (រួមទាំងការរំលោភជាក្រុម ឬ “បូក”) ការវាយប្រហារគ្នាតាមចិញ្ចើមថ្នល់ និងដាក់ស្នែងការធ្វើកុប្បកម្មនៅទីក្រុងភ្នំពេញនាថ្ងៃទី២៩ មករា ឆ្នាំ២០០៣ កន្លងទៅថ្មីៗនេះ ។ បញ្ហាជនខ្លះបានស្តីបន្ទោសទៅលើកង្វះការយកចិត្តទុកដាក់របស់រដ្ឋាភិបាលនិងទៅលើប្រព័ន្ធអប់រំ ។ អ្នកខ្លះថាកម្ពុជាពុំមានបានសិក្សាស៊ីជម្រៅចំពោះបញ្ហាផ្លូវចិត្តរបស់យុវជនខ្មែរ ។

បណ្ឌិត នូ លក្ខិណា នាយកមហាវិទ្យាល័យមនុស្សសាស្ត្រនៃសកលវិទ្យាល័យកម្ពុជា បាននិយាយថា “កម្ពុជាមិនគួរផ្តោតអារម្មណ៍តែទៅលើអតីតកាលនោះទេ ប៉ុន្តែការបំភ្លេចអតីតកាលទាំងស្រុងជាការមិនទទួលខុសត្រូវ” ។ គាត់បានទាមទារឲ្យមានការស្រាវជ្រាវតាមបែបពិសោធនិយមទៅលើឥទ្ធិពលនៃសម័យខ្មែរក្រហមមកលើយុវជនខ្មែរសម័យបច្ចុប្បន្ន មុនការបង្កើតគោលនយោបាយថ្មីដើម្បីដោះស្រាយបញ្ហា ។

ខ្ញុំយល់ស្របតាមយោបលរបស់ បណ្ឌិត នូ លក្ខិណា ប៉ុន្តែខ្ញុំសូមបន្ថែមថា ការស្រាវជ្រាវតាមបែបពិសោធនិយមតែមួយមុខមិនគ្រប់គ្រាន់ទេ ។ ខ្ញុំមានជំនឿយ៉ាងមុតមាំថាខ្មែរក្រហមគឺជាបុព្វហេតុនៃភាពអវិជ្ជមានទាំងឡាយដែលកើតមាននៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ។ ដំណោះស្រាយទៅនឹងបញ្ហាដែលប្រទេសកម្ពុជាកំពុងជួបប្រទះ គឺការបញ្ចប់ជាស្ថាពរនូវបញ្ហាខ្មែរក្រហមតាមរយៈការកាត់ទោសអតីតមេដឹកខ្មែរក្រហមនៅក្នុងតុលាការយុត្តិធម៌មួយ និងសំខាន់បំផុតគឺការផ្តល់នូវការអប់រំប្រវត្តិសាស្ត្រសម័យខ្មែរក្រហមដល់សិស្សានុសិស្សនិងប្រជាជនទូទៅ ។

នៅក្នុងសម័យខ្មែរក្រហម យុវជន (អាយុពី១០ទៅ១៧ ឆ្នាំ) ត្រូវបានលើកតម្កើងយ៉ាងខ្ពង់ខ្ពស់ ថាជាសសរទ្រូងនៃបដិវត្តន៍ ។ យុវជនទាំងនេះត្រូវមេដឹកនាំខ្មែរក្រហមចាត់ទុកថាជាអនាគតនិងកំម្លាំងជំរុញពីក្រោយជោគជ័យរបស់បដិវត្តន៍ ។ ដោយមានជំនឿដូច្នេះហើយ ទើបមេដឹកនាំខ្មែរក្រហមបានតែងតាំងយុវជនឲ្យបម្រើការងារនៅគ្រប់ផ្នែកទាំងអស់នៅក្នុងប្រទេសដោយមានមុខតំណែងជាកម្មាភិបាល នីរសា អ្នកសួរចម្លើយ និងធ្វើទារុណកម្មនៅក្នុងមន្ទីរសន្តិសុខ (គុក) និង ពេជ្ឈឃាត ។ល ។ ដើម្បីឲ្យយុវជនទាំងនេះបំពេញការងាររបស់ខ្លួនដោយពេញចិត្ត និងទទួលបានទិន្នផលខ្ពស់ អង្គការបានប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ដើម្បីបំពាក់បំប៉នយុវជនឲ្យស្អប់ខ្ពើមសត្រូវបដិវត្តន៍ ឲ្យចេះសម្លាប់ និងឲ្យជ្រើសយកអំពើហិង្សាជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃរបស់ពួកគេ ។ ផ្ទុយទៅវិញ យុវជនផ្សេងទៀតដែលគ្រាន់តែជាយុវជនសាមញ្ញធម្មតា បានរស់នៅក្នុងពិភពមួយដែលពោរពេញទៅដោយភាពហិង្សា ហើយត្រូវទទួលរងនូវវិបត្តិផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ។

សព្វថ្ងៃនេះ យុវជនទាំងនេះ រួមទាំងយុវជនដែលជាអតីតកម្មាភិបាលខ្មែរក្រហមនិងយុវជនដែលជាប្រជាជនគឺជាអាណាព្យាបាលរបស់យុវជនកម្ពុជានាសម័យបច្ចុប្បន្នដែលជាប់ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋកម្មភាគច្រើនដែលកើតមានឡើងនៅក្នុងសង្គម ។

ចាប់ពីឆ្នាំ១៩៧៩ដល់ដើមទសវត្សរ៍ឆ្នាំ១៩៩០ សង្គ្រាមស៊ីវិលដ៏ឃោរឃៅ និងវិនាសសកម្មបានកើតឡើងរវាងខ្មែរក្រហម និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ សង្គ្រាមនេះបានបន្សល់ទុកនូវគ្រាប់មីនរាប់លានគ្រាប់នៅទូទាំងប្រទេសដែលកំពុងតែបន្តធ្វើទុក្ខបុកម្នេញដល់ប្រជាជនស្លូតត្រង់បច្ចុប្បន្នហើយធ្វើឲ្យដីស្រែចម្ការមួយភាគធំមិនអាចយកទៅប្រើប្រាស់បាន ។

ខ្ញុំបានចាប់កំណើតនៅឆ្នាំ១៩៨០ នៅក្នុងភូមិកំពង់ក្តី ខេត្តសៀមរាប ។ ទោះជាខ្មែរក្រហមត្រូវបានផ្តួលរលំទៅហើយក៏ដោយ ក៏ខ្មែរក្រហមនៅតែធ្វើឲ្យខ្ញុំ គ្រួសារខ្ញុំ និងប្រជាជនក្នុងភូមិ មានការភ័យខ្លាចជានិច្ចតាមរយៈការវាយប្រហារមកលើ

ភូមិឋានជាប្រចាំ ។ នៅពេលដែលបានទទួលដំណឹងពីអាជ្ញាធរខេត្តថាមានសភាពការមិនល្អ ម្តាយរបស់ខ្ញុំតែងតែដាស់តឿនខ្ញុំឲ្យហូបបាយពីក្បាលព្រលប់ ។

ខ្មែរក្រហមបានវាយប្រហារភូមិជាញឹកញាប់ ប៉ុន្តែជាច្រើនលើក ខ្មែរក្រហមមិនបានចូលដល់កណ្តាលភូមិទេ ។ ជួនកាល នៅពេលកំពុងតែមានការវាយប្រហារ អ្នកភូមិបានវាយចានឆ្នាំងនិងឧបករណ៍ផ្សេងទៀត ដើម្បីបន្លឺសំឡេងប្រកាសអាសន្ន ដោយសង្ឃឹមថាអាចបន្ទាចខ្មែរក្រហមឲ្យដកថយទៅវិញ ។ ខ្ញុំសួរម្តាយខ្ញុំថានោះជាសំឡេងអ្វីឮរំពងពេញភូមិដូច្នេះ ។ គាត់និយាយថា ប្រជាជនកំពុងធ្វើជាសញ្ញាបញ្ជាក់ឲ្យភូមិយើងត្រៀមខ្លួនជាស្រេចដើម្បីវាយតទល់ជាមួយខ្មែរក្រហម ។

នៅក្នុងរយៈពេលនៃការវាយប្រហារ អ្នកភូមិដែលរស់នៅក្បែរៗផ្ទះរបស់ខ្ញុំតែងតែពួនសម្ងំនៅក្បែរគ្នា ។ បុរសចំណាស់ៗខ្លះអាចប្រាប់យើងថាគ្រាប់ណាជាគ្រាប់ផ្លោងចេញ ហើយគ្រាប់ណាជាគ្រាប់ផ្លោងចូល ។ ចំណែកឯស្ត្រីចំណាស់ៗបានបន់ស្រន់ដល់ព្រះពុទ្ធជាម្ចាស់ឲ្យជួយការពារជីវិតរបស់ពួកយើងពីគ្រាប់កាំភ្លើង និងការរកឃើញរបស់ខ្មែរក្រហម ដោយសង្ឃឹមថាខ្មែរក្រហមនឹងដកថយទៅវិញយ៉ាងឆាប់រហ័ស ។

ទោះជាមានការវាយប្រហារជាញឹកញាប់ក៏ដោយ ក៏ខ្ញុំមិនដែលបានឃើញកងទ័ពខ្មែរក្រហមម្នាក់សោះឡើយ ។ អ្នកភូមិបានប្រាប់ខ្ញុំថា ខ្មែរក្រហមស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ ។ សម្តីនេះគឺងាយស្រួលនឹងស្វែងយល់ណាស់ ពីព្រោះថា ខ្មែរក្រហមនៅពេលនេះជានិមិត្តរូបនៃការភ័យខ្លាច ជាបិសាចដែលវះយកថ្លើមរបស់កុមារ ស៊ីសាច់មនុស្សជាអាហារ និងមានភ្នែកពណ៌ក្រហម ។

ជួនកាលខ្មែរក្រហមបង្កប់គ្រាប់មីននៅលើដងផ្លូវដើម្បីបំផ្លាញរថយន្ត ហើយប្រជាជនជាច្រើនត្រូវទទួលរងការឆក់ប្លន់នៅពេលកំពុងធ្វើដំណើរ ។ ពេលខ្លះខ្ញុំឮថាពួកខ្មែរក្រហមបានវាយលុកចូលដល់កណ្តាលភូមិជិតខាង ដែលប្រជាជនត្រូវទទួលរងការឆក់ប្លន់យកទ្រព្យសម្បត្តិ រំលោភ និងការធ្វើទារុណកម្មលើរាងកាយ ។

ដោយសារសេចក្តីភ័យខ្លាចបានធ្វើឲ្យឪពុកម្តាយខ្ញុំបានសម្រេចចិត្តរើទីលំនៅទៅទីរួមខេត្តសៀមរាប នៅអំឡុងឆ្នាំ១៩៨៩ ក្នុងគោលបំណងស្វែងរកទីលំនៅមួយដែលកាន់តែមានសុវត្ថិភាពរស់នៅ ទោះបីជាឪពុកម្តាយខ្ញុំពុំដឹងបានថាត្រូវចិញ្ចឹមជីវិតតាមវិធីណាក៏ដោយ ។

រឿងរ៉ាវខាងលើនេះគឺជាអ្វីដែលពលរដ្ឋកម្ពុជាអាយុប្រហាក់ប្រហែលខ្ញុំបានស្តាប់ឮកាលពីនៅក្មេង ។ ជាការពិតណាស់ អ្នកខ្លះបានទទួលរងនូវការធ្វើទុក្ខបុកម្នេញលើសពីខ្ញុំទៅទៀត ដូចជា អ្នកខ្លះមានសមាជិកគ្រួសារមួយចំនួនបាត់បង់ជីវិតនៅក្នុងពេលវាយប្រយុទ្ធគ្នា ។ នៅសាលារៀន យើងត្រូវបង្រៀនឲ្យចេះសូត្រ "បន ប៉ុល ពត, អៀង សារី និង ខៀវ សំផន" ហើយឲ្យដឹងគុណចំពោះកងទ័ពវៀតណាម ។

ជួនកាល មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលសំបុត្រពីសិស្សវិទ្យាល័យក្នុងគោលបំណងកែតម្រូវថា ចំនួនប្រជាជនដែលបានស្លាប់នៅក្នុងសម័យខ្មែរក្រហម គឺ៣លាននាក់ មិនមែនប្រហែលជា១,៧លាននាក់ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជា (តួលេខ១,៧លាន ជាតួលេខដែលត្រូវទទួលស្គាល់ជាអន្តរជាតិ និង មានភស្តុតាងបញ្ជាក់ច្បាស់លាស់) និងអ្នកស្រាវជ្រាវជាច្រើននាក់បានសន្និដ្ឋាននោះទេ ។ ហេតុអ្វី? ពីព្រោះថានេះជាចំណុចមួយដែលបានបញ្ជាក់នៅក្នុងសៀវភៅពុម្ពក្នុងកម្មវិធីសិក្សាមុនៗ ។

កម្ពុជាត្រូវតែចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម ពិភាក្សាគ្នា ហើយវិភាគឲ្យបានដិតដល់អំពីប្រវត្តិសាស្ត្រនេះ ។ យើងត្រូវតែផ្តល់នូវការអប់រំតាមបែបវិទ្យាសាស្ត្រអំពីផ្នែកនេះនៃប្រវត្តិសាស្ត្រកម្ពុជាដល់កូនខ្មែរជំនាន់ក្រោយ ។

**អេង កុកថាយ**

## ពន្យល់ពាក្យខ្មែរក្រហម

◆ **អារម្មណ៍:** គឺជាមែកធាងរបស់ចិត្តដែលនឹកឃើញអ្វីមួយ រូបីក្តី អរូបីក្តី ។

◆ **ពលករ:** អ្នកធ្វើការដោយកម្លាំងញើសឈាម មានតែបាតដៃទទេ ។

**(ដកស្រង់ពីសៀវភៅកំណត់ អ៊ីវ)**

# ដំណើរការយុត្តិធម៌ជូនជនរងគ្រោះនៃរបបខ្មែរក្រហម

ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរយៈពេលកម្ពុជាប្រជាធិបតេយ្យត្រូវបានប្រារព្ធឡើងនៅសាលសន្និសីទចតុមុខ កាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ។ ពិធីនេះបានប្រព្រឹត្តទៅក្រោមអធិបតីភាពឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារសម្រាប់សហប្រតិបត្តិការជាមួយអ្នកជំនាញច្បាប់បរទេសនិងរៀបចំដំណើរការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម និងលោក ហេន កូរ៉េល អគ្គ-លេខាធិការរងអង្គការសហប្រជាជាតិផ្នែកកិច្ចការច្បាប់ ទីប្រឹក្សាច្បាប់នៃអង្គការសហប្រជាជាតិ ។

ជនរងគ្រោះនៃរបបខ្មែរក្រហមនៅតាមជនបទដាច់ស្រយាលឯណោះវិញ មិនបានដឹងទាល់តែសោះអំពីរឿងនេះ ។ មួយចំនួនទៀតមិនទាំងបានដឹងថានឹងមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមផង ។ ដំណឹងដ៏មានសារសំខាន់បែបនេះដែលទាក់ទងទៅនឹងដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងមិនបានជ្រួតជ្រាបដល់ជនរងគ្រោះឡើយ ដរាបណាការយកចិត្តទុកដាក់ទៅលើបញ្ហានេះនៅតែមិនទាន់ត្រូវបានធ្វើឬធ្វើឡើងក្នុងទ្រង់ទ្រាយតូចនិងមិនជាប់លាប់ ។

មជ្ឈមណ្ឌលឯកសារកម្ពុជា មានក្រុមស្រាវជ្រាវចុះទៅធ្វើការងាររបស់ខ្លួននៅក្នុងខេត្តចំនួន៤ក្នុងប្រទេសកម្ពុជា លើកម្មវិធីជំរុញឲ្យមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាមធ្យមក្នុងមួយថ្ងៃជនរងគ្រោះនៃរបបខ្មែរក្រហមចំនួន១៦នាក់ ត្រូវបានក្រុមស្រាវជ្រាវជួបនិងធ្វើសម្ភាសទាក់ទិនទៅនឹងជីវិតរងគ្រោះម្យ៉ាងដោយមានសាច់សារលោហិតស្លាប់បាត់បង់ជីវិតបន្ទាប់ពីបានចូលបម្រើរបបផ្តាច់ការខ្មែរក្រហម និងម្យ៉ាងទៀតដោយធ្លាប់បានឆ្លងកាត់ការលំបាកផ្ទាល់ខ្លួននៅក្នុងរបបនោះ ។ មានចំនួនភាគតិចណាស់ដែលក្រុមការងារបានជួបសម្ភាសជាមួយឪពុក-ម្តាយដែលមានកូនស្លាប់បាត់បង់នៅក្នុងរបបខ្មែរក្រហម ដោយសារតែវ័យចាស់ជរាពេកមិនអាចរៀបរាប់ទុក្ខលំបាករបស់គាត់បាន និងដោយសារការស្លាប់បាត់បង់ជីវិតជាបន្តបន្ទាប់មុននឹងយុត្តិធម៌មួយត្រូវបានផ្តល់ជូនគាត់ ។

លោកតា កុល អាយុ៨០ឆ្នាំ ដែលអង្គុយនៅលើយ៉មុខខ្ទមដ៏រខេករខាកនិងប្រពន្ធជរាដេកនៅនឹងកន្ទេលដើរមិនរួច គ្មានអ្វីជាក្តីសង្ឃឹមទាល់តែសោះ ។ លោកតា កុល មានកូនប្រាំនាក់ចូលបម្រើរបបខ្មែរក្រហម ។ កូនរបស់គាត់ទាំង៥នាក់ ខ្លះស្លាប់ និងខ្លះទៀតបាត់ដំណឹងសូន្យឈឹងរហូតមកដល់ពេលនេះ ។ លោកតា កុល មិនមានសេសសល់កូនណាម្នាក់រស់នៅជាមួយគាត់ទេ មានតែអ្នកភូមិប៉ុណ្ណោះដែលជួយជាអង្ករ ម្ហូប និង


ហេន កូរ៉េល

ជួយរែកទឹកដាក់ពាងឲ្យគាត់គ្រាន់បានជម្រះកាយ ។ លើសពីនេះទៅទៀត លោកតា កុល មិនទាន់ទទួលបាននូវយុត្តិធម៌សម្រាប់ការបាត់បង់កូនទាំង៥នាក់របស់គាត់នៅឡើយ ។

អតីតយុទ្ធជននិងកម្មាភិបាលដ៏ច្រើនសន្ធឹកសន្ធាប់ដែលស្មោះស្ម័គ្រនឹងរបបខ្មែរក្រហមតាំងពីទសវត្សរ៍ឆ្នាំ១៩៧០ ត្រូវបានសម្លាប់ដោយសារតែភ័យខ្លាចថាមិនបានកាន់អំណាចយូរអង្វែងរបស់អតីតមេដឹកនាំខ្មែរក្រហមដែលកំពុងរស់រានមានជីវិតយ៉ាងមានសេរីភាពនៅឡើយក្នុងទឹកដីកម្ពុជា ។ អតីតយុទ្ធជននិងកម្មាភិបាលខ្មែរក្រហមជាច្រើនផ្សេងទៀតកំពុងស្ថិតក្នុងការបាត់ខ្លួននៅឡើយ ដែលកាលណោះគឺមេដឹកនាំខ្មែរក្រហមនោះឯងដែលជាអ្នករៀបចំគោលនយោបាយឃោសនាឲ្យអតីតយុទ្ធជននិងកម្មាភិបាលទាំងនោះចូលបម្រើរបបផងខ្លួន ។

រយៈពេល២៤ឆ្នាំនិង៦ខែ ហើយបើគិតមកដល់ខែកក្កដាឆ្នាំ២០០៣ ដែលយុត្តិធម៌មួយត្រូវរំពឹងថានឹងបានទទួលតាមរយៈការបង្កើតតុលាការពិសេសមួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលក្រោមការដឹកនាំរបស់មេៗទាំងនេះនៅអំឡុងឆ្នាំ១៩៧៥ដល់១៩៧៩ បានធ្វើឲ្យប្រជាជនកម្ពុជាស្លាប់បាត់បង់ជីវិតអស់រាប់លាននាក់ ។ ការអូសបន្លាយតទៅមុខទៀតក្នុងការផ្ដល់យុត្តិធម៌ជូនដល់ជនរងគ្រោះនៃរបបខ្មែរក្រហមមិនមែនជាដំណោះស្រាយល្អឡើយ ។


ឯកឧត្តម សុខ អាន

ផ្ទុយទៅវិញ បញ្ហាលំបាកស្មុគស្មាញប្រាកដជានឹងកើតមានកាន់តែច្រើន ។ ការដែលគ្មានជនសង្ស័យ(មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម) សម្រាប់ឲ្យតុលាការចោទប្រកាន់និងកាត់ទោសជាបញ្ហាចម្បងមួយ ។ ចំណែកឯការមិនបានផ្ដល់យុត្តិធម៌ឲ្យបានទាន់ដង្ហើមជនរងគ្រោះដោយផ្ទាល់នៅក្នុងរបបខ្មែរក្រហមក៏ជាបញ្ហាចម្បងមួយទៀតដែរ ។ នៅក្នុងឱកាសចុះហត្ថលេខាលើកិច្ចព្រមព្រៀង ឯកឧត្តម សុខ អាន បានអានបទទេសនាមជូនភ្ញៀវជាច្រើនរូបរួមមានឯកអគ្គរាជទូត(រដ្ឋទូត) បរទេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដោយមានការសន្យាមួយថា “ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជាផង ខ្ញុំសូមសន្យានៅចំពោះមុខព្រលឹងរបស់អ្នកដែលបានបាត់បង់ជីវិតទៅចំពោះមុខបងប្អូនសាច់ញាតិនិងមិត្តភក្តិរបស់អ្នកទាំងនោះនិងចំពោះមុខប្រជាជនទាំងអស់ដែលបានទទួលរងទុក្ខវេទនានៅក្នុងរយៈពេល៣ឆ្នាំ ៨ខែ និង២០ថ្ងៃថានឹងបន្តការខិតខំប្រឹងប្រែងរបស់យើងរហូតសម្រេចបានការកាត់ទោសតាមផ្លូវច្បាប់...នូវបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ” ។

លោក ហេន កូវែល ក៏បានអានសុន្ទរកថារបស់លោកដែលចុងក្រោយមានខ្លឹមសារថា “ប្រជាជនកម្ពុជាបានរង់ចាំជាយូរមកហើយ ចង់ឃើញការកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឃោរឃៅក្នុងកំឡុងពេលនោះក្នុងប្រវត្តិសាស្ត្រជាតិរបស់ខ្លួន ។ ការរង់ចាំរបស់ពួកគេមិនទាន់ដល់ទីបញ្ចប់នៅឡើយទេ ប៉ុន្តែសង្ឃឹមថា វាក៏នឹងជិតដល់ទីបញ្ចប់ផងដែរ” ។

លោកតា កុល សូមផ្ញើជោគវាសនានេះលើរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិជាលើកចុងក្រោយ ។

**ឌ៉ាន់ថាន់ ពៅដារ៉ា**

# ការយល់ឃើញរបស់ប្រជាជនកម្ពុជាចំពោះតុលាការខ្មែរក្រហម

## *សេចក្តីផ្តើម*

ប្រជាជនជាច្រើនហាក់ដូចជាមិនដឹងច្បាស់ ហើយស្ទើរតែមិនដឹង អំពីភាពឃោរឃៅនៅប្រទេសកម្ពុជាប្រព្រឹត្តឡើងនៅក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ។ ចាប់តាំងពីសង្គ្រាមលោកលើកទីពីរមក ពិភពលោកនេះឃើញមានកើតឡើងនូវអំពើឃោរឃៅ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាច្រើនករណី ប្រកបដោយសោកនាដកម្ម ក្នុងនោះមានប្រទេសកម្ពុជាមួយដែរដែលបានទទួលរងនូវអំពើនេះ ។ មានសោកនាដកម្មប្រហាក់ប្រហែលគ្នាកើតឡើងហ្កាតេម៉ាឡា ហៃទី សេរ៉ាឡេអូន រ៉្វាន់ដា អតីតយូហ្គោស្លាវីនិងប្រទេសដទៃទៀត ។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិង/ឬឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺជាការបំផ្លិចបំផ្លាញមនុស្សជាតិក្នុងទ្រង់ទ្រាយធំ រហូតដល់រាប់រយរាប់ពាន់ ឬមានដល់រាប់លាន ឬបានធ្វើឲ្យមានការឈឺចាប់នៅក្នុងរដ្ឋរៀងៗខ្លួនទៀតផង ។ ប៉ុន្តែករណីកម្ពុជា ព្រឹត្តិការណ៍នេះអូសបន្លាយរហូតជិតបួនឆ្នាំ ហើយចំនួនមនុស្សស្លាប់បាត់បង់ជីវិតនិងការឈឺចាប់បានធ្វើឲ្យករណីនេះក្លាយជាព្រឹត្តិការណ៍មួយក្នុងចំណោមព្រឹត្តិការណ៍ដ៏អាក្រក់បំផុតនៅក្នុងសតវត្សរ៍ទី២០ បន្ទាប់ពីពួកណាហ្ស៊ីនិយមរបស់អ៊ីត្លែរ និងការសម្លាប់ដ៏ឆ្កួតលីលារបស់ពួកហ៊ូទូមកលើក្រុមទុតស៊ីសនៅប្រទេសរ៉្វាន់ដា ។ ប្រវត្តិវិទូ ដេវីដ ឆេនដល័រ បានហៅព្រឹត្តិការណ៍នេះថា ជា«បដិវត្តន៍សន្ធោសន្ធៅ» និង «មានលក្ខណៈឃោរឃៅនិងវឹកវរបំផុតនៅក្នុងប្រវត្តិបដិវត្តន៍នាសតវត្សរ៍នេះ» ។ ហេតុដូចនេះហើយបានជាករណីកម្ពុជាត្រូវស្វែងយល់ឲ្យបានពេញលេញ សម្រាប់កត់ត្រាទុកជាប្រវត្តិសាស្ត្រនិងទប់ស្កាត់មិនឲ្យមានសោកនាដកម្មបែបនេះកើតឡើងសាជាថ្មី ។ ដោយសារមានសោកនាដកម្មទាំងនេះកើតឡើង ការវិវឌ្ឍន៍របស់ច្បាប់អន្តរជាតិ និងការប្រើតុលាការឧក្រិដ្ឋកម្មសង្គ្រាមក៏មានការលូតលាស់ដែរ ។ ទោះបីជាតុលាការឧក្រិដ្ឋកម្មសង្គ្រាមជាផ្នែកមួយរបស់នយោបាយអន្តរជាតិទូទៅទៅហើយក្តី ក៏តុលាការទាំងនោះព្រមជាមួយនឹងតុលាការអន្តរជាតិនានា អាចនៅតែគេចាត់ទុកថាស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការវិវឌ្ឍន៍ ។ តុលាការទាំងនេះមិនកើតឡើងញឹកញាប់ទេ ប៉ុន្តែនៅពេលកើតឡើងវាក៏មិនទទួលបានជោគជ័យតែរហូតនោះដែរ ។

រដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិអាចចរចាបញ្ហាបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមចាប់តាំងពីឆ្នាំ១៩៩៧មកម្ល៉េះ ។ ពេញអំឡុងពេលចរចានេះ ភាគីទាំងពីរសុទ្ធតែបានចូលរួមធ្វើឲ្យដំណើរការនេះប្រកបដោយភាពធុញទ្រាន់និងប្រកបដោយការរិះគន់យ៉ាងច្រើន ។ ការចរចាបានជួបវិបត្តិនៅពេលដែលអង្គការសហប្រជាជាតិដកថយឈប់ចរចាទាំងស្រុង ។ ទើបតែថ្មីៗនេះប៉ុណ្ណោះដែលមហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តលើសេចក្តីសម្រេចចិត្តព្រាងជំរុញឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ បន្តការចរចាឡើងវិញ ។ ទោះបីជាសេចក្តីសម្រេចនេះមិនមែនជាអាណត្តិផ្លូវការ ប៉ុន្តែវាបង្ហាញថាអាណត្តិនឹងមកដល់ក្នុងពេលឆាប់ៗនេះ ។ អត្ថបទនេះមានគោលបំណងពីរយ៉ាង ។ ទីមួយផ្តល់នូវព្រឹត្តិការណ៍ជុំវិញជាទ្រឹស្តីសម្រាប់សម្លឹងមើលទៅលើបញ្ហាខ្មែរក្រហម ហើយទីពីរគឺផ្តល់នូវការយល់ឃើញរបស់ប្រជាជនកម្ពុជាផ្ទាល់ទៅលើតុលាការនេះ ។ ការស្វែងយល់ជាលក្ខណៈទ្រឹស្តីទៅលើព្រឹត្តិការណ៍ជុំវិញនឹងដកស្រង់ចេញពីស្នាដៃនិពន្ធរបស់ ប៊ូណាថាន ហ្គារីបាស់ នៅក្នុងសៀវភៅរបស់លោកមានចំណងជើងថា “*Stay the Hand of Vengeance: The Politics of War Crimes Tribunals*” និងយកមកពីទ្រឹស្តីនយោបាយអន្តរជាតិជាមូលដ្ឋានមួយចំនួនទៀត ។ ដែលមូលហេតុថាប្រជាជនកម្ពុជាភាគច្រើនចង់បានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ប្រការដែលគាត់ចង់បានតុលាការនេះគឺមានមូលហេតុសំខាន់ពីរយ៉ាង ទីមួយគាត់ចង់ដឹងការពិត និងទីពីរចង់បានយុត្តិធម៌ ។ ជាមួយនឹងប្រធានបទនេះដែរ ទស្សនៈគំនិតកម្ពុជាទៅលើរដ្ឋាភិបាលរបស់ខ្លួននិងប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជាក៏នឹងត្រូវលើកមកពិនិត្យពិភាក្សា ។ ទោះបីជាវាជាការពិបាកក្នុងការនិយាយអំពីទស្សនៈគំនិតរបស់ប្រជាជនកម្ពុជាដោយសារភាព

ស្មុគស្មាញរបស់បញ្ហានេះយ៉ាងណាក៏ដោយ ក៏អត្ថបទនេះនឹងផ្តល់នូវការឆ្លុះបញ្ចាំងមួយផ្អែកទៅលើហេតុផលដ៏មានទម្ងន់មួយចំនួនថាហេតុអ្វីបានជាប្រជាជនកម្ពុជាចង់បានតុលាការនិងទទួលស្គាល់ថាមានមន្ទិលសង្ស័យមួយចំនួនទៅលើរដ្ឋាភិបាលនិងប្រព័ន្ធច្បាប់របស់ប្រទេសខ្លួន ។

## ទ្រឹស្តីនយោបាយស្តីអំពីតុលាការឧក្រិដ្ឋកម្មសង្គ្រាម

ការពិភាក្សាលើបញ្ហាបង្កើតតុលាការខ្មែរក្រហម ត្រូវដាក់នៅក្នុងប្រធានបទជាទ្រឹស្តីគឺជាការសំខាន់ ។ តាមវិធីនេះហើយដែលធ្វើឲ្យការពិភាក្សានេះអាចមើលឃើញក្នុងទ្រង់ទ្រាយធំហើយការអនុវត្តន៍ដ៏ទូលំទូលាយនៅក្នុងការបង្កើតឬមិនបង្កើតតុលាការនេះត្រូវបានយល់ឃើញ ។ នៅពេលដែលបញ្ហានានាមិនគួរត្រូវយកមកវិភាគត្រឹមតែតាមរយៈប្រតិកម្មឬអព្ពន្តរញ្ញាណប៉ុណ្ណោះទេ ប៉ុន្តែមានមូលដ្ឋានមួយចំនួនថាត្រូវតែពិនិត្យមើលទៅលើបញ្ហាតុលាការនេះដែរ ។ គឺដោយឈរលើមូលដ្ឋាននេះហើយដែលបញ្ហាខ្មែរក្រហមត្រូវបានលើកយកមកពិភាក្សាមុនបន្តូស់នៅក្នុងសៀវភៅនិពន្ធដោយ ចូណាថាន ហ្គារី បាស់ ។ បាស់បង្ហាញថា ទស្សនវិស័យសេរីនិយមផ្តល់នូវហេតុផលតក្កបំផុតនិងផលប្រយោជន៍ខ្លាំងជាងហេតុផលទស្សនវិស័យប្រាកដនិយមក្នុងការឲ្យមានតុលាការឧក្រិដ្ឋកម្មសង្គ្រាម ។ ទស្សនវិស័យប្រាកដនិយមមិនចង់ឲ្យមានតុលាការឧក្រិដ្ឋកម្មសង្គ្រាមទេ ។

ទីមួយៈ ការស្វែងយល់អំពីទ្រឹស្តីប្រាកដនិយមខ្លួនឯង មិនគួរស្វែងរកដើម្បីយល់ឲ្យកាន់តែច្បាស់អំពីទស្សីករណ៍នានាដែលចេញមកពីទ្រឹស្តីប្រាកដនិយមនេះទេ ។ ទ្រឹស្តីប្រាកដនិយមចាប់កំណើតមុនដំបូងបន្តូស់នៅប្រទេសក្រិចសម័យបុរាណ (ឆ្នាំ ៤១៣-៤០៤មុនគ្រិស្តសករាជ) ហើយទ្រឹស្តីនេះអាចរកឃើញនៅក្នុងស្នាដៃនិពន្ធរបស់ Thucydides, Machiavelli, Hobbes, Beitz និងទស្សនវិទូលោកធាតុផ្សេងៗទៀត ។ ទ្រឹស្តីប្រាកដនិយមឈរលើមូលដ្ឋានគំនិតដែលយល់ឃើញថា ឆាកអន្តរជាតិមានលក្ខណៈអានាធិបតេយ្យនិងស្ថិតនៅក្នុងសភាពធម្មជាតិ ។ សភាពអានាធិបតេយ្យមានន័យថា នៅក្នុងឆាកអន្តរជាតិគ្មានឋានានុក្រមទេ ហើយសភាពនេះសរសើរគំនិតដែលយល់ឃើញថាឆាកអន្តរជាតិគឺស្ថិតនៅក្នុងសភាពធម្មជាតិដែលក្នុងនោះរដ្ឋនីមួយៗធ្វើការដើម្បីតែផលប្រយោជន៍របស់ខ្លួនប៉ុណ្ណោះ ពីព្រោះថាសូម្បីតែជួយរដ្ឋមួយផ្សេងទៀតក៏អាចនាំឲ្យធ្លាក់ខ្លួនឯងនៅទីបញ្ចប់ ។ នៅក្នុងទ្រឹស្តីប្រាកដនិយមមានកន្លែងតូចណាស់ ឬក៏មិនមានផងសម្រាប់ធម្មចរិយា ។

តាមទស្សនៈបែបប្រាកដនិយមនេះឃើញថា មានទស្សីករណ៍ពីរសំខាន់ៗប្រឆាំងនឹងតុលាការឧក្រិដ្ឋកម្មសង្គ្រាម ដែលទស្សីករណ៍ទាំងពីរនេះគឺការព្យាយាមកាត់បន្ថយឬលុបបំបាត់ប្រតិកម្មចំពោះការរៀបចំឲ្យមានតុលាការឧក្រិដ្ឋកម្មសង្គ្រាម ។ ទស្សីករណ៍ទីមួយគឺថាកិច្ចខិតខំប្រឹងប្រែងទាំងនេះអាចបង្កជាសង្គ្រាមឡើង ។ នៅក្នុងករណីនេះ ពាក្យថា “សង្គ្រាម” នឹងត្រូវប្រើប្រាស់ចង់សំដៅទៅលើអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ទោះបីជាមិនមានសង្គ្រាមឬសង្គ្រាមស៊ីវិលក្តី វាពិបាកនឹងរកពាក្យមួយដែលពិពណ៌នាឲ្យបានត្រឹមត្រូវនូវអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ នៅក្នុងករណីខ្មែរក្រហម គឺវាមានរយៈពេល២៣ឆ្នាំទៅហើយចាប់តាំងពីខ្មែរក្រហមអស់អំណាចដូចនេះតុលាការឧក្រិដ្ឋកម្មសង្គ្រាមមិនអាចបង្កសង្គ្រាមបានទេ ពីព្រោះខ្មែរក្រហមអស់អំណាចជាយូរណាស់មកហើយ ។ ទោះជាទស្សីករណ៍នេះអាចកើតឡើងបន្តិចក្រោយពីមានសង្គ្រាមក៏ដោយ ក៏នៅក្នុងករណីខ្មែរក្រហម ទស្សីករណ៍នេះមិនកើតឡើងទេសព្វថ្ងៃ ។ អ្នកប្រាកដនិយមអាចទាញហេតុផលថា ខ្មែរក្រហមមិនអាចវិលត្រឡប់មកកាន់អំណាចបានទេ ប៉ុន្តែការអះអាងនេះពិបាករកអ្វីមកបញ្ជាក់បង្ហាញហើយក៏ពិបាកនឹងរិះគន់ដែរ ។ មិនត្រឹមតែ ប៉ុល ពត បានស្លាប់ទៅប៉ុណ្ណោះទេ ប៉ុន្តែស្ថានភាពជាក់ស្តែងរបស់ខ្មែរក្រហមក៏ពិបាកនឹងវាយតម្លៃ ។ ដូចនេះមានន័យថា ទោះបីជាខ្មែរក្រហមបានដួលរលំទៅហើយក្តី ក៏អាចនៅមានក្រុមផ្សេងទៀតដែលរៀបចំឡើងដើម្បីកាន់អំណាច ប៉ុន្តែប្រសិនបើមិនប្រមូលផ្តុំគ្នាទេអ្នកទាំងនោះមិនអាចបង្កសង្គ្រាមបានទេ ប៉ុន្តែអាចបង្កជាព្រឹត្តិការណ៍ដាច់ដោយឡែក ។

ទស្សីករណ៍ទីពីរមានលក្ខណៈត្រឹមត្រូវគួរសមដែលអះអាងថា តុលាការឧក្រិដ្ឋសង្គ្រាមអាចធ្វើឲ្យអស្ថិរភាពដល់កិច្ចខិតខំប្រឹងប្រែងក្រោយពេលសង្គ្រាមក្នុងការកសាងនូវសន្តិភាពមួយជាប់លាប់ ។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នៃរាជរដ្ឋាភិបាលកម្ពុជាបានទាញហេតុផលថា ប្រទេសកម្ពុជាអាចធ្លាក់ចូលទៅក្នុង

សង្គ្រាមស៊ីវិលប្រសិនបើមេដឹកនាំខ្មែរក្រហមមួយចំនួនដែលទទួលបានការលើកលែងទោសរួចហើយ នោះត្រូវនាំយកមកកាត់ទោស ។ ទោះបីជាខ្មែរក្រហមត្រូវបានផ្តួលរំលំពីអំណាចនៅឆ្នាំ១៩៧៩ ទៅហើយក្តី ប៉ុន្តែកាលនោះខ្មែរក្រហមនៅតែជាក្រុមខ្លាំងហើយបានកាន់កាប់តំបន់មួយចំនួននៃប្រទេសកម្ពុជា ជាពិសេសនៅជិតព្រំដែនថៃ ។ ចាប់តាំងពីឆ្នាំ១៩៩៧មកឃើញថា ខ្មែរក្រហមបានដួលរលំអស់ទៅហើយ ប៉ុន្តែវត្តមាននៃអង្គការចាត់តាំងមួយចំនួនអាចក្លាយជាបញ្ហា ។ លោក ថូម៉ាស់ ហាម៉ាប៊ឺក តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាកាលពីឆ្នាំ១៩៩៩ បានមានប្រសាសន៍ថា “ការព្រួយបារម្ភរបស់រដ្ឋាភិបាលដែលថា ការចាប់ខ្លួននិងការកាត់ទោស (មេដឹកនាំខ្មែរក្រហម) ប្រហែលជាអាចបង្កឲ្យមានការរំដើបរំជួល នោះគួរតែគិតគូរដោយយកចិត្តទុកដាក់ បើទោះជាវាមានលក្ខណៈផ្ទុយទៅនឹងការធានាជាផ្លូវការថាខ្មែរក្រហមត្រូវបានផ្តួលរំលំជាផ្លូវការហើយក្តី” ។ សរុបមក ការឲ្យហេតុផលដែលថាការជំនុំជម្រះក្តីអាចធ្វើឲ្យមានអស្ថិរភាពដល់សន្តិភាពនោះ ក៏នៅតែអាចលើកឡើងបានដដែល ប៉ុន្តែវាពិបាកនឹងធ្វើឲ្យទស្សនៈនេះមានទម្ងន់ ពីព្រោះ ទាំងអស់គ្នាដឹងច្បាស់ថា បើទោះជាមានវត្តមាននៃអង្គការចាត់តាំងរបស់ខ្មែរក្រហម គឺមានតិចតួចណាស់ ។

មានទស្សនៈតាមទ្រឹស្តីសេរីនិយមចំនួនប្រាំគាំទ្រឲ្យមានតុលាការឧក្រិដ្ឋកម្មសង្គ្រាម ។ ការប្រើពាក្យ“សេរី” នៅក្នុងករណីនេះចង់សំដៅទៅទស្សនៈគំនិតដែលមិនមែនជាទស្សនៈគំនិតរបស់អ្នកប្រាកដនិយម ។ ទស្សនៈនេះរួមមានធម្មចរិយារបស់ទ្រឹស្តីវិទូអំពីរដ្ឋ លោកធាតុវិទូ និងទ្រឹស្តីរបស់ ចន រ៉លស៍ ។ គោលការណ៍នៃទ្រឹស្តីទាំងនេះមាននៅក្នុងសំណេររបស់ ម៉ៃឃើល វ៉លហ្ស័រ ដើរ៉េមី បេនថាម ឪពុកនិងកូនគ្រួសារ មីលស៍, ចន រ៉លស៍ ដែលនិយាយខាងដើម ព្រមទាំងអ្នកនិពន្ធដទៃៗទៀត ។ ធម្មចរិយារបស់ទ្រឹស្តីវិទូអំពីរដ្ឋនិងរបស់លោកធាតុវិទូលោកធាតុ អាចហៅបានថាជាទ្រឹស្តីសេរីនិយមដោយហេតុថាទ្រឹស្តីទាំងនេះមានសារសំខាន់ចំពោះជីវភាពរស់នៅរបស់ប្រជាជន ។ ចំពោះធម្មចរិយារបស់ទ្រឹស្តីវិទូអំពីរដ្ឋគឺថា មានភារកិច្ចច្រើនជាងក្នុងការមើលការខុសត្រូវជនទាំងឡាយនៅក្នុងរដ្ឋមួយ ។ ចំពោះលោកធាតុវិទូវិញ មានភារកិច្ចមួយក្នុងការមើលការខុសត្រូវប្រជាជាតិទាំងអស់ដោយមិនគិតអំពីលក្ខខណ្ឌរបស់រដ្ឋឡើយ ។ ទ្រឹស្តីវិទូកើតចេញអំពីប្រពៃណីទាំងពីរប្រហែលជាអាចគាំទ្រដល់តុលាការខ្មែរក្រហម ពីព្រោះដើម្បីទទួលបាននូវការពន្យល់ឲ្យកាន់តែច្បាស់បន្ថែមទៀត តុលាការនេះអាចជួយបង្កើតបានជាបរិយាកាសរស់នៅកាន់តែប្រសើរសម្រាប់ប្រជាជន ដែលក្នុងបរិយាកាសនោះ ប្រជាជនទទួលបាននូវសន្តិភាព ហើយនៅក្នុងអនាគតទៀតសោត អំពើឃោរឃៅទាំងនោះមិនអាចកើតឡើងសាជាថ្មីបានឡើយ ។ តាមវិធីនេះជីវភាពរស់នៅនិងសុខមាលភាពរបស់ប្រជាជនត្រូវបានធានាមួយកម្រិតទៀត ។ ទ្រឹស្តីរបស់ ចន រ៉លស៍ ត្រូវបានបង្កើតឡើងនៅពេលដែល (ក្រោមវាំងនននៃអវិជ្ជា) រដ្ឋនានាសម្រេចអំពីថាតើឆាកអន្តរជាតិគួរតែដំណើរការទៅដោយគ្មានការដឹងច្បាស់ចំពោះស្ថានភាពរបស់ខ្លួនឯងប្រយ៉ាងដូចម្តេច ។ ឧទាហរណ៍នេះបង្ហាញថា រដ្ឋភាគច្រើនដែលប្រកាន់លទ្ធិសេរីនិយមនិងកាន់លទ្ធិដែលមិនសូវតឹងនិងមិនសូវធូរ អាចគាំទ្រតុលាការប្រសិនបើរដ្ឋនោះមានប្រជាជនទទួលរងនូវការសម្លាប់រង្គាល ។ ប៉ុន្តែប្រទេសដែលប្រហែលជាមិនគាំទ្រតុលាការ គឺជាប្រទេសដែលនៅក្រៅច្បាប់និងជាប់មានភារៈក្នុងការទទួលខុសត្រូវ ។

ទស្សនៈសេរីនិយមទាំងប្រាំដែលគាំទ្រតុលាការឧក្រិដ្ឋសង្គ្រាម និយាយអំពីការកសាងសន្តិភាពមួយដែលរឹងមាំ ។ ក៏ដូចជាសមភាគីប្រាកដនិយមដែរ មានទស្សនៈមួយចំនួនមិនអនុវត្តចំពោះករណីខ្មែរក្រហមទេ ។ ទស្សនៈសេរីនិយមទីមួយដែលគាំទ្រដល់តុលាការឧក្រិដ្ឋកម្មសង្គ្រាម គឺគំនិតដែលយល់ឃើញថាធ្វើយ៉ាងដូច្នេះ មេដឹកនាំដែលគំរាមកំហែងនឹងត្រូវបោសសម្អាត ។ ប្រការនេះមិនអនុវត្តច្រើនទេ ចំពោះករណីជាក់ស្តែងនៅប្រទេសកម្ពុជា នៅខណៈដែលអ្នកទាំងនោះដែលនឹងត្រូវនាំមកកាត់ទោសមិនស្ថិតក្នុងតួនាទីជាមេដឹកនាំប្រទេសបច្ចុប្បន្នឡើយ ។ ទោះបីមិនមែនជាមេដឹកនាំផ្លូវការក៏ដោយ អ្នកទាំងនោះអាចជាមេដឹកនាំអង្គការខ្មែរក្រហមក្រៅផ្លូវការ ។ អាចនិយាយបានថាតាមរយៈការបោសសម្អាតមេដឹកនាំខ្មែរក្រហម រាល់អង្គការចាត់តាំងរបស់ខ្មែរក្រហមបច្ចុប្បន្នប្រហែលជានឹងត្រូវធ្វើឲ្យចុះខ្សោយ ។

ទឡ្ហីករណ៍ទីពីរគឺថា តុលាការឧក្រិដ្ឋសង្គ្រាមធ្វើឲ្យឧក្រិដ្ឋជនសង្គ្រាមរាងចាល ។ និយាយជាទូទៅ ការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងធ្វើឲ្យបុគ្គលផ្សេងទៀតលែងហ៊ានចូលរួមប្រព្រឹត្តបទឧក្រិដ្ឋស្រដៀងគ្នានេះនៅថ្ងៃខាងមុខ ។ កន្លងមកធ្លាប់មានករណីដែលបុគ្គលមួយចំនួនផ្លាស់ប្តូរទង្វើរបស់ខ្លួនដោយសារការគំរាមកំហែងថានឹងត្រូវកាត់ទោស ប៉ុន្តែមិនដឹងថាខ្មែរក្រហមបានទទួលឥទ្ធិពលនេះដែរឬក៏យ៉ាងណានោះឡើយ ។ ក៏ប៉ុន្តែ ធម្មចរិយារបស់ទ្រឹស្តីវិទូអំពីរដ្ឋ ឬអ្នកគិតពីផលវិបាកលោកធាតុ នឹងទាញហេតុផលថា ប្រសិនបើរៀបចំតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងការពារពីម្នាក់ទៅម្នាក់កុំឲ្យទទួលគ្រោះថ្នាក់នៅថ្ងៃអនាគតនោះ យកល្អគួរតែធ្វើដូចនេះ ។ និយាយរួម ការទាញហេតុផលបែបនេះទាក់ទងទៅនឹងឥទ្ធិពលនាពេលអនាគតដែលថាតុលាការខ្មែរក្រហមនឹងចេញជារូបរាងឡើង ។

ទឡ្ហីករណ៍ទីបីដែលគាំទ្រតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមគឺថា តុលាការជួយស្តារនីតិសម្បទាដល់រដ្ឋទាំងឡាយដែលប្រព្រឹត្តអំពើអ្វីៗស្រេចតែទំនើងចិត្តរបស់ខ្លួន ។ ម្យ៉ាងទៀតសម្រាប់ករណីខ្មែរក្រហម ទឡ្ហីករណ៍នេះនឹងត្រូវកែតម្រូវ ។ ក្រៅពីរដ្ឋដែលធ្វើអ្វីតាមទំនើងចិត្ត ការរៀបចំតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមអាចជួយស្តារឡើងវិញនូវបក្សខ្មែរក្រហមផ្ទាល់ ប្រសិនបើមានបក្សនៅសល់រហូតដល់សព្វថ្ងៃ ។ ទាក់ទងនឹងចំណុចនេះគឺថារបបខ្មែរក្រហមបានដួលរលំតាំងពីយូរយារណាស់មកហើយ នៅពេលដែលការចរចាអំពីការបង្កើតតុលាការចាប់ផ្តើម ។ ប្រសិនបើតុលាការត្រូវបានយកមកគិតគូរតាំងពីដំបូងដៃ ម៉្លេះសមទឡ្ហីករណ៍នេះនឹងអនុវត្តចំពោះបញ្ហាខ្មែរក្រហមបានយ៉ាងសមស្រប ។

ទឡ្ហីករណ៍ទីបួននិងទីប្រាំប្រហែលជាទឡ្ហីករណ៍ដែលខ្លាំងបំផុតសម្រាប់ពេលបច្ចុប្បន្ន គាំទ្រដល់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ទឡ្ហីករណ៍ទីបួនគឺថាតាមរយៈការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម កំហុសនឹងត្រូវបានដាក់ទៅលើបុគ្គលនានាមិនមែនជនជាតិភាគតិចឡើយ ។ ក្នុងករណីខ្មែរក្រហម កំហុសនឹងត្រូវបង្វែរពីខ្មែរក្រហមទាំងអស់មកដាក់លើ «មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងកម្មាភិបាលថ្នាក់ក្រោមដែលមានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងអំពើឃោរឃៅធ្ងន់ធ្ងរបំផុត» ។ ជាការសំខាន់គឺត្រូវបែកឲ្យដាច់ពីគ្នារវាងអ្នកទាំងអស់ដែលបានចូលរួម និងអ្នកដែលទទួលខុសត្រូវចំពោះការកើតឡើងនៃអំពើឃោរឃៅនោះ ។ នៅក្នុងជួរខ្មែរក្រហមមានមេដឹកនាំមួយចំនួនដែលបញ្ជូនបទបញ្ជាទៅអាជ្ញាធរថ្នាក់ក្រោមបំផុតឲ្យអនុវត្តនិងសម្លាប់ ។ ស្ទើរតែគ្មានមន្ទិលសង្ស័យទេថា មេដឹកនាំខ្មែរក្រហមដឹងយ៉ាងច្បាស់អំពីផលវិបាកចេញពីបទបញ្ជារបស់ខ្លួននិងអ្វីដែលកំពុងតែកើតឡើង ។ ប្រសិនបើគ្មានមេដឹកនាំសំខាន់ៗទេ ក៏គ្មានអំពើគួរឲ្យខ្ពើមរអើមដូចនេះដែរ ។ ដោយសារតែវាជាភាពយុត្តិធម៌ក្នុងការដាក់កំហុសទៅលើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ទើបទឡ្ហីករណ៍នេះអនុវត្តចំពោះករណីខ្មែរក្រហមយ៉ាងប្រសើរ ។

ទឡ្ហីករណ៍ទីប្រាំគឺថា តុលាការឧក្រិដ្ឋសង្គ្រាមលាតត្រដាងនូវការពិតនៃអំពើឃោរឃៅនៅក្នុងពេលសង្គ្រាម ។ អ្នកប្រកាន់ទ្រឹស្តីសេរីនិយមទាញហេតុផលថា ការបដិសេធថាមិនមានអំពើឃោរឃៅគឺជាផ្នែកមួយនៃអំពើឃោរឃៅផ្ទាល់តែម្តង ។ ការបង្ហាញពីការពិតមិនត្រឹមតែជាទឡ្ហីករណ៍តាមបែបទ្រឹស្តីនិយមទេ ប៉ុន្តែគឺជាការបង្ហាញមួយដែលកើតឡើងដោយអំណាចអត្តនុ-ញាណ ដែលបញ្ហានេះនឹងលើកមកពិភាក្សាទាក់ទងនឹងគំនិតកម្ពុជា ។ លោក ឆាំង យុ ជាស្ថាបនិក និងជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បាននិយាយចំៗលើបញ្ហានេះ ។ នៅក្នុងកិច្ចសម្ភាសន៍មួយជាមួយ ភីតធ័រ ឡយ មកពីស្ថានីយ៍វិទ្យុនិងទូរទស្សន៍ អេ.ប៊ី.ស៊ី លោក ឆាំង យុ មានប្រសាសន៍ថា «**មិនមែនជាការផ្តន្ទាទោសទេ ប៉ុន្តែជាបញ្ហាបង្ហាញអំពីការពិតនៃការចាក់គ្រឹះសម្រាប់នីតិរដ្ឋ ។ វាជារឿងសម្រាប់អ្នករស់រានមានជីវិតក្នុងការវិនិច្ឆ័យ ដើម្បីគាត់អាចធ្វើដំណើរទៅមុខ អត់ទិនទោស បំភ្លេចនូវអ្វីដែលបានកើតឡើងកន្លងមក**» ។ ចំពោះលោក ឆាំង យុ ការបង្ហាញនូវការពិតគឺមានសារសំខាន់ជាងការផ្តន្ទាទោសចារីប្រព្រឹត្តបទល្មើសទៅទៀត ។ នៅក្នុងរបាយការណ៍សង្ខេបការងារសរសេរដោយលោក ភីតធ័រ ហេដឌ័រ អ្នកស្រាវជ្រាវជាន់ខ្ពស់អំពីបញ្ហាកម្ពុជា និងប្រេនទីតម័រ អ្នកជំនាញការច្បាប់ដែលសរសេរអត្ថបទមានចំណងជើងថា «បុគ្គលប្រាំពីររូបប្រឈមមុខនឹងការកាត់ទោសៈ ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយខ្មែរក្រហម» សរសេរថា «ការិយាល័យស្រាវជ្រាវឧក្រិដ្ឋកម្មសង្គ្រាមនិងការរួមគ្នាសម្រាប់

យុត្តិធម៌អន្តរជាតិសង្ឃឹមថានឹងចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែង របស់ប្រជាជនកម្ពុជាក្នុងការធានាឲ្យបាននូវវិធានការមួយចំនួន ដើម្បីរកយុត្តិធម៌ចំពោះអ្វីដែលប្រជាជនបានទទួលរង ក៏ដូចជា ចូលរួមដល់ការបង្កើតនូវឯកសារប្រវត្តិសាស្ត្រប្រកបដោយ សុក្រឹតភាព» ។ សារសំខាន់នៃការលាតត្រដាងការពិត ឆ្លុះបញ្ចាំង ឲ្យឃើញតាមរយៈសន្ទុះនិងល្បឿននៃការបង្កើតរបាយការណ៍ នេះ ។ កម្មវិធីសិក្សានេះចាប់ផ្តើមចេញពីគំនិតថា «គ្មានតុលាការ ក៏គ្មានការទទួលខុសត្រូវក្នុងការផ្តល់ឯកសារច្បាប់អំពីការសម្លាប់ រង្គាលនៅកម្ពុជាដែរ» ហើយថាតាមរយៈការផ្តល់នូវភ័ស្តុតាង បែបនេះ នឹងជួយកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ។ ការស្រាវ ជ្រាវចាប់ផ្តើមធ្វើឡើងនៅឆ្នាំ១៩៩៨ មួយឆ្នាំក្រោយពីកិច្ចចរចា ស្តីអំពីការបង្កើតតុលាការខ្មែរក្រហមបានចាប់ផ្តើម ហើយការ រកឃើញឯកសារត្រូវបានបោះពុម្ពផ្សាយយ៉ាងឆាប់រហ័សក្នុង រយៈពេលបីឆ្នាំក្រោយមក ។ របាយការណ៍នេះផ្តល់នូវភ័ស្តុតាង ច្បាស់លាស់បង្ហាញអំពីការចូលរួមរបស់មេដឹកនាំខ្មែរក្រហមនៅ ក្នុងការសម្លាប់ប្រជាជនកម្ពុជា ។ របាយការណ៍មិនត្រឹមតែបង្កើត ករណីប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមទេ ប៉ុន្តែដោយសារឯកសារ មិនទាន់បកប្រែនិងបោះពុម្ពផ្សាយ នោះក៏រួមចំណែកយ៉ាងច្រើន ដល់ការយល់ដឹងអំពីរបបខ្មែរក្រហមដែរ ។ ការស្រាវជ្រាវនិង បោះពុម្ពផ្សាយដោយភាពរហ័សបែបនេះបង្ហាញថាពត៌មាននេះ ពិតជាមានសារសំខាន់សម្រាប់តុលាការនិងសម្រាប់ការពិតខ្លួន ឯងតែម្តង ។ ដូចនេះ ទស្សីករណ៍សេរីនិយមក្នុងការលាតត្រដាង ការពិតបានចាប់ផ្តើមបញ្ចេញឲ្យឃើញខ្លួនឯងនៅក្នុងករណីខ្មែរ ក្រហម ។

សរុបមកវិញ វាហាក់ដូចជាថា ដើម្បីឲ្យទស្សីករណ៍បែប សេរីនិយមប្រឆាំងនឹងការរៀបចំតុលាការកាត់ទោសមេដឹកនាំ ខ្មែរក្រហម ត្រូវតែមានការស្រាវជ្រាវច្បាស់លាស់បន្ថែមទៀត អំពីអង្គការចាត់តាំងរបស់ខ្មែរក្រហមបច្ចុប្បន្នប្រសិនបើមាន ។ ផ្ទុយមកវិញ ទស្សីករណ៍បែបសេរីនិយមបានចាប់ផ្តើមបង្ហាញខ្លួន ឯងរួចហើយ ហើយហាក់ដូចជាមានលទ្ធភាពផ្តល់នូវទស្សីករណ៍ល្អ បំផុត និងមានប្រយោជន៍បំផុតសម្រាប់ប្រជាជនកម្ពុជា និងពិភព លោកទាំងមូល ។ ក្នុងវិធីនេះវាហាក់ដូចជាថា ទស្សីករណ៍បែបសេរី និយមមានលក្ខណៈរឹងមាំជាងទស្សីករណ៍បែបប្រាកដនិយម ដែល អាស្រ័យលើស្ថានភាពតាមសម្មតិកម្មមួយចំនួន ។

## ទស្សនៈកម្ពុជា
## ការពិត យុត្តិធម៌ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រព័ន្ធច្បាប់កម្ពុជា

គឺដោយសារមូលហេតុជាក់ស្តែងបែបនេះហើយ បានជា យើងគួរយកគំនិតរបស់កម្ពុជាមកគិតពិចារណានៅពេលពិភាក្សា បញ្ហាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ដូចដែល ប្រជាជនកម្ពុជាស្ទើរតែទាំងអស់ដែលរស់នៅសព្វថ្ងៃធ្លាប់ឆ្លង កាត់ ឬក៏គ្រួសាររបស់គាត់ធ្លាប់ជួបប្រទះសោកនាដកម្មរបស់ខ្មែរ ក្រហមយ៉ាងដូច្នេះដែរ គឺអ្នកទាំងនេះហើយដែលរស់នៅទាំង កម្សត់កម្រនិងមានអារម្មណ៍ផ្សេងៗពីនេះដែលបណ្តាលមកពី ការរំលោភបំពាន និងការស្លាប់បាត់បង់ជីវិតកើតឡើងនៅក្នុងរបប ខ្មែរក្រហម ។ ប្រជាជនកម្ពុជាមិនត្រឹមតែបានស៊ូទ្រាំទប់អារម្មណ៍ សោកសង្រេងប៉ុណ្ណោះទេ តែថែមទាំងត្រូវរស់នៅដោយប្រឈម មុខនឹងការលំបាកផ្នែកសេដ្ឋកិច្ច នយោបាយ និងសង្គមទៀតផង ដែលទាំងអស់នេះសុទ្ធតែបន្សល់ទុកដោយរបបខ្មែរក្រហម ។ ជីវិត របស់ប្រជាជនកម្ពុជាសព្វថ្ងៃគឺជាលទ្ធផលដោយផ្ទាល់ចេញពី របបខ្មែរក្រហម ។ ទោះបីជាយើងអាចនិយាយបានថាប្រជាជន កម្ពុជាគាំទ្រតុលាការខ្មែរក្រហមក៏ពិតមែន ប៉ុន្តែហេតុផលគាំទ្រ តុលាការនេះមានលក្ខណៈស្មុគស្មាញណាស់ ។ វាមានលក្ខណៈ ស្មុគស្មាញមិនត្រឹមតែជាមួយទស្សនៈនយោបាយប៉ុណ្ណោះទេ ប៉ុន្តែ ទាក់ទងនឹងអារម្មណ៍ដក់ជាប់ក្នុងចិត្ត ទស្សនៈបែបវប្បធម៌និង សាសនាថែមទៀតផង ។ ហេតុផលទាក់ទងនឹងអារម្មណ៍ ទាក់ទង នឹងវប្បធម៌ និងសាសនា ពិតជាពិបាកយល់ឲ្យបានច្បាស់ណាស់ ។ អាចយល់បានទាល់តែអានឲ្យបានច្រើន ទាក់ទងនឹងចិត្តវិទ្យា សតិ-អារម្មណ៍សង្គមកម្ពុជា ព្រះពុទ្ធសាសនា និងបើអាចទៅរួចគ្រិស្ត សាសនា ។ ជាទូទៅ ប្រជាជនកម្ពុជាក៏មានសាវតារជាតិផ្សេងៗ ពីគ្នា ហើយកើតក្នុងជំនាន់ផ្សេងៗពីគ្នា ។ ផ្នែកមួយនៃអត្ថបទនេះ នឹងផ្តោតសំខាន់ទៅលើវិធីពីរយ៉ាងដែលសឹងតែនិយាយថាជាហេតុ ផលសម្រាប់រៀបចំឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ពីព្រោះវាជាហេតុផលគ្មានការប្រទាញប្រទង់និងមានលក្ខណៈ

ដូចៗគ្នាដែលប្រជាជនកម្ពុជាភាគច្រើនបានលើកឡើង ។ ហេតុផលទាំងពីរនេះគឺការពិតនិងយុត្តិធម៌ ។ ហេតុផលពីរយ៉ាងនេះក៏ទាក់ទងទៅនឹងបញ្ហាថាតើប្រជាជនកម្ពុជាយល់ឃើញយ៉ាងដូចម្តេចចំពោះសុចរិតភាពរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងរដ្ឋាភិបាលរបស់ខ្លួន ព្រមទាំងប្រព័ន្ធច្បាប់កម្ពុជា ។ ប្រធានបទនេះក៏នឹងត្រូវលើកមកពិភាក្សាផងដែរ ។ ជាការគួរឲ្យសោកស្តាយ មានតែទស្សនៈរបស់ប្រជាជនកម្ពុជានៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះដែលបានលើកមកពិភាក្សាពេលនេះ ។

**ក) ការពិត**

ការស្វែងរកការពិតមានសារសំខាន់នៅក្នុងកម្រិតមួយដែលអំពើឃោរឃៅនៅក្នុងរបបខ្មែរក្រហមអាចត្រូវបានចងក្រងជាឯកសារឲ្យបានពេញលេញជាផ្លូវការ ជួយកាត់បន្ថយការឈឺចាប់ដល់អ្នកដែលរស់រានមានជីវិតចាកផុតពីរបបនោះនិងចុងក្រោយគឺជួយផ្តល់នូវរឿងរ៉ាវពេញលេញជាអចិន្ត្រៃយ៍មួយសម្រាប់យុវវ័យជំនាន់ក្រោយស្វែងយល់ ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាជនជាតិខ្មែរមួយរូបក្នុងចំណោមជនជាតិខ្មែរដទៃទៀតដែលហ៊ាននិយាយចំៗ ទាក់ទងនឹងបញ្ហាខ្មែរក្រហម ។ សាវតារជាតិរបស់លោកធ្វើឲ្យលោកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ឲ្យលោកនិយាយរឿងនេះ ។ ក្រោយពីមករស់នៅសហរដ្ឋអាមេរិកប្រមាណជិតពីរទសវត្សរ៍ លោកបានត្រឡប់មកប្រទេសកម្ពុជាវិញ ចាប់ផ្តើមចងក្រងឯកសារដែលអាចរកបានទាក់ទងនឹងរបបខ្មែរក្រហម ។ មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលខុសត្រូវខាងប្រមែប្រមូលឯកសារថែរក្សា និងផ្សព្វផ្សាយឯកសារទាក់ទងនឹងមន្ទីរទួលស្លែងរបស់ខ្មែរក្រហម ឯកសារខ្មែរក្រហមទូទៅ និងស្រាវជ្រាវតួលេខអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម ដែលកំពុងតែដំណើរការមិនទាន់ចប់នៅឡើយ ។ ទាក់ទងនឹងការស្វែងរកការពិត លោក ឆាំង យុ មានប្រសាសន៍នៅក្នុងកិច្ចសម្ភាសន៍ជាមួយ ភីតធ័រ ឡយ ថា “**វាមិនមែនជារឿងផ្តន្ទាទោសទេ ប៉ុន្តែវាជារឿងលាតត្រដាងនូវការពិត**” ។ ជាការច្បាស់ណាស់ថា គំនិតនេះគួរតែយកមកគិតគូរពិចារណា ។ តុលាការនៅនូរ៉ឹមប៊ឺក បានលាតត្រដាងនូវឯកសាររបស់បក្សណាហ្ស៊ីរបស់អាល្លឺម៉ង់ ចំណែកតុលាការកាត់ទោសខ្មែរក្រហមក៏នឹងលាតត្រដាងនូវឯកសាររបស់ខ្មែរក្រហមដែរ ។ តុលាការនេះមិនមែននិយាយអំពីការគុំគួនសងសឹករបស់អ្នករស់រានមានជីវិតចាកផុតពីរបបខ្មែរក្រហមទេ ប៉ុន្តែតុលាការនេះនឹងជួយផ្តល់នូវចម្លើយទៅនឹងសំណួរដ៏សំខាន់ ។ ប្រជាជនកម្ពុជានិងប្រជាជនទូទៅគ្រាន់តែចង់ដឹងថាតើមានអ្វីខ្លះកើតឡើងកាលពីសម័យនោះ ។

រឿងរ៉ាវដែលអ្នកសល់ពីស្លាប់បាននិទានឡើងទាក់ទងនឹងសម័យខ្មែរក្រហម គឺមានលក្ខណៈកម្សត់ប្រហាក់ប្រហែលគ្នា ។ វាជារឿងរ៉ាវឈឺចាប់ ប៉ុន្តែឈឺចាប់លើរាងកាយនោះវាមានកម្រិតតិចទេ ។ ផ្ទុយមកវិញ រឿងរ៉ាវឈឺចាប់ខ្លាំងគឺនៅត្រង់ថាបាត់បង់គ្រួសារ និងការនឹកមិនឃើញសមាជិកគ្រួសារត្រូវនាំយកទៅសម្លាប់ចោលនៅចំពោះមុខខ្លួនយ៉ាងច្បាស់ក្រឡែត ។ សោកនាដកម្មនេះបាននិងកំពុងតាមលងប្រជាជនកម្ពុជាអស់ជាច្រើនឆ្នាំមកហើយ ។ តម្លៃជីវិតមនុស្សមិនអាចកាត់ថ្លៃបានឡើយ ។ ប្រជាជនប្រមាណ១ម៉ឺន៧ពាន់នាក់ត្រូវបានចាប់មកធ្វើទារុណកម្មនៅទីក្រុងភ្នំពេញ ។ ជុំ ម៉ី អាយុ៦៩ឆ្នាំ ជាជាងជួសជុលរថយន្ត ត្រូវចាប់មកដាក់នៅទួលស្លែងអស់រយៈពេល៦ខែ ។ ក្រោយពីឮដំណឹងថាអង្គការសហប្រជាជាតិឈប់ចរចាអំពីរឿងបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមកាលពីចុងខែកុម្ភៈកន្លងទៅ ជំងឺសម្រាន្តមិនលក់បានមកយាយីលើរូបគាត់សាជាថ្មី ។ នៅក្នុងអត្ថបទមួយចុះផ្សាយនៅក្នុងកាសែតវ៉ាស៊ីនតោនប៉ុស្តិ៍ ជុំ ម៉ី និយាយថា “សុបិនអាក្រក់បានមកយាយីជីវិតខ្ញុំទៀតហើយ” ។ មានតែតុលាការទេដែលអាចបណ្តេញខ្មោចបិសាចចេញពីអារម្មណ៍របស់គាត់ “ប៉ុន្តែប្រសិនបើគ្មានយុត្តិធម៌ មនុស្សដូចជារូបខ្ញុំនេះនឹងទទួលរងទារុណកម្មជារៀងរាល់ថ្ងៃ” ។ អ្នកដែលសល់ពីស្លាប់នៅក្នុងរបបខ្មែរក្រហម មានជំងឺផ្នែករាងកាយនិងស្មារតីមកដល់សព្វថ្ងៃ ។ ជំងឺនេះកាន់តែរើខ្លាំងឡើងនៅពេលអ្នកប្រព្រឹត្តអំពើអាក្រក់មកលើអ្នកដែលនៅរស់ទាំងនោះ មិនត្រូវដាក់ឲ្យទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនតាមផ្លូវច្បាប់ ។ កាន់តែឈឺចាប់ជាងនេះទៅទៀតនោះ គឺគាត់រស់នៅជាមួយអ្នកដែលមានចំណែកទទួលខុសត្រូវនៅក្នុងរបបខ្មែរក្រហម ហើយគាត់មិនអាចធ្វើអ្វីអ្នកទាំងនោះបាន ។ ដូចមនុស្សម្នាក់បាននិយាយថា សម្លាប់មនុស្សមួយម៉ឺននាក់ងាយស្រួលនឹងរួចខ្លួនជាងសម្លាប់មនុស្សតែម្នាក់ទៅ

ទៀត ។ ករណីនេះហាក់បីដូចជាករណីរបស់ខ្មែរក្រហមដូច្នេះដែរ ។ គ្មានអ្នកណាអាចរៀបរាប់ឲ្យអស់នូវភាពអយុត្តិធម៌ដែលកើតឡើងចំពោះប្រជាជនកម្ពុជាទេ ។ ចំពោះប្រជាជនកម្ពុជារាប់លាននាក់នៅក្នុងនិងក្រៅប្រទេសកម្ពុជា វាហាក់ដូចជាថាប្រជាជនទាំងនោះសមតែទទួលបានយ៉ាងហោចណាស់នូវការឆ្លើយតបមួយចំនួនពីជនទាំងឡាយដែលមានការទទួលខុសត្រូវខ្ពស់បំផុត ។

ទិដ្ឋភាពមួយទៀតក្នុងការស្វែងរកការពិតដែលអាចមានលក្ខណៈពិបាកសម្រាប់ឲ្យអ្នកបស្ចិមប្រទេសយល់គឺថា ការស្វែងរកការពិតមិនត្រឹមតែសម្រាប់ជនរងគ្រោះដែលបានរួចចាកផុតពីរបបខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែការពិតសម្រាប់អ្នកដែលបានស្លាប់បាត់បង់ជីវិតដែរ ។ នៅក្នុងប្រទេសកម្ពុជា វិស្សមកាលមួយដែលចាត់ទុកថាជាវិស្សមកាលសំខាន់ជាងបុណ្យចូលឆ្នាំប្រពៃណីជាតិទៀតនោះគឺបុណ្យភ្ជុំបិណ្ឌ ។ នៅក្នុងពិធីបុណ្យភ្ជុំបិណ្ឌ ប្រជាជនកម្ពុជាយកម្ហូបចំណីទៅប្រគេនព្រះសង្ឃនៅវត្តនិងបោះបាយបិណ្ឌនៅព្រះវិហារដើម្បីឧទ្ទិសកុសលដល់ញាតិសន្តានដែលបានលាចាកលោកទៅ ។ នៅតាមគេហដ្ឋានរបស់អ្នកកាន់ព្រះពុទ្ធសាសនាយើងមិនត្រឹមតែឃើញធូប ទៀន ទឹក និងម្ហូបអាហារនៅរានអ្នកតាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឃើញរូបថតពាក់កណ្តាលខ្លួនរបស់អ្នកដែលទទួលអនិច្ចកម្មទៀតផង ។ ទង្វើនេះគឺជាការបង្ហាញនូវការយកចិត្តទុកដាក់ទៅលើអ្នកដែលទទួលមរណភាព ។ ពុទ្ធសាសនិកកម្ពុជាមិនភ្លេចសមាជិកគ្រួសារដែលទទួលមរណភាពទេ ផ្ទុយទៅវិញគេនឹកគិតស្ទើរតែរៀងរាល់ថ្ងៃ ។ នៅថ្ងៃចងកំហឹង (២០ ឧសភា) ប្រជាជនកម្ពុជាបានប្រមូលផ្តុំគ្នានៅទូទាំងប្រទេសកម្ពុជាដើម្បីរំឭកដល់វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ គោលបំណងសំខាន់នៃទិវាចងកំហឹងនេះគឺធ្វើឡើងសម្រាប់រំឭកម្តងហើយម្តងទៀត ឲ្យកាត់ទោសមេដឹកនាំខ្មែរក្រហមដែលទទួលខុសត្រូវចំពោះបទប្រល័យពូជសាសន៍និងឧទ្ទិសបួងសួងបញ្ជូនកុសលដល់អ្នកដែលលាចាកលោកទៅ ។ មានប្រជាជនជាច្រើនបានអញ្ជើញទៅជើងឯកដែលជាវាលពិឃាតល្បីជាងគេនៅកម្ពុជា ។ ឆ្នាំចុងក្រោយនេះមានប្រជាជនប្រមាណបីពាន់នាក់ បានមានវត្តមាននៅវាលពិឃាតដែលមានចម្ងាយប្រហែល១៥គីឡូម៉ែត្រភាគខាងត្បូងរាជធានីភ្នំពេញ ។

នៅទីនេះមានស្តូបសាមញ្ញមួយដែលមានពណ៌ប្រផេះធ្វើអំពីស៊ីម៉ងត៍ដាក់កញ្ចក់ព័ទ្ធជុំវិញ ផ្ទុកទៅដោយលលាដ៍ក្បាលនិងសម្លៀកបំពាក់របស់សាកសពប្រមាណ៩ពាន់ ដែលត្រូវបានរកឃើញនៅក្បែរៗបរិវេណវត្តជើងឯក ។ វត្តនេះមិនសូវខ្ពស់ប៉ុន្មានទេបើប្រៀបធៀបទៅនឹងអគារនានានៅក្នុងទីក្រុង ។ ស្តូបជើងឯកមានកម្ពស់ពីរជាន់ គ្របដណ្តប់នៅលើវាលស្មៅលើទីទួលជម្រាល ។ ស្តូបជើងឯក និងរណ្តៅសាកសពដែលគាស់រួចហើយ ជាមួយនឹងដើមឈើមួយដើមមានដីដែកគោលដែលនិយាយអំពីរឿងរ៉ាវដែលខ្មែរក្រហមយកក្មេងទៅបោកក្បាលកម្ទេចមុនពេលបោះចូលទៅក្នុងរណ្តៅសាកសពរួមនោះ គឺជាការរំឭកតូចមួយនៃព្រឹត្តិការណ៍គួរឲ្យព្រឺព្រួចដែលបានកើតឡើងនៅក្នុងទីតាំងនេះ ។ ទីតាំងវាលពិឃាតជើងឯកមើលពីចម្ងាយមានលក្ខណៈដូចគ្នាទៅនឹងទីតាំងស្ងប់ស្ងៀមនានានៅក្នុងប្រទេសកម្ពុជាដែរ ។ នៅអំឡុងពិធីបុណ្យភ្ជុំបិណ្ឌ ឯកឧត្តម ជា សុផារ៉ា (អតីត) អភិបាលរាជធានីភ្នំពេញដែលបានបាត់បង់ញាតិសន្តានអស់២៧នាក់រួមទាំងម្តាយបង្កើតផង បានឈរនិយាយនៅវាលពិឃាតនេះថា “គ្មានអ្វីគួរឲ្យសង្ស័យទេថា មេដឹកនាំខ្មែរក្រហមត្រូវតែនាំយកមកកាត់ទោសចំពោះមុខច្បាប់ បើមិនដូច្នេះទេវិញ្ញាណក្ខន្ធរបស់ជនរងគ្រោះនឹងមិនទៅកាន់សុគតិភពឡើយ” ។ គំនិតរបស់ប្រជាជនកម្ពុជាក្នុងការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមមិនត្រឹមតែកាត់បន្ថយការឈឺចាប់របស់ប្រជាជនផ្ទាល់ប៉ុណ្ណោះទេ តែកាត់បន្ថយការឈឺចាប់របស់ញាតិសន្តានរបស់ខ្លួនដែលបានស្លាប់បាត់បង់ជីវិតទៀតផង ។ តាមការយល់ឃើញផ្សេងៗទៀតឃើញថា វាហាក់ដូចជាថាការឈឺចាប់របស់ញាតិសន្តានដែលបានស្លាប់បាត់បង់ជីវិតសំខាន់ជាងការឈឺចាប់របស់ខ្លួនទៅទៀត ពីព្រោះថាគឺអ្នកដែលស្លាប់បាត់បង់ជីវិតទាំងនោះហើយដែលបានបាត់បង់ច្រើនជាងគេ និងបាននាំចាកផុតពីពិភពនេះ ។ សំខាន់ដែរនោះពីព្រោះថាជនរងគ្រោះដែលស្លាប់បាត់បង់ជីវិតទៅហើយនោះលែងមានសំឡេងទៀតហើយ ពោលគឺវាអាស្រ័យតែនៅលើអ្នកដែលនៅរស់រានមានជីវិតតែប៉ុណ្ណោះដែលជួយរកការពិតនិងយុត្តិធម៌ដល់ខ្លួន ។ ការស្វែងរកការពិតមិនត្រឹមតែនាំយកជនដែលមានការទទួលខុសត្រូវមកផ្តន្ទាទោសប៉ុណ្ណោះទេ តែធ្វើឲ្យប្រាកដថារឿងរ៉ាវ

របស់អ្នកដែលបានស្លាប់បាត់បង់ជីវិតពិតជាត្រូវបានលើកមកនិយាយប្រាប់ទៅអ្នកផ្សេងទៀតឲ្យដឹងនូវអ្វីដែលកើតឡើងចំពោះគាត់ ។ ប៉ ហេង បាននាំកូនប្រុសឲ្យចូលរួមនៅថ្ងៃបុណ្យនោះដែរ ដើម្បីបង្ហាញឲ្យកូនប្រុសរបស់គាត់ដឹងនូវការឈឺចាប់ដែលគាត់បានទទួលរងកាលពីជំនាន់មុន ហើយឲ្យកូនបានឃើញជាក់ស្តែងដូចដែលគាត់បាននិយាយប្រាប់កូនកន្លងមកអំពីបញ្ហាខ្មែរក្រហមដែលបានសម្លាប់បងប្រុសរបស់គាត់ ។ គីម ប៊ុនធំ កម្មការិនីធ្វើការនៅទីក្រុងភ្នំពេញជំរុញឲ្យ “រដ្ឋាភិបាលស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនរាប់លាននាក់ដែលទទួលរងគ្រោះ” ដោយស្នាដៃខ្មែរក្រហម ។ ប៊ុនធំ កំពុងនិយាយអំពីអ្នកដែលចាកផុតពីរបបខ្មែរក្រហមនិងអ្នកដែលមានតែលលាដ៍ក្បាលតម្រៀបនៅក្នុងវត្តដែលនៅតែខោអាវរាយប៉ាយនៅតាមមាត់រណ្តៅតូចៗនិងនៅតាមបណ្តោយផ្លូវលំនៅទីតាំងវាលពិឃាត ។ មានតុលាការរកយុត្តិធម៌ឲ្យមិនមែនសម្រាប់តែប្រយោជន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមតែប៉ុណ្ណោះទេ ។

ការស្វែងរកការពិតមិនត្រឹមតែនាំមកនូវសន្តិភាពសម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែផ្តល់នូវការយល់ដឹងដល់យុវវ័យជំនាន់ក្រោយឲ្យដឹងនូវអ្វីដែលបានកើតឡើង ។ លោក ឆាំង យុ មានប្រសាសន៍នៅក្នុង Times Educational *Supplement* ថា “មិនសូវមានអ្នកជឿពីរឿងនេះទេ ។ កុមារាកុមារីជាច្រើនមិនជឿនូវអ្វីដែលបានកើតឡើងកន្លងមកទេ ។ កុមារាកុមារីទាំងនោះមិនជឿថាកូនហ៊ានសម្លាប់ឪពុកម្តាយខ្លួនឯងនោះទេ” ។ កុមារីមួយរូបដែលមិនចង់បញ្ចេញឈ្មោះ បាននិយាយនៅឱកាសប្រារព្ធពិធីទិវាចងកំហឹងនៅជើងឯកថា “ខ្ញុំមិនសូវដឹងរឿងខ្មែរក្រហមប៉ុន្មានទេ ប៉ុន្តែខ្ញុំដឹងអត្ថន័យប្រល័យពូជសាសន៍នេះដោយសារខ្ញុំរៀននៅសាលា ។ ជនណាក៏ដោយឲ្យតែទទួលខុសត្រូវពីបទប្រល័យពូជសាសន៍ ត្រូវតែនាំមកកាត់ទោស ដើម្បីកុំឲ្យអំពើនេះកើតឡើងជាថ្មីទៀត” ។ តាមសម្តីរបស់កុមារីរូបនេះបង្ហាញថា អ្វីដែលបានកើតឡើងត្រូវតែធ្វើឲ្យសាធារណជនដឹងឮហើយសារសំខាន់នៃការដឹងនេះមិនមែនដើម្បីត្រឹមតែដឹងប៉ុណ្ណោះទេ តែដើម្បីធានាថាប្រវត្តិសាស្ត្រនេះនឹងមិនវិលថយក្រោយម្តងទៀតឡើយ ។ ដែកឃី ន័រដាម មកពីវិទ្យុ National Public Radio និយាយអំពីហេតុផលនិងក្តីសង្ឃឹមមួយចំនួនដែលលើកឡើងដោយណេលី ប៉េលួ មកពីក្រុមការងារសិទ្ធិមនុស្សលីកាដូថា “...ការពិតទាក់ទងនឹងសម័យខ្មែរក្រហមមិនត្រូវបានបង្រៀននៅតាមសាលារៀនទេ ហើយនិយាយទៀតថាតុលាការនឹងអាចចងក្រងជាឯកសារអំពើឃោរឃៅដើម្បីកុំឲ្យភ្លេច” ។ ដោយសាររបបខ្មែរក្រហមមិនមែនជាប្រធានបទសិក្សាស៊ីជម្រៅនៅតាមសាលារៀន ឬប្រហែលមានបង្រៀនដែរ តែមានកម្រិតតិចបំផុតនោះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមគឺជាវិធីមួយសម្រាប់ផ្សព្វផ្សាយព័ត៌មាន ជាពិសេសសម្រាប់យុវវ័យជំនាន់ក្រោយ ។ ការស្វែងរកការពិតមិនមែនសម្រាប់តែជនរងគ្រោះដែលនៅរស់និងស្លាប់ប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់អ្នកដែលអាចមិនធ្លាប់បានដឹងរឿងរ៉ាវដែលអ្នកចាស់ទុំក្នុងគ្រួសារមិនដែលនិយាយប្រាប់ទៀតផង ។ រឿងរ៉ាវទាំងនេះគឺសម្រាប់កូនរបស់កុមារាកុមារីសព្វថ្ងៃ និងតកូនតចៅទៅរហូត ។ ម្យ៉ាងវិញទៀតវិធីនេះមានលក្ខណៈដូចគ្នាទៅនឹងរបៀបដែលប្រជាជនកម្ពុជាស្វែងរកការពិតសម្រាប់អ្នកដែលបានស្លាប់បាត់បង់ជីវិតផង ។ ជាវិធីស្វែងរកការពិតសម្រាប់អ្នកដែលមិនទាន់កើត ហើយការស្វែងរកការពិតមិនមែនសម្រាប់តែក្រុមណាមួយឡើយ ប៉ុន្តែសម្រាប់ប្រជាជនកម្ពុជាទូទៅដែលបានទទួលនិងត្រូវទទួលឥទ្ធិពលពីរបបខ្មែរក្រហមនៅថ្ងៃអនាគត ។ ណេលី ប៉េលួ និយាយបន្ទាប់មកទៀតថា “ខ្ញុំគិតថាវាជាការសំខាន់ចំពោះយើងគ្រប់គ្នាដើម្បីដឹងអំពីប្រវត្តិសាស្ត្ររបស់យើង ទោះជាប្រវត្តិសាស្ត្រនោះល្អក្តីអាក្រក់ក្តី ។ យើងចាំបាច់ត្រូវដឹងថាយើងជានរណា” ។ អ្នកស្រីចង់និយាយថា ប្រជាជនកម្ពុជានៅតែព្យាយាមស្វែងយល់អត្តសញ្ញាណរបស់ខ្លួន ប្រវត្តិរបស់ខ្លួន និងប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួន ។ ការស្វែងរកការយល់ដឹងបែបនេះគឺមិនមានតែមួយជំនាន់ទេ ។ ផ្ទុយទៅវិញ ការស្វែងរកនេះនឹងបន្តទៅថ្ងៃមុខដ៏យូរអង្វែងនិងច្រើនជំនាន់ទៀត ។ មានតុលាការដើម្បីលាតត្រដាងការពិតនឹងធ្វើឲ្យការស្រាវជ្រាវកាន់តែឆាប់រហ័សនិងកាន់តែងាយស្រួល ។ ប៉ ហេង ក៏និយាយនៅទិវាចងកំហឹងទាក់ទងនឹងកូនប្រុសរបស់គាត់ថា “ពេលនេះខ្ញុំចង់ឲ្យកូនខ្ញុំឃើញដោយផ្ទាល់ភ្នែកនូវការឈឺចាប់ដែលមនុស្សជំនាន់យើងបានឆ្លងកាត់” ។ មនោសញ្ចេតនានេះហើយដែលដក់ជាប់ក្នុងចិត្ត

អ្នករួចផុតពីរបបខ្មែរក្រហមគ្រប់ៗរូប ។

ហេតុផលក្នុងការស្វែងរកការពិតទាំងអស់នេះប្រៀបដូចជាការផ្សះផ្សារបួសអ្នកដែលរួចចាកផុតពីរបបខ្មែរក្រហម ការនាំមកនូវភាពស្ងប់អារម្មណ៍របស់អ្នកដែលបាត់បង់ជីវិតទៅ និងការផ្តល់ឯកសារសម្រាប់កូនចៅជំនាន់ក្រោយ ទាំងអស់នេះបានពួនផ្គុំគ្នានៅក្នុងគំនិតសាមញ្ញមួយបញ្ជាក់ថា អំពើឃោរឃៅទាំងនេះមិនគួរបំភ្លេចចោលឡើយ ។ ដែកឃី ន័រដាម និយាយថា "តុលាការនឹងត្រូវបានចងក្រងជាឯកសារដើម្បីកុំឲ្យភ្លេច" ។ នៅក្នុងការស្រាវជ្រាវជាច្រើនបញ្ហាដែលលើកឡើងដូចៗគ្នាទាក់ទងនឹងប្រជាជនកម្ពុជាគឺថា គេចង់ឲ្យប្រជាជនដឹងអំពីប្រវត្តិ-សាស្ត្ររបស់ខ្លួន ។ ប្រជាជនកម្ពុជាភាគច្រើនចង់ចែករំលែកនូវអ្វីៗដែលបានកើតឡើងចំពោះខ្លួន ដើម្បីរក្សាទុកជាឯកសារប្រវត្តិសាស្ត្រ ។ ការទទួលរងនូវការរំលោភបំពានរួចហើយក៏បំភ្លេចចោល ការដែលមានមនុស្សស្លាប់ជាងមួយលាននាក់រួចហើយបំភ្លេចអ្នកដែលស្លាប់បាត់បង់ជីវិតទាំងនោះ និងគំនិតយល់ឃើញថា យុវវ័យជំនាន់ក្រោយពុំមានអ្វីដែលត្រូវបំភ្លេចនោះគឺជាការគិតដ៏គួរឲ្យភ័យខ្លាចនិងសោកស្តាយ ។ ដោយសារប្រវត្តិសាស្ត្រត្រូវតែរកឲ្យឃើញ ចងក្រងទុក និងរក្សាទុកដើម្បីទប់ស្កាត់កុំឲ្យកើតឡើងសាជាថ្មី ដូចនេះវាស៊ីគ្នាខ្លាំងណាស់ជាមួយនឹងករណីកម្ពុជា ។ សព្វថ្ងៃនេះ ប្រវត្តិសាស្ត្រខ្មែរក្រហមកំពុងតែត្រូវបានស្វែងរកហើយ ។

### ៧) យុត្តិធម៌

យុវសិស្ស គាប វិបុត្រ អាយុ១៧ឆ្នាំ បាននិយាយនៅក្នុងទិវាចងកំហឹងនៅពេលអង្គុយជិតម្តាយបង្កើតមានអាយុ៥៨ឆ្នាំ ឈ្មោះ ប៉ ហេង នៅជិតរណ្តៅសាកសពរួមថា "ខ្ញុំខឹងណាស់នៅពេលបានឃើញពេលនេះ ។ តើយុត្តិធម៌នៅឯណាទៅ?" ។ នេះគឺជាសំណួរដែលមានប្រជាជនកម្ពុជាជាច្រើនរូបបានចោទឡើង ។ គំនិតនៃពាក្យយុត្តិធម៌គឺថាអ្នកដែលទទួលខុសត្រូវ គួរតែនាំយកមកកាត់ទោសចំពោះមុខច្បាប់ ។ គឺគំនិតយុត្តិធម៌នេះហើយដែលនឹងត្រូវលើកមកនិយាយ នៅក្នុងអត្ថបទនេះពីព្រោះថានេះគឺជាអ្វីដែលគេតែងតែនិយាយ នៅពេលដែលគេនិយាយអំពីយុត្តិធម៌ ។ ក៏ប៉ុន្តែដោយសារតែការបម្រើឲ្យយុត្តិធម៌អាស្រ័យទៅលើប្រព័ន្ធច្បាប់ដែលតុលាការបិតក្នុងការប្រតិបត្តិទស្សនៈរបស់ប្រជាជនកម្ពុជាចំពោះរដ្ឋាភិបាលរបស់ខ្លួនឯងនោះគឺសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងប្រព័ន្ធច្បាប់កម្ពុជានឹងត្រូវលើកមកពិភាក្សាដែរ ។ នៅក្នុងករណីខ្មែរក្រហមការទទួលខុសត្រូវទាំងនោះគឺជាការទទួលខុសត្រូវចំពោះការស្លាប់របស់ប្រជាជនកម្ពុជាចំនួន១លាន៧សែននាក់ក្នុងរយៈកាលជាង៣ឆ្នាំ ។ ការបង្កើតឡើងនូវតុលាការគឺដើម្បីស្វែងរកការពិតនិងដាក់ឲ្យទទួលខុសត្រូវចំពោះការសម្លាប់រង្គាល ។ ដោយសារតែគោលបំណងនៃការកាត់ទោសទាំងឡាយគឺការស្វែងរកការពិត និងដាក់ទោសអ្នកដែលប្រព្រឹត្តខុស ដូច្នេះគោលបំណងរបស់តុលាការកាត់ទោសខ្មែរក្រហមនិងមូលហេតុដែលប្រជាជនកម្ពុជាគាំទ្រឲ្យមានតុលាការក៏ដូចគ្នា ។

ការអាក់អន់ចិត្តមួយរបស់ប្រជាជនកម្ពុជា គឺយុត្តិធម៌ដូចជាត្រូវបានប្តូរកំពុងធ្វើឡើងនៅក្នុងប្រទេសផ្សេងៗដែលបានជួបប្រទះរឿងប្រល័យពូជសាសន៍ ដូចជានៅរ៉្វាន់ដា សេរ៉ាឡេអូន និងអតីតយូហ្គោស្លាវី ប៉ុន្តែតុលាការនោះបានមានជិត២៥ឆ្នាំទៅហើយចាប់ពីអំពើឃោរឃៅរបស់ខ្មែរក្រហមបានកើតឡើង ។ ដែកឃី ជុត នៃវិទ្យុជាតិសាធារណៈ និយាយឡើងវិញអំពីគំនិតរបស់លោក ឡៅ ម៉ុងហៃ (អតីត) នាយកស្ថាប័នខ្មែរដើម្បីប្រជាធិបតេយ្យ "ឡៅ និយាយថា គាត់មិនយល់ហេតុអ្វីបានជាចង់ឲ្យមានយុត្តិធម៌ដើម្បីកាត់ទោសចំពោះភាពឃោរឃៅនៅបូស្នៀនិងរ៉្វាន់ដា ប៉ុន្តែបែរជាមិនអាចឲ្យកម្ពុជាមានយុត្តិធម៌ទៅវិញ" ។ លោក ឆាំង យុ សរសេរថា "***នៅសេរ៉ាឡេអូន អង្គការសហប្រជាជាតិកំពុងតែជួយដល់ការស្ថាបនាតុលាការពិសេសនិងសូម្បីតែនៅពេលក្រោយអតីតដើមកំណើតនៃរបបប្រល័យពូជសាសន៍ប្រទេសស៊ែប៊ីធំ បានសម្រេចនិរទេសអ្នកដែលទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដ៏យង់ឃ្នងដែលបានប្រព្រឹត្តនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ...ទាំងពីរបានជាប់ចោទពីបទជាឧក្រិដ្ឋជនសង្គ្រាម***" ។ និយាយពីភ្ញៀវម្នាក់ទៀតនៅក្នុងកម្មវិធីវិទ្យុ ដែកឃី ន័រដាម និយាយបន្តថា "គ្រូបង្រៀន សាក់ សមប៊ូន យល់ស្រប ។ គាត់បានចំណាយពេល៤ឆ្នាំ ដឹកព្រែកទាំងឡាយ នៅក្នុងសម័យខ្មែរក្រហម ហើយម្តាយរបស់គាត់និងបងប្អូនពីរនាក់ត្រូវមេដឹកនាំ

ខ្មែរក្រហមសម្លាប់» ហើយក្រោយមកទៀត សាក់ និយាយថា «ប្រជាជននៅក្នុងប្រទេសកម្ពុជាត្រូវការយុត្តិធម៌ខ្លាំងណាស់» ។ ការគិតរបស់លោក សាក់ សមប៊ូន បង្ហាញនូវភាពលំបាកវេទនាដ៏អយុត្តិធម៌ដែលគាត់ខំអត់ធ្មត់ និងប្រាប់ពីការស្លាប់របស់គ្រួសារគាត់ដោយសារតែខ្មែរក្រហម ។ វាបង្ហាញថា គាត់ក៏ដូចជាប្រជាជនកម្ពុជាដទៃទៀតបានឆ្លងកាត់យ៉ាងលំបាកប៉ុនណា ប៉ុន្តែគ្មានអ្វីត្រូវបានធ្វើដើម្បីដាក់ទោសអ្នកដែលប្រព្រឹត្តនោះនៅឡើយ ។ គាត់បានបញ្ជាក់ថា ប្រជាជនកម្ពុជាទាំងអស់មានតម្រូវការយុត្តិធម៌នេះ ។

ការចង់បានយុត្តិធម៌នេះត្រូវធ្វើឡើងឲ្យមានការគាបសង្កត់ថែមទៀត ដោយសារតែពេលវេលាកន្លងទៅតាំងពីភាពឃោរឃៅនៃរបបខ្មែរក្រហមបានកើតឡើង ។ ដែកឃី ន័រដាម នៃ NPR និយាយពីភ្ញៀវម្នាក់ដែលបាននិយាយតាមរយៈអ្នកបកប្រែម្នាក់ថា «វ៉ាន់ ណាត បាននិយាយថា គាត់រង់ចាំយុត្តិធម៌អស់ជាង ២៣ឆ្នាំហើយ ហើយទើបតែមានមេដឹកនាំខ្មែរក្រហមជាប់ឃុំឃាំងតែពីរនាក់ប៉ុណ្ណោះ» ។ សេចក្តីដកស្រង់ពីបទសម្ភាសន៍របស់វិទ្យុ និងទូរទស្សន៍អេ.ប៊ី.ស៊ី ជាមួយលោក ឆាំង យុ មានប្រសាសន៍ថា «***ឥឡូវនេះគឺជាពេលដែលកម្ពុជាបង្ហាញការយកចិត្តទុកដាក់របស់ខ្លួនចំពោះការនាំយកខ្មែរក្រហមទៅកាត់ទោសហើយ***» ។ ជិត២៥ឆ្នាំទៅហើយ គួរតែល្មមដល់ពេលបញ្ចប់រឿងរ៉ាវកាត់ទោសអ្នកដែលទទួលខុសត្រូវចំពោះអ្វីដែលបានកើតឡើង ។

ទោះបីជាយុត្តិធម៌ចាំបាច់សម្រាប់ប្រជាជនកម្ពុជាក៏ដោយ ក៏វាត្រូវការស្តង់ដារអន្តរជាតិដែរ ។ ដូចជាទស្សនៈបែបសេរីនិយមថា តុលាការបំភ័យឧក្រិដ្ឋជនសង្គ្រាមផ្សេងទៀត ពេលដែលមានតុលាការកាត់ក្តីមួយបង្ហាញទៅចំពោះពិភពលោកទាំងមូលថាឧក្រិដ្ឋជនមិនអាចរួចខ្លួនពីអំពើឃោរឃៅរបស់គេបែបនេះបានឡើយ ។ ផ្ទុយទៅវិញ រដ្ឋាភិបាលកម្ពុជាត្រូវមានកាតព្វកិច្ចចំពោះប្រជាជនរបស់ខ្លួន និងសហគមន៍អន្តរជាតិដើម្បីឆ្លើយតបនឹងការចង់បានតុលាការអន្តរជាតិមួយ ។ លោក ឆាំង យុ មានប្រសាសន៍ថា «***គឺច្បាស់ទៅហើយដែលថាខ្មែរក្រហមក៏រំលោភច្បាប់អន្តរជាតិដែរ ដូច្នេះវាជាកាតព្វកិច្ចចំពោះសហគមន៍អន្តរជាតិដែលរដ្ឋាភិបាលនោះត្រូវតែទទួលខុសត្រូវ***» ។ ប៉ុន្តែប្រជាជនកម្ពុជាក៏បានដឹងដែរថា សហគមន៍អន្តរជាតិអាចដើរតួនាទីកាន់តែធំជាងនេះទៅទៀត គឺការស្វែងរកយុត្តិធម៌ ។ នៅក្នុងអត្ថបទមួយរបស់កាសែតវ៉ាស៊ីនតោនប៉ុស្តិ៍ លោក ឆាំង យុ មានប្រសាសន៍ថា «***ឲ្យមេខ្មែរក្រហមទាំងអស់នេះគេចផុតពីការវិនិច្ឆ័យគ្រាន់តែជាការពិចារណាដ៏គួរឲ្យឈឺចាប់មួយប៉ុណ្ណោះ ។ តើឲ្យឃាតករសម្លាប់មនុស្សច្រើនថ្នាក់នេះរួចខ្លួនយ៉ាងម៉េចនឹងកើត? តើរដ្ឋាភិបាលរបស់យើងបណ្តោយឲ្យរឿងនេះកើតឡើងម៉េចនឹងបាន? តើពិភពលោកបណ្តោយឲ្យវាកើតដោយរបៀបណា?***» ។ ទស្សនៈរបស់ប្រជាជនកម្ពុជាចំពោះតុលាការកាត់ក្តីមួយមិនត្រឹមតែរិះគន់រដ្ឋាភិបាលផ្ទាល់របស់ខ្លួនតែប៉ុណ្ណោះទេ នៅមានសហគមន៍អន្តរជាតិថែមទៀត ។

ទោះបីជាមានការស្នើសុំឲ្យស្វែងរកយុត្តិធម៌តាមរយៈតុលាការក៏ដោយ ក៏វាបានបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ទៅហើយថា ប្រជាជនកម្ពុជាសុំឲ្យតុលាការកាត់ក្តីដោយត្រឹមត្រូវនិងយុត្តិធម៌ ។ នៅក្នុងបទសម្ភាសន៍ជាមួយវិទ្យុ NPR លោក ឡៅ ម៉ុងហៃ និយាយថា «គ្មានការកាត់ក្តីប្រសើរជាងមានការកាត់ក្តីមិនត្រឹមត្រូវ ។ តើចំណុចសំខាន់នៃការកាត់ក្តីគឺប្រសិនបើវាមិននាំមកនូវយុត្តិធម៌ពិតប្រាកដទេនោះ?» ។ លោក សម រង្ស៊ី មេដឹកនាំផ្ទាល់នៃគណបក្សប្រឆាំងនឹងសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលគ្រប់គ្រងគណបក្សប្រជាជនកម្ពុជា និយាយអំពីការដកខ្លួនចេញពីការពិភាក្សាការកាត់ក្តីរបស់អង្គការសហប្រជាជាតិកាលពីខែកុម្ភៈកន្លងទៅថា «អង្គការសហប្រជាជាតិធ្វើត្រូវដែលដកខ្លួនចេញពីការកាត់ក្តីមិនទំនងនេះ ដែលសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ចង់ឲ្យមាន» ។ ទោះបីជាមានមនុស្សមួយចំនួនអះអាងថាមានការកាត់ទោសខ្វះល្អជាងគ្មានក៏ដោយ ក៏នៅមានអ្នកផ្សេងទៀតប្រកែកយ៉ាងខ្លាំងថា គេសុខចិត្តឲ្យគ្មានអ្វីសោះជាជាងឲ្យមានល្ខោនកាត់ក្តី ។ នេះដោយសារតែការទាមទាររបស់រដ្ឋាភិបាលកម្ពុជាស្តីអំពីស្តង់ដារនៃតុលាការកាត់ទោសខ្មែរក្រហមមិនបានឲ្យតុលាការនោះធ្វើតាមកម្រិតស្តង់ដារតុលាការអន្តរជាតិ ភាពយុត្តិធម៌ និងនិតិវិធីច្បាប់ត្រឹមត្រូវ ។ បញ្ហាស្តីពីភាពយុត្តិធម៌និងត្រឹមត្រូវចុងក្រោយនេះនាំមកនូវការយកចិត្តទុកដាក់អំពីសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងរដ្ឋាភិបាលកម្ពុជា ព្រមទាំងប្រព័ន្ធ

ច្បាប់របស់កម្ពុជា ។

### ក) សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន

ការជឿជាក់របស់ប្រជាជនកម្ពុជាចំពោះសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងរដ្ឋាភិបាលរបស់ពួកគេអាចត្រូវបានចាត់ទុកនិងគូសបញ្ជាក់ថា ជាជំនឿមួយដែលពោរពេញដោយការសង្ស័យ ។ ចាប់តាំងពីការពិភាក្សាអំពីតុលាការកាត់ទោសខ្មែរក្រហមបានចាប់ផ្តើមមក សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នៃគណបក្សប្រជាជនកម្ពុជា កំពុងតែនាំមុខការចរចាជាមួយអង្គការសហប្រជាជាតិដើម្បីសុំជំនួយក្នុងការបង្កើតតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមនៅក្នុងឆ្នាំ១៩៩៧ ។ ប៉ុន្តែទាំងប្រជាជនកម្ពុជានិងសហគមន៍អន្តរជាតិបានយល់អំពីភាពស្មុគស្មាញ និងការបង្ហាញមតិផ្ទុយគ្នា ដែលសម្តេចនាយករដ្ឋមន្ត្រីមានចំពោះតុលាការដែលមានក្នុងពេលវែងដែលត្រូវព្រមព្រៀងលើផ្នែកមួយចំនួននៃការកាត់ក្តី និងការបង្ហាញឲ្យឃើញនូវភាពខុសគ្នានិងវាទប្បដិវាទរបស់គាត់ ។ ការពិពណ៌នាខ្លះៗជាបន្តបន្ទាប់របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងរដ្ឋាភិបាលកម្ពុជាត្រូវបានរិះគន់ដោយប្រជាជនកម្ពុជា ប៉ុន្តែមានប្រជាជនកម្ពុជាមួយចំនួនមានចម្ងល់នៅក្នុងចិត្តតែបន្តិចបន្តួច ។

លោក សម រង្ស៊ី គឺជាសំឡេងដ៏ខ្លាំងមួយក្នុងចំណោមសំឡេងដ៏ពុះៗទាក់ទងទៅនឹងតុលាការកាត់ទោសខ្មែរក្រហមហើយមិនខ្លាចនឹងនិយាយដោយចំហអំពីទស្សនៈរបស់គាត់ចំពោះសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងរាជរដ្ឋាភិបាលកម្ពុជាឡើយ ។ ទោះបីជាគាត់មេដឹកនាំនៃគណបក្សប្រឆាំងក៏ដោយ ទស្សនៈរបស់គាត់ត្រូវបានរួមចំណែកពីប្រជាជនកម្ពុជាជាច្រើនទៀតនិងបាននិយាយដោយមិនលាក់លៀម ។ លោក សម រង្ស៊ី បាននិយាយថា "ដរាបណាសម្តេច ហ៊ុន សែន, (ប្រធានរដ្ឋសភា) សម្តេច ជា ស៊ីម និងអ្នកដឹកនាំតំណាងគណបក្សប្រជាជនកម្ពុជានៅមានអំណាច (យើង) មិនអាចសង្ឃឹមថានឹងមានការកាត់ទោសប្រកបដោយយុត្តិធម៌ចំពោះមេដឹកនាំខ្មែរក្រហមដែលគួរឲ្យជឿជាក់បានឡើយ" ។ លោក ឡៅ ម៉ុងហៃ មានទស្សនៈប្រហាក់ប្រហែលគ្នានេះដែរនៅពេលដែលគាត់និយាយថា "សម្តេច ហ៊ុន សែន មិនចង់បានតុលាការពិតប្រាកដទេ ។ គាត់គ្រាន់តែគាំទ្រតុលាការនោះដើម្បីផលប្រយោជន៍ខាងនយោបាយផ្ទាល់ខ្លួនតែប៉ុណ្ណោះ" ។ មានសំណួរធម្មតាមួយចំពោះសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងចេតនាពិតរបស់គាត់ស្តីពីតុលាការកាត់ទោសខ្មែរក្រហម ។ លោក សាក់ សមប៊ូន និយាយនៅក្នុងវិទ្យុNPR ថា "ចំពោះខ្ញុំការកាត់ទោសបទឧក្រិដ្ឋគឺជារឿងសំខាន់មួយដែលចាំបាច់ត្រូវមានមិនថាពួកគេមានចេតនាបុគ្គាននោះទេ ប៉ុន្តែមិនមែននៅពេលដែលវាអាស្រ័យលើគណបក្សគ្រប់គ្រងឡើយ ។ អ្នកដឹងហើយថា រដ្ឋាភិបាលរបស់យើងដូចជាក្មេងម្នាក់" ។ ការដែលដូចជាក្មេងម្នាក់គឺវាមិនគួរឲ្យទុកចិត្តឬរំពឹងទុកថានឹងធ្វើអ្វីៗដោយម៉ត់ចត់ទេដោយសារតែក្មេងម្នាក់អាចប្រព្រឹត្តទៅតាមទំនើងចិត្តដែលមានគ្រប់ពេល ។ អត្ថបទមួយរបស់កាសែតវ៉ាស៊ីងតោនប៉ុស្តិ៍សរសេរថា "មន្ត្រីអង្គការសហប្រជាជាតិអ្នកដឹកនាំប្រឆាំងរបស់កម្ពុជានិងអ្នកឧបត្ថម្ភផ្នែកសិទ្ធិមនុស្សបានចោទបញ្ហាចំពោះការសន្យាឲ្យមានតុលាការយុត្តិធម៌មួយរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន" ។ រឿងនេះបង្ហាញថាប្រជាជនជាច្រើនមកពីក្រុមផ្សេងៗគ្នាមានគំនិតសង្ស័យដូចគ្នាចំពោះសម្តេច ហ៊ុន សែន ។ អត្ថបទមួយទៀតនៅក្នុងកាសែតញូវយ៉កថែមសរសេរថា "សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលនិយាយសម្តីចុងក្រោយរបស់គាត់នៅទីនេះ បានស្វែងរកនយោ-បាយនៃភាពមិនជាក់លាក់ថាតើគាត់ចង់ឲ្យមានការកាត់ទោសឬទេ" ។ នៅក្នុងអត្ថបទរបស់ អ៊ិនធី ប្រេស មានសេចក្តីដកស្រង់មួយដែលអានដោយផ្ទាល់ពីសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ថា "ខ្ញុំមិនខ្វល់ថាអង្គការសហប្រជាជាតិចូលរួមក្នុងតុលាការកាត់ទោសឬក៏អត់ទេ" ហើយថា "ជនបរទេសមិនគួរគ្រប់គ្រងតុលាការកាត់ទោសខ្មែរក្រហមឡើយ" ។ ជាមួយសេចក្តីដកស្រង់នេះ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនខ្វល់អំពីការចូលរួមរបស់អង្គការសហប្រជាជាតិទេ ។ នៅពេលដែលអង្គការសហប្រជាជាតិសង្ឃឹមនឹងធ្វើតុលាការកាត់ទោសមួយឲ្យមានភាពយុត្តិធម៌និងត្រឹមត្រូវស្របច្បាប់នោះ ការនិយាយឥតខ្វល់ខ្វាយនេះកំពុងតែមានសន្ទុះគួរឲ្យភ្ញាក់ផ្អើលនិងធ្លាក់តម្លៃ ។ ទាំងនេះគ្រាន់តែជាសេចក្តីថ្លែងខ្លះៗនៅក្នុងសារពត៌មានជាច្រើនដែលបង្ហាញពីការមិនពេញចិត្តជាមួយនឹងសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលលាបពណ៌រូបភាពរបស់គាត់ទាំងមូលឲ្យមានមន្ទិលសង្ស័យ ។

ចំណែកមួយនៃភស្តុតាងដែលបង្ហាញថាចេតនារបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ខុសប្លែកគ្នាពីបំណងដែលគាត់បង្ហាញចំពោះសារព័ត៌មាន អាចរកឃើញនៅក្នុងការសន្ទនាមួយរវាងគាត់និងនាយករដ្ឋមន្ត្រីថៃ ឈួន លីកផៃ នៅក្នុងឆ្នាំ ១៩៩៨ ។ នៅក្នុងការសន្ទនានោះ គាត់និយាយអំពីអតីតមេដឹកនាំខ្មែរជាន់ខ្ពស់បីរូប ដោយនិយាយថា “ប្រសិនបើ តាម៉ុក, នួន ជា និង ខៀវ សំផន បាត់ខ្លួនវាជាការល្អ ។ សហរដ្ឋអាមេរិកត្រូវការពួកគេ ប៉ុន្តែខ្ញុំមានអារម្មណ៍ថា មេដឹកនាំទាំងនោះនឹងមិនចុះចាញ់ចំពោះស្ថានភាពណាមួយឡើយ ។ ប្រសិនបើពួកគេអាចរកកន្លែងជ្រកណាមួយដែលគ្មានអ្នកណារកឃើញវាពិតជាដំណោះស្រាយដ៏ល្អបំផុត” ។ នៅក្នុងការនិយាយបែបនេះ សម្តេចកត់សម្គាល់ថាអតីតមេដឹកនាំជាន់ខ្ពស់ទាំងបីរូបនេះនឹងមិនអស់សង្ឃឹមចំពោះខ្លួនគេទេ ហើយបណ្តោយឲ្យពួកគេមានកន្លែងជ្រកពួនផ្សេងទៀតដើម្បីចៀសពីការធ្វើដូច្នេះ ។ ទោះបីជាវាមិនប្រាកដច្បាស់ថាសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន កំពុងតែស្នើឲ្យប្រទេសថៃលាក់ពួកខ្មែរក្រហម ជួយពួកខ្មែរក្រហមឲ្យគេចខ្លួនទៅប្រទេសចិនឬសម្ងាប់ពួកខ្មែរក្រហមយ៉ាងណាក៏ដោយ វាបង្ហាញឲ្យឃើញថាសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនយកចិត្តទុកដាក់ចំពោះការកាត់ទោសសោះឡើយ ។ គួរតែកត់សម្គាល់ថា ជនទាំងបីរូបនេះគឺជាផ្នែករបស់បក្ខជន៧នាក់សម្រាប់ការកាត់ទោសដែល ស្ទេហ្វេន ហេដឺ បានបញ្ចូលនៅក្នុងរបាយការណ៍របស់គាត់ ហើយដែលប្រហែលជាជនទាំងបីរូបនេះត្រូវនាំមកកាត់ទោស ប្រសិនបើតុលាការបានកើតឡើង ។ សេចក្តីថ្លែងរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នេះផ្ទុយទាំងស្រុងទៅនឹងអ្វីដែលគាត់បានប្រាប់សារព័ត៌មាន ហើយដែលថាត្រូវតែកាត់ទោសនិងនាំអ្នកប្រព្រឹត្តបទល្មើសមកកាន់តុលាការកាត់ក្តី ។

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានទាញផលប្រយោជន៍ពីការគាំទ្រឲ្យមានតុលាការ ប៉ុន្តែក៏មានការខ្វាចញញើតខ្លះៗដែរ ។ លោក ឡៅ ម៉ុងហៃ និយាយថា “គាត់គាំទ្រតុលាការដើម្បីផលប្រយោជន៍នយោបាយតែប៉ុណ្ណោះ” ។ ប្រយោជន៍ខាងនយោបាយនេះគឺជាប្រយោជន៍ទាំងក្នុងស្រុកនិងអន្តរជាតិ ។ គណបក្សប្រជាជនកម្ពុជាអះអាងថា ការទទួលខុសត្រូវមួយចំនួនចំពោះការសុំឲ្យកងទ័ពវៀតណាមជួយបណ្តេញខ្មែរក្រហមដែលជាការឆ្លើយតបមួយផ្តល់ឲ្យពួកគេមានឈ្មោះល្អ ។ ទោះបីជាមានជាប់ទាក់ទិននឹងហាយនភ័យដែលនឹងត្រូវពិភាក្សាពេលក្រោយក៏ដោយ ក៏ការជំរុញឲ្យមានតុលាការមួយអាចធ្វើបានដូចគ្នាដែរ ។ នៅពេលដែលប្រជាជនកម្ពុជាស្ទើរតែទាំងអស់ចង់បានតុលាការ ការឧបត្ថម្ភជាសាធារណៈរបស់គណបក្សប្រជាជនកម្ពុជាចំពោះជំនួយតុលាការនៅតែបន្តគាំទ្រពីប្រជាជនកម្ពុជាមួយចំនួនទៀត ។ អត្ថបទមួយរបស់ អ៊ិនធឺប្រេស សឺវីស សរសេរថា “ការចូលរួមរបស់អង្គការសហប្រជាជាតិនៅក្នុងការកាត់ទោសខ្មែរក្រហម... នឹងជួយជំរុញឲ្យសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន កាន់តែមានសំអាងលើសមរភូមិនយោបាយសំខាន់មួយ ដែលតុលាការស៊ើបអង្កេតបទឧក្រិដ្ឋរបស់ខ្មែរក្រហមដែលបានប្រព្រឹត្តអំឡុងពេលកាន់កាប់អំណាច ។ វាក៏នឹងមកដល់ដៃដែរសម្រាប់ការបោះឆ្នោតជាទូទៅនៅឆ្នាំ២០០៣ ។ ស៊ុនណៃ ដាស៊ុក ជាអ្នកស្រាវជ្រាវនៅបណ្តាញអាស៊ាននៅបាងកកដើម្បីប្រជាធិបតេយ្យ និយាយថានីត្យានុកូលភាពរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺជាវត្ថុមួយដែលសម្តេច “កំពុងតែខំព្យាយាមយ៉ាងខ្លាំងដើម្បីឲ្យបានសម្រេច” ។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនមែនខំប្រឹងប្រែងដើម្បីទទួលនូវនីត្យានុកូលភាពនៅក្នុងប្រទេសរបស់គាត់តែប៉ុណ្ណោះទេ ។ ស៊ុនណៃ ដាស៊ុក ក៏និយាយដែរថា “គាត់កំពុងតែព្យាយាមកែលម្អរូបរាងរបស់គាត់ដើម្បីឲ្យមានការទទួលស្គាល់ជាអន្តរជាតិ” ។ គឺការទទួលស្គាល់នេះហើយដែលមានសារសំខាន់បំផុតសម្រាប់កម្ពុជា ។ ប្រទេសកម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសក្រីក្របំផុតនៅក្នុងពិភពលោក ហើយកំពុងតែប្រឹងប្រែងងើបចេញពីប្រវត្តិសាស្ត្រនៃសង្គ្រាមដ៏យូរឲ្យក្លាយជាប្រទេសមានប្រជាធិបតេយ្យ ។ តុលាការប្រភេទនេះបង្ហាញពិភពលោកឲ្យឃើញថា ប្រទេសកម្ពុជាកំពុងព្យាយាមឲ្យខ្លួនឯងប្រសើរឡើង ។ ការគាំទ្រឲ្យមានតុលាការមិនត្រឹមតែធ្វើឲ្យប្រទេសកម្ពុជាមានលក្ខណៈល្អប្រសើរទេ វាថែមទាំងមានការទាមទារពីប្រទេសលោកខាងលិចឲ្យមានតុលាការ ។

មានទំនាស់សំខាន់ៗពីរស្តីអំពីតុលាការដែលសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងរដ្ឋាភិបាលកម្ពុជា មានការមិនពេញចិត្តៈ

មួយគឺសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ផ្ទាល់ និងសមាជិកផ្សេងទៀតរបស់រដ្ឋាភិបាល នឹងត្រូវធ្វើឲ្យអាម៉ាស់ចំពោះព័ត៌មានដែលបង្ហាញអំពីការជាប់ទាក់ទងរបស់ខ្លួនជាមួយខ្មែរក្រហម និងទីពីរគឺប្រទេសចិននឹងលែងមានមិត្តភាព ប្រសិនបើតុលាការត្រូវបានបង្កើតហើយបានដឹងថាប្រទេសចិនមានតួនាទីសំខាន់នៅក្នុងជោគជ័យរបស់ខ្មែរក្រហម ។

នៅពេលចាប់ផ្តើមនៃរបបខ្មែរក្រហម សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺជាមេបញ្ជាការយោធាថ្នាក់ទាបម្នាក់ ប៉ុន្តែក្រោយមកបានរត់ទៅប្រទេសវៀតណាមនៅក្នុងឆ្នាំ១៩៧៧ ។ សារព័ត៌មានក្បួសរសេរតាមសម្តីរបស់លោក សម រង្ស៊ី ថា“គាត់និយាយថា មេបញ្ជាការខ្មែរក្រហមថ្នាក់កណ្តាលជាច្រើនដែលប្រព្រឹត្តអំពើប្រល័យពូជសាសន៍វាលពិឃាត ធ្វើការនៅក្នុងរដ្ឋាភិបាលរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន” ។ អត្ថបទរបស់សារព័ត៌មានរ៉យទ័រ សរសេរថា “សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺជារដ្ឋមន្ត្រីម្នាក់ក្នុងចំណោមរដ្ឋមន្ត្រីមួយចំនួនរបស់រដ្ឋាភិបាលដែលមានសាវតាជាខ្មែរក្រហម” ។ ស្ថិតនៅក្នុងវិធីចោទប្រកាន់ធ្ងន់ធ្ងរមួយទៀតនោះ អត្ថបទមួយរបស់ សៅ ឆាយណា ម័រនីងប៉ុស្តិ៍ សរសេរថា “តាមការជាក់ស្តែង អ្នកនយោបាយគ្រប់រូបនៅក្នុងប្រទេសកម្ពុជាសុទ្ធតែធ្លាប់ចូលរួមនិងចងសម្ព័ន្ធមិត្តជាមួយទ័ពព្រៃខ្មែរក្រហម” ។ សេចក្តីថ្លែងទាំងអស់នេះបង្ហាញថានាយករដ្ឋមន្ត្រីនិងមន្ត្រីផ្សេងទៀតមានរឿងជាប់ពាក់ព័ន្ធផ្ទាល់ខ្លួនប្រសិនបើតុលាការកើតឡើង ។

នៅក្នុងអត្ថបទរបស់សារព័ត៌មាន អ៊ីនធី ប្រេស សឺវិស សរសេរថា “ដំណើរការកាត់ទោសរបស់តុលាការអាចធ្វើឲ្យឈឺចាប់ដល់ស្រមោលរបស់ពួកគេ ហើយកាន់តែសំខាន់ជាងនេះទៅទៀតគឺភ័ព្វវាសនានយោបាយនៅក្នុងប្រទេសរបស់ពួកគេ ។ ទោះបីជាការងាររបស់ពួកគេមិនជាប់ពាក់ព័ន្ធទាំងស្រុងដូចបាននិយាយថា គ្មានភ័ស្តុតាងបញ្ជាក់ថាពួកគេជាប់ទាក់ទងនឹងខ្មែរ-ក្រហមក៏ដោយ ក៏ភាពអាម៉ាសនឹងត្រូវបង្ហាញនៅក្នុងសារព័ត៌មានដដែលជាដដែល ។

ការគំរាមកំហែងពីប្រទេសចិនក៏ជាហេតុផលមួយទៀតដែលធ្វើឲ្យសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មានការស្ទាក់ស្ទើរមិនចង់ចូលរួមការចរចាឲ្យទាន់ពេលវេលា ។ ទោះបីជាមានការដឹងឮសុះសាយថាចិនមានការជំពាក់ជំពិនជាមួយខ្មែរក្រហមក៏ដោយ ប៉ុន្តែចិនមិនចង់ឲ្យមានការដឹងឮតទៅទៀត ឬមិនចង់ឲ្យមានការរកឃើញការជំពាក់ជំពិនថ្មីៗទៀត អំពីការជាប់ទាក់ទងរបស់ខ្លួនជាមួយនឹងខ្មែរក្រហមដែរ ។ ទាក់ទិនទៅនឹងតួនាទីរបស់ចិន លោក សម រង្ស៊ី និយាយថា “យើងត្រូវការវត្តមានរបស់សហរដ្ឋអាមេរិកដើម្បីធ្វើឲ្យមានតុល្យភាពអំណាចជាមួយចិនដែលទំនុញយ៉ាងខ្លាំងក្លា” ។ ការដកស្រង់សម្តីមួយទៀតពីលោក សម រង្ស៊ី បញ្ជាក់ថា “ចិនដែលជាចៅហ្វាយនាយរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្លាប់បានបញ្ជាក់ច្បាស់ថា គេនឹងគាំទ្រតុលាការនេះប្រសិនបើការជំពាក់ជាក់វិនរបស់ចិនជាមួយអំពើឃោរឃៅប្រព្រឹត្តឡើងដោយខ្មែរក្រហមមិនស្ថិតនៅក្រោមការពិនិត្យពិច័យពីសំណាក់អន្តរជាតិទេនោះ ។ ជាការច្បាស់ណាស់ថា ការមិនពេញចិត្តរបស់ចិន គឺជាអ្វីដែលរដ្ឋាភិបាលកម្ពុជាមិនចង់ប្រឈមមុខជាមួយ ។ តួនាទីរបស់ចិននៅក្នុងការពិភាក្សានេះគឺមានសារសំខាន់ណាស់ដោយសារចិនគឺជាសមាជិកមួយក្នុងចំណោមសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ។ ចិនអាចប្រើសិទ្ធិជំទាស់ចំពោះរាល់អាណត្តិដែលស្នើឡើងក្នុងការបង្កើតនូវតុលាការឧក្រិដ្ឋកម្មសង្គ្រាម ប៉ុន្តែអាណត្តិនេះក៏អាចអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិដែរ ។

### ឃ) ប្រព័ន្ធច្បាប់កម្ពុជា

នៅពេលដែលរដ្ឋាភិបាលកម្ពុជាបានទទូចឲ្យមានតុលាការនៅកម្ពុជា ហើយមានចៅក្រមកម្ពុជាជាអធិបតីដែលមានចំនួនច្រើនជាងចៅក្រមអន្តរជាតិដែលនាំឲ្យមាន “អំណាចលើសលប់” នៅក្នុងដំណើរការជំនុំជម្រះក្តីនោះ មានការផ្តោតសំខាន់ទៅលើអធិបតេយ្យភាពរបស់ប្រព័ន្ធច្បាប់កម្ពុជា ។ អ្វីដែលប្រត្យក្សនោះគឺថា ប្រព័ន្ធច្បាប់កម្ពុជាមានលក្ខណៈពុករលួយ ។ បញ្ហានេះទាំងប្រជាជនកម្ពុជាទាំងសហគមន៍អន្តរជាតិក៏បានដឹងឮដែរ ។

នៅក្នុងកិច្ចសម្ភាសន៍មួយនៅក្នុងវិទ្យុ NPR លោក ឡៅ ម៉ុងហៃ និយាយថា “បេសកម្មរបស់អង្គការសហប្រជាជាតិ អស់លោកដឹងទេ អ្នកសង្កេតការណ៍បរទេសនិងអ្នកសង្កេតការណ៍ខ្មែរសុទ្ធតែយល់ស្របគ្នាថាប្រព័ន្ធតុលាការរបស់យើងមិនសូវមាន

សមត្ថភាពទេ ។ តុលាការយើងមិនមានលក្ខណៈឯករាជ្យ ។ ចៅក្រមមិនមានឯករាជ្យ ។ ដូចនេះតើធ្វើយ៉ាងដូចម្តេចនឹងមានការជម្រះក្តីប្រកបដោយភាពយុត្តិធម៌?» ។ លោក សុខ សំអឿន មេធាវីមួយរូបនិងជាអ្នកសម្របសម្រួលនៅក្នុងគណៈកម្មាធិការប្រព្រឹត្តិកម្មសិទ្ធិមនុស្សកម្ពុជានិយាយថា «ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់យើងមិនអាចធ្វើការកើតទេ ។ ចៅក្រមអាចទទួលឥទ្ធិពលពីរដ្ឋាភិបាល ។ មានចៅក្រមមួយចំនួនមានទំនាក់ទំនងជាមួយគណបក្សគ្រប់គ្រងអំណាច» ។ សម្រង់សម្តីទាំងពីរនេះបង្ហាញអំពីកង្វះឯករាជភាពរបស់តុលាការនិងចៅក្រមកម្ពុជា ។ នេះគឺជាការព្រួយបារម្ភយ៉ាងខ្លាំងប្រសិនបើរដ្ឋាភិបាលកម្ពុជាគ្រប់គ្រងយ៉ាងលើសលប់ទៅលើដំណើរការតុលាការទាំងមូល ។ វាទំនងជាថាចៅក្រមរបស់កម្ពុជាអាចនឹងធ្វើតាមសម្ពាធផ្សេងៗ ។

លោក ថូម៉ាស ហាម៉ាប៊ើក អតីតតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានសរសេរនៅក្នុងឆ្នាំ១៩៩៩ថា «តុលាការមានធនធានមិនគ្រប់គ្រាន់ហើយស្ថិតនៅក្រោមសម្ពាធនយោបាយនិងយោធា ។ មានសេចក្តីរាយការណ៍មកថា ភាគច្រើននៃបទល្មើសគឺប្រព្រឹត្តឡើងដោយអ្នកអនុវត្តច្បាប់ខ្លួនឯងផ្ទាល់...សូម្បីតែការសម្លាប់លោក ហូ សុខ នៅក្នុងបរិវេណក្រសួងមហាផ្ទៃក៏បានបញ្ជាក់ស្រាប់» ។ ទោះបីជារបាយការណ៍នេះសរសេរឡើងនៅក្នុងឆ្នាំ១៩៩៩ក៏ដោយ ប៉ុន្តែក៏នៅមានសម្ពាធថ្មីៗជាច្រើនមកពីប្រទេសអ្នកផ្តល់ជំនួយដល់កម្ពុជាក្នុងគោលបំណងឲ្យកម្ពុជាធ្វើកំណែទម្រង់ប្រព័ន្ធច្បាប់នៅកម្ពុជា ។ ការយល់ជ្រាបអំពីបញ្ហានៅក្នុងប្រព័ន្ធតុលាការកម្ពុជានិងកងកម្លាំងនគរបាលព្រមទាំងអ្នកស៊ើបអង្កេត វាពិបាកធ្វើឲ្យមានការជឿជាក់ថា ប្រទេសកម្ពុជាដែលមានការទទួលខុសត្រូវទាបបែបនេះនឹងផ្តល់នូវការជំនុំជម្រះក្តីប្រកបដោយភាពត្រឹមត្រូវនិងយុត្តិធម៌នៅក្នុងតុលាការឧក្រិដ្ឋកម្មសង្គ្រាម ។ បើងាកត្រឡប់ទៅនិយាយអំពីការដកស្រង់សម្តីរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលមិនខ្វល់ថាអង្គការសហប្រជាជាតិចូលរួមឬក៏អត់នោះ វាបានបង្ហាញថាគ្មានបញ្ហាអ្វីឡើយចំពោះប្រជាជនកម្ពុជា ជាពិសេសរដ្ឋាភិបាលរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នឹងមានសិទ្ធិច្រើននៅក្នុងដំណើរការជំនុំជម្រះក្តីនេះ ។ គំនិតដែលថារដ្ឋាភិបាលនិងប្រព័ន្ធតុលាការកម្ពុជាពុករលួយមកធ្វើអធិបតីនៅក្នុងតុលាការឧក្រិដ្ឋកម្មសង្គ្រាមដើម្បីស្វែងរកការពិតនិងយុត្តិធម៌គឺជាភាពអវិជ្ជមានមួយក្នុងចំណោមភាពអវិជ្ជមានដទៃទៀតពាក់ព័ន្ធនឹងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

## សេចក្តីសន្និដ្ឋាន

ការពិភាក្សាអំពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមគឺជារឿងគួរឲ្យនឿយណាយនិងស្រងាកចិត្តនៅពេលដែលដឹងថាមានឧបសគ្គជាច្រើនជំពូកដែលត្រូវប្រឈមមុខ ។ ទ្រឹស្តីនយោបាយបង្ហាញថា តុលាការគឺជាផ្លូវសម្រាប់ចំណាត់ការដ៏ត្រឹមត្រូវដែលត្រូវដើរ ហើយថា មានហេតុផលច្រើនជាងមិនបង្កើតតុលាការ ប៉ុន្តែមានបញ្ហានយោបាយជាក់ស្តែងជាច្រើននៅពេលប្រតិបត្តិ ។ ទស្សនៈរបស់កម្ពុជាទៅលើបញ្ហាតុលាការនេះ ទោះបីជាមិនទាន់មានការវាយតម្លៃឲ្យបានម៉ត់ចត់ក៏ដោយ ក៏វាបង្ហាញជាទូទៅអំពីការគាំទ្រឲ្យមានតុលាការកើតឡើង ។ ហេតុផលពីរយ៉ាងដែលប្រជាជនកម្ពុជាគាំទ្រតុលាការគឺទីមួយ ដើម្បីស្វែងរកការពិត ទីពីរ ដើម្បីយុត្តិធម៌ ។ ប៉ុន្តែដើម្បីស្វែងរកការពិតនិងយុត្តិធម៌ តុលាការគួរតែឆ្លើយតបទៅនឹងបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនិងដំណើរការទៅតាមនីតិវិធីត្រឹមត្រូវ ។ នៅក្នុងគន្លងវិធីឆ្ពោះទៅរកភាពសុក្រឹតនេះ មានការរិះគន់យ៉ាងខ្លាំងនិងមានលក្ខណៈរារាំងបង្អាក់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងប្រព័ន្ធតុលាការកម្ពុជា ហើយនៅទីនេះហើយដែលឧបសគ្គទាំងឡាយរារាំងដល់ការបង្កើតតុលាការត្រូវបានលើកឡើង ។

នៅក្នុងចំណោមបញ្ហាទាំងនេះ យើងមិនត្រូវបំភ្លេចនូវស្ថានភាពចរចាអំពីការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមឡើយ ។ ឥទ្ធិពលនៃព្រឹត្តិការណ៍ថ្ងៃទី១១កញ្ញា កាលពីឆ្នាំ២០០១ នៅសហរដ្ឋអាមេរិកបាននិងកំពុងធ្វើឲ្យប៉ះពាល់ដល់អារម្មណ៍សាធារណមតិ ចំណែកឯសហរដ្ឋអាមេរិកនិងអង្គការសហប្រជាជាតិផ្តោតសំខាន់ទៅលើការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម ។ ទោះបីជាអង្គការសហប្រជាជាតិប្រកាសថ្មីៗនេះថា ការចរចាអំពីបញ្ហាតុលាការនឹងចាប់ផ្តើមសាជាថ្មី ក្រោយពីការអាក់ខានអស់រយៈពេល៩ខែកន្លងមកហើយ ថាតើមានការគាំងចិត្តដល់ត្រឹមកម្រិតណាចំពោះការបង្កើតតុលាការខ្មែរក្រហមនៅមិនទាន់

ដឹងនៅឡើយទេ ។ បញ្ហាដែលកើតឡើងក្រោមការដឹកនាំរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏ហាក់ដូចជានៅតែបន្តទៅមុខទៀតដោយសារនាពេលថ្មីៗនេះ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថា សម្តេចនឹងនៅបន្តកាន់អំណាចក្នុងអំឡុងពេល១០ឆ្នាំតទៅមុខទៀត ។ វាហាក់ដូចជាថាបញ្ហាដូចគ្នាមួយចំនួននៃការចរចានេះនឹងនៅតែបន្តកើតមានតទៅទៀត ទោះបីជាវាមិនពិបាកដោះស្រាយក៏ដោយ ។ ខ្ញុំយល់ថា លោក ឆាំង យុ ពិតជាធ្វើមូលន័យបានយ៉ាងល្អ ដោយលោកបានសរសេរថា «***២៣ឆ្នាំក្រោយពីការដួលរលំនៃរបបខ្មែរក្រហម ជនរងគ្រោះបន្តរង់ចាំយុត្តិធម៌និងការពិត ខណៈដែលមេដឹកនាំនៃរបបខ្មែរក្រហមចេះតែបន្តរស់នៅដោយមានសេរីភាពពេញលេញនៅចំពោះមុខជនរងគ្រោះ ។ នៅពេលដែលជនរងគ្រោះជាច្រើនរស់នៅក្នុងភាពក្រីក្របានព្រឹកខ្វះល្ងាច អតីតមេដឹកនាំខ្មែរក្រហមដូចជា អៀង សារី និង អៀង ធីរិទ្ធ ជាដើមធ្វើដំណើរទៅពិនិត្យព្យាបាលជំងឺនៅប្រទេសថៃដោយចំណាយប្រាក់យ៉ាងច្រើន ។ កាលពីប៉ុន្មានខែមុន ពិភពលោកបានងាកការយកចិត្តទុកដាក់ទៅលើយុត្តិធម៌សម្រាប់ ចឹន ឡាដិន និងកូនចៅរបស់ ចឹន ឡាដិន ។ ជាការច្បាស់ណាស់ថា គួរតែមានការប្រើប្រែងឲ្យអស់លទ្ធភាពដើម្បីចាប់ខ្លួនឧក្រិដ្ឋជនទាំងនោះនិងនាំខ្លួនពួកគេមកកាត់ទោសទៅតាមច្បាប់ ។ ប៉ុន្តែទន្ទឹមពេលនេះដែរ គួរឲ្យអន់ចិត្តដោយសារតែសហគមន៍អន្តរជាតិឥឡូវនេះបង្ហាញនូវការចាប់អារម្មណ៍តិចតួចចំពោះយុត្តិធម៌នៅកម្ពុជានិងមនុស្សជាតិទាំងមូល ។ នាំមេដឹកនាំខ្មែរក្រហមមកកាត់ទោសជាការងាយស្រួលនិងត្រូវចំណាយតែមួយផ្នែកនៃកិច្ចខិតខំប្រឹងប្រែងដូចដែលគេយកចិត្តទុកដាក់ទៅលើពួកអាល់កេដាជាការស្រេច ។ អ្វីដែលត្រូវការ គឺឆន្ទៈនយោបាយរវាងសហគមន៍អន្តរជាតិនិងកម្ពុជា ។ ការប្រសព្វគ្នានេះបានខិតជិតរកគ្នាហើយប៉ុន្តែពេលនេះវាហាក់ដូចជាកំពុងតែថមថយសន្ទុះទៅវិញ ។ ប្រការនេះមិនគួរឲ្យកើតមានឡើយ***» ។

លោក ឆាំង យុ លើកឡើងអំពីភាពមិនស្មើគ្នារវាងជនរងគ្រោះដែលនៅរស់រានមានជីវិតជាមួយនឹងអតីតមេដឹកនាំខ្មែរក្រហមដែលបានសម្លាប់គ្រួសាររបស់ខ្លួន និងនាំឲ្យខ្លួនធ្លាក់ចូលក្នុងរណ្តៅមរណៈ ។ លោក ឆាំង យុ ក៏បង្ហាញទៀតថា មានពេលខ្លះអាទិភាពរបស់អន្តរជាតិប្រើខុសកន្លែង ប៉ុន្តែនៅតែសង្ឃឹមថារាល់កិច្ចប្រឹងប្រែងទាំងអស់នឹងសម្រេចបានជោគជ័យជាមិនខាន ។ ចំណុចសំខាន់បំផុតដែលលោកលើកឡើងគឺថាពេលវេលាជិតដល់ទីបញ្ចប់ហើយ នៅពេលដែលប្រជាជននាំគ្នាគេចវេះចេញពីបញ្ហាខ្មែរក្រហមនិងអ្វីដែលត្រូវធ្វើ ។ ដោយសារអត្ថបទនេះគ្រាន់តែចាប់ផ្តើមសម្លឹងមើលទៅលើទស្សនៈរបស់ប្រជាជនកម្ពុជាសង្ឃឹមថានឹងមានរឿងជាច្រើនទៀតដែលត្រូវលើកយកមកសិក្សាស៊ីជម្រៅបន្ថែម ។ ដោយសារប្រជាជនកម្ពុជាបានទទួលរងនូវការឈឺចាប់ខ្លាំងគឺគួរតែយកទស្សនៈនិងអារម្មណ៍របស់គាត់មកគិតគូរពិចារណាឲ្យបានច្រើនបំផុត ។ ប៉ុន្តែដោយសារតែពេលវេលាចេះតែខិតទៅៗទាំងមិនទាន់កាត់ទោសមេដឹកនាំខ្មែរក្រហមផងនោះក្តីសង្ឃឹមចង់បានការពិតនិងយុត្តិធម៌ហាក់ដូចជាស្រពាប់ស្រពោននិងសោះកក្រោះ ។ ទោះបីជាមានសង្ឃឹមថា ការយល់ដឹងអំពីពេលវេលានៅតិចតួចនឹងជំរុញឲ្យមានការចរចាជាបន្ទាន់ក៏ដោយ អំណាចគឺនៅតែស្ថិតនៅក្នុងដៃរដ្ឋាភិបាលកម្ពុជានិងសហគមន៍អន្តរជាតិក្នុងការបំពេញកិច្ចការនេះ ។ ប៉ុន្តែដោយសារបញ្ហាអធិបតេយ្យភាពរបស់រដ្ឋាភិបាលកម្ពុជានៅតែជាចម្ងល់នៅឡើយ វាហាក់ដូចជាមានការព្រួយបារម្ភនិងការចំអកឡកឡឺយថាក្តីសង្ឃឹមពិតប្រាកដស្ថិតនៅលើកម្លាំងនិងការតស៊ូរបស់ប្រទេសនានាក្រៅពីកម្ពុជា ។ **ឌួប ខាំលី**

# ដំណឹងស្វែងរកគ្រួសារ



ខ្ញុំបាទឈ្មោះ ប៉ុល ឯក សព្វថ្ងៃរស់នៅសហរដ្ឋអាមេរិក ។ កាលពីដើមមុនភៀសខ្លួនរស់នៅស្រុកកោះធំ ខេត្តកណ្តាល ។

ខ្ញុំសូមប្រកាសរកប្អូនស្រីបង្កើតពីរនាក់ៈ ១) ប៉ុល គិម អេង ហៅ គៀវ និងគ្រួសារ ២) ប៉ុល គិមអាន និងគ្រួសារ ។ ចំពោះលោកអ្នកណាស្គាល់ សូមមេត្តាផ្តល់ដំណឹងមកឈ្មោះអ្នកស្រី សុខុម លេខទូរស័ព្ទដៃស្រុកខ្មែរៈ ០១២ ៨៤០ ៤៦៨ ។ សូមអរគុណ ។

# ខ្ញុំចង់បានសន្តិភាពពិតប្រាកដ



ខ្ញុំកើតនៅឆ្នាំ១៩៨១ គឺពីរឆ្នាំក្រោយការដួលរលំនៃរបបខ្មែរក្រហម ។ ឪពុកម្ដាយនិងជីដូនរបស់ខ្ញុំធ្លាប់និយាយថា ខ្ញុំសំណាងល្អណាស់ដែលកើតក្រោយរបបវាលពិឃាត មិនបានជួបប្រទះនឹងការលំបាកវេទនាដូចជារូបគាត់ ។ កាលណោះ ខ្ញុំទើបតែមានអាយុប្រមាណ៥ឬ៦ឆ្នាំប៉ុណ្ណោះ ខ្ញុំមិនទាន់យល់អំពីអ្វីដែលឪពុកម្ដាយនិងជីដូនរបស់ខ្ញុំនិយាយទេ ។ ឪពុកម្ដាយរបស់ខ្ញុំធ្លាប់និយាយប្រាប់ខ្ញុំត្រួសៗអំពីរបបខ្មែរក្រហមថា ខ្មែរក្រហមចាប់ផ្ដើមគ្រប់គ្រងប្រទេសពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់មកបានជម្លៀសប្រជាពលរដ្ឋខ្មែរទាំងអស់ចាកចេញពីលំនៅដ្ឋានភូមិ ស្រុក ទៅទីជនបទឆ្ងាយៗ ហើយបង្ខំឲ្យធ្វើការធ្ងន់ៗដូចសត្វ និងឲ្យបរិភោគអាហារមិនគ្រប់គ្រាន់ ។ ប្រជាពលរដ្ឋខ្មែរទាំងអស់ត្រូវព្រាត់ប្រាសបងប្អូន កូនចៅ ឪពុកម្ដាយ យាយតា ប្ដីប្រពន្ធក្នុងអំឡុងពេលជម្លៀស មិនតែប៉ុណ្ណោះ ខ្មែរក្រហមបានប្រើអំពើឃោរឃៅ កាប់សម្លាប់ បាញ់ប្រហារដោយគ្មានត្រាប្រណីនិងគ្មានរើសមុខ ។ ប្រជាជនត្រូវបិទសិទ្ធិសេរីភាពគ្រប់បែបយ៉ាង វត្តអារាម ព្រះវិហារ និងទីសក្ការៈផ្សេងៗទៀតត្រូវបំផ្លាញ ។ អំឡុងពេលនោះជារយៈពេលដែលប្រទេសកម្ពុជាធ្លាក់ទៅក្នុងពិភពអន្ធការ ។

ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ខ្មែរក្រហមបានសម្លាប់ប្រជាជនកម្ពុជាអស់រាប់លាននាក់ ក្នុងនោះមានជីដូនជីតាខាងឪពុកខ្ញុំ ជីតាខាង ម្ដាយខ្ញុំ រួមទាំងអ៊ំ ពូ មីង និងបងប្អូនជីដូនមួយរបស់ខ្ញុំ សរុប៨នាក់បានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមនេះដូចគ្នា ។ នៅពេលខ្ញុំបានស្ដាប់ពាក្យការនិយាយត្រួសៗអំពីរឿងរ៉ាវទាំងអស់នេះ ខ្ញុំមិនបានចាប់អារម្មណ៍ខ្លាំងប៉ុន្មានឡើយ ខ្ញុំគ្រាន់តែគិតថាវាដូចជាខ្សែភាពយន្តមួយដែលត្រូវនិពន្ធឡើងដើម្បីអប់រំក្មេងប៉ុណ្ណោះ ព្រោះរូបភាពនៃអំពើសាហាវព្រៃផ្សៃជ្រុលហួសហេតុដែលកើតមាននៅក្នុងលំនឹកគិតរបស់ខ្ញុំចំពោះមនុស្សដូចគ្នា ដែលរស់នៅសម័យនោះ គឺស្ទើរមិនដល់និងមិនគួរឲ្យជឿទាល់តែសោះ ។ ដោយជាក់ស្ដែង តាមរយៈការរៀបរាប់របស់ឪពុកម្ដាយខ្ញុំ របស់ញាតិជិតខាង និងការរៀនសូត្រនៅសាលាធ្វើឲ្យខ្ញុំជឿជាក់ថាពិតជាមានរបបប្រល័យពូជសាសន៍នេះប្រាកដមែន ។

ក្នុងឆាកជីវិតរបស់ខ្ញុំធ្លាប់ជួបប្រទះអនុស្សាវរីយ៍គួរឲ្យតក់ស្លុតជាច្រើន ដែលបង្កឡើងដោយកងទ័ពខ្មែរក្រហមសេសសល់ ។ នៅអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៨០ ទោះបីជារបបខ្មែរក្រហមបានដួលរលំទៅក៏ពិតមែន ក៏ប្រជាជនកម្ពុជាទូទាំងប្រទេសនៅតែមិនបានស្ងប់ចិត្តអស់ក្ដីព្រួយបារម្ភចំពោះការវិលត្រឡប់នៃរបបនេះមួយរយភាគរយដែរ ព្រោះមានខ្មែរក្រហមដែលនៅសេសសល់បានរត់ទៅលាក់ខ្លួននៅក្នុងព្រៃជុំវិញរាជធានីភ្នំពេញនិងនៅតាមតំបន់នានា ចាំបង្កចលាចលគ្រប់ពេលដែលឱកាសហុចឲ្យ ។

ពេលដែលខ្ញុំចាប់ផ្ដើមដឹងក្ដី គឺអំឡុងឆ្នាំ១៩៨៦-៨៧ ក្រុមគ្រួសាររបស់ខ្ញុំនិងប្រជាជននៅក្នុងឃុំប្រាំងចំរេះ (តាមបណ្ដោយផ្លូវជាតិលេខ៥) ត្រូវរំខានឲ្យដាច់ដំណេកជារឿយៗ ដោយសារតែការរត់ពួនពីគ្រាប់ផ្លោងរបស់ទាហានខ្មែរក្រហម ។ ខ្ញុំនៅចាំស្នូរសន្ធឹករថក្រោះរបស់កងទ័ពវៀតណាមដែលបើកលាន់រង្គើដីក្នុងប្រតិបត្តិការទប់ទល់ជាមួយកងទ័ពខ្មែរក្រហម ។ ទម្ងន់កង់រថក្រោះបានធ្វើឲ្យទ្រុឌទ្រោមថ្នល់ជាតិ ។ ស្ទើរតែរៀងរាល់យប់តែងតែមានការបាញ់ផ្លោងដាក់គ្នាទៅវិញទៅមករវាងទាហានខ្មែរក្រហមសេសសល់ ដែលលាក់ខ្លួននៅត្រើយខាងកើតទន្លេជាមួយទាហានរបស់រដ្ឋាភិបាលដែលឈរជើងនៅត្រើយខាង

លិចទន្លេ ។ រាល់ពេលមានការប្រយុទ្ធគ្នា ប្រជាជននៅក្នុងភូមិខ្ញុំ ត្រូវក្រោកពីដំណេកទាំងភ័យស្លន់ស្លោ នាំកូនចៅរត់ទៅពួនក្នុងលេណដ្ឋាន ។ អ្នកភូមិរបស់ខ្ញុំគ្រប់ៗគ្នា រៀបចំអីវ៉ាន់ដាក់ក្នុងកាបូប សាក់កាដូ និងចងជាបង្វេចរួចជាស្រេច ត្រៀមខ្លួនដើម្បីរត់គេច ។ នៅក្នុងរយៈពេលនោះ អ្នកនៅក្នុងភូមិរបស់ខ្ញុំនិងភូមិជិតខាងឯទៀត សុទ្ធតែមានការព្រួយបារម្ភដូចគ្នាទាំងអស់ គឺខ្លាចកើតមានសង្គ្រាមជាថ្មីម្តងទៀត ខ្លាចបាត់គ្រួសារ បងប្អូន កូនចៅ សាច់ញាតិ ឧទាហរណ៍ដូចជាម្តាយរបស់ខ្ញុំ គាត់តែងតែរៀបអាហារពេលល្ងាចឲ្យគ្រួសារខ្ញុំញុំាមុនពេលព្រលប់ជានិច្ច និងតឿនខ្ញុំនិងប្អូនៗញុំាឲ្យលឿនៗ ពីព្រោះគាត់ខ្លាចមានការប្រយុទ្ធគ្នានៅពេលយប់ ។

ខ្ញុំភិតភ័យខ្លាំងណាស់ពេលឮស្នូរគ្រាប់កាំភ្លើងម្តងៗ ។ ជារៀងរាល់ថ្ងៃ ខ្ញុំមិនចង់ឲ្យឪពុកម្តាយខ្ញុំចេញទៅធ្វើការប្រកបរបររកទទួលទានអ្វីឡើយ ព្រោះខ្ញុំខ្លាចមានការប្រយុទ្ធគ្នាចំពេលដែលគាត់មិននៅផ្ទះ ។ យប់ខ្លះខ្ញុំមិនហ៊ានគេងទេ ខ្លាចក្រែងមានការប្រយុទ្ធគ្នាហើយខ្ញុំរត់ទៅពួនមិនទាន់ ។

ខ្ញុំនៅចាំថាយប់មួយនោះ ពេលដែលខ្ញុំកំពុងតែគេងលង់លក់ទាំងដក់ជាប់នូវក្តីបារម្ភពីល្ងាច ស្រាប់តែឮស្នូរផ្ទុះខ្លាំងៗ ធ្វើឲ្យខ្ញុំភ្ញាក់ក្រញាង តក់ស្លុតស្ទើរបាត់ដង្ហើម ។ ម្តាយខ្ញុំម្នីម្នាដាស់បងប្អូនខ្ញុំឲ្យក្រោកឡើង ហើយរត់ទៅពួនក្នុងលេណដ្ឋានក្រោមផ្ទះ ។ លុះព្រឹកឡើង ខ្ញុំបានដឹងថា គ្រាប់ផ្លោងរបស់កងទ័ពខ្មែរក្រហមបានធ្លាក់ត្រូវព្រះវិហារឥស្លាមមួយ ស្ថិតក្នុងភូមិគីឡូម៉ែត្រលេខ៧ ជាប់ផ្លូវជាតិលេខ៥ ។

សង្គ្រាមស៊ីវិលរ៉ាំរ៉ៃ ដែលបង្កដោយកងទ័ពខ្មែរក្រហម សេសសល់បណ្តាលឲ្យមានផលវិបាកជាច្រើនទាក់ទងទៅនឹងជីវភាពរស់នៅរបស់ប្រជាជនរហូតដល់នាំឲ្យប៉ះពាល់ដល់ប្រទេសជាតិទាំងមូល ។ ប្រជាជនមិនសូវហ៊ានចេញពីលំនៅដ្ឋានសិស្សទៅសាលារៀនមិនទៀងទាត់ ការប្រកបរបររកទទួលទានមិនជាប់លាប់ ប្រទេសស្ថិតក្នុងភាពអសន្តិសុខ គ្មានស្ថិរភាពសង្គម មនុស្សស្ថិតក្នុងការភ័យខ្លាច អ្នកវិនិយោគនៅក្រៅប្រទេសមិនចូលមកដាក់ទុន គ្មានអ្នកទេសចរ បណ្តាលឲ្យសេដ្ឋកិច្ចធ្លាក់ចុះ ប្រទេសជាតិមិនរីកចម្រើនលូតលាស់ទៅមុខ ។

ខ្ញុំជាពលរដ្ឋកម្ពុជា កើតនៅក្នុងប្រទេសកម្ពុជា រស់នៅក្នុងប្រទេសនេះតាំងពីតូចរហូតដល់ធំ ។ លោកគ្រូអ្នកគ្រូបានបង្រៀនខ្ញុំឲ្យស្រឡាញ់ជាតិសាសន៍ ស្រឡាញ់ប្រពៃណីវប្បធម៌ប្រជាជនខ្មែរ និងរស់នៅក្នុងសង្គមខ្មែរដែលមានតម្លៃបំផុត ។ ខ្ញុំគោរពនិងស្រឡាញ់ប្រទេសជាតិរបស់ខ្ញុំ ។ ខ្ញុំទៅសាលារៀន ខ្ញុំទៅធ្វើការ ខ្ញុំរស់ដោយរីករាយជាមួយក្រុមគ្រួសាររបស់ខ្ញុំ និងមានសេរីភាពជាប្រជាពលរដ្ឋកម្ពុជាម្នាក់ ។ ខ្ញុំគ្រាន់តែប្រាថ្នាចង់បានសន្តិភាពមួយពិតប្រាកដមិនមែនជាសន្តិភាពមួយលាយឡំដោយក្តីព្រួយបារម្ភនិងភាពភ័យខ្លាចឡើយ ហើយខ្ញុំសុំឲ្យប្រជាជនកម្ពុជាទាំងអស់មានឱកាសរៀនសូត្រ មានចំណេះដឹង ចៀសផុតពីសង្គ្រាម និងមានសន្តិភាពពេញលេញគ្រប់ពេលវេលាជារៀងរហូត ។


ក្រុមគ្រួសារ សើ សាយព្យាណា ក្នុងឆ្នាំ១៩៨៦

**សើ សាយព្យាណា**

# តើអ្នកណាជាអ្នកប្រល័យពូជសាសន៍?

## ខ្ញុំសូមគោរពជូនលោកនាយក ឆាំង យុ នាយកមជ្ឈមណ្ឌលស្រាវជ្រាវឯកសារកម្ពុជា

*លោកប្រធានជាទីស្រឡាញ់រាប់អានពីខ្ញុំដោយស្មោះ ខ្ញុំបាទបានទទួលទស្សនាវដ្ដីស្វែងរកការពិតអំពីលោកនាយកតាមសំណើរបស់ខ្ញុំ ហេតុនេះខ្ញុំមានចិត្តត្រេកអររកអ្វីប្រៀបស្មើពុំបានឡើយ ដោយខ្ញុំចង់បានទស្សនាវដ្ដីនេះយកមកចែកជូនបងប្អូនប្រជាពលរដ្ឋដែលនៅក្នុងភូមិឃុំខ្ញុំ បានអាន ដើម្បីស្វែងយល់ធាតុពិតរបបពួកខ្មែរក្រហម ប៉ុល ពត, អៀង សារី, ខៀវ សំផន។ “ថាតើអ្នកណាជាអ្នកប្រល័យពូជសាសន៍? ហើយប្រល័យពូជសាសន៍ដើម្បីអ្វី? ដើម្បីទឹកដី ឬ ជាតិសាសន៍” ។*

*ម្យ៉ាងទៀត ខ្ញុំចង់ឲ្យពួកកុមារ និស្សិត បញ្ញាវន្ត ជំនាន់ក្រោយ ស្វែងយល់ច្បាស់អំពីរបបកុម្មុយនិស្តនិងលទ្ធិប្រជាធិបតេយ្យតើខុសគ្នាយ៉ាងណា ដើម្បីកុំឲ្យរបបប្តូលទ្ធិកុម្មុយនិស្តនេះកើតឡើងម្តងទៀត ។*

*ឆ្លៀតក្នុងឱកាសបុណ្យចូលឆ្នាំថ្មីនេះ ខ្ញុំសូមគោរពជូនពរ សូមឲ្យលោកនាយក ព្រមទាំងបុគ្គលិកមជ្ឈមណ្ឌលស្រាវជ្រាវស្វែងរកការពិតកម្ពុជា សូមឲ្យលោកមានសុខភាពល្អ កម្លាំងមាំមួន បានជំនួយខ្លាំងក្លា បន្តការងារដូចក្តីប្រាថ្នាជារៀងរហូតទៅ ។ ផ្ញើនៅភូមិអង្គរនាប ឃុំត្រាំកក់ ស្រុកត្រាំកក់ តាកែវ ។ គួរពុំគួរសូមអភ័យទោស ។*

*ថ្ងៃ១២ មេសា ២០០៣,* **ឆាយ ថ្មុន**





ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា

ទស្សនាវដ្ដីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្ដីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្ដីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@online.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 43, July 2003.**
**Funded by Norway, Sweden, Switzerland, the Netherlands, Canada and USA.**